អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយាតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អនិច្ចតោ មនសិការោតីតិ ។

*បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្ន តែងធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគតដែរ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល កាលធ្វើទុកក្នុងចិត្ត នូវបច្ចុប្បន្ន ថាជាបច្ចុប្បន្ន តែងធ្វើទុកក្នុងចិត្ត នូវអតីត ថាជាអតីត តែងធ្វើទុកក្នុងចិត្ត នូវអនាគត ថាជាអនាគតដែរឬ ។ អើ ។ ការប្រជុំចុះ នៃផស្សៈទាំងបី ។ បេ ។ នៃចិត្តទាំងបីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២២៧] *បុគ្គលមិនគួរនិយាយថា បុគ្គលត្រាស់ដឹងហើយ ទើបធ្វើទុកក្នុងចិត្តឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួង មិនទៀងដូច្នេះ ក្នុងកាលណា រមែងនឿយណាយចំពោះទុក្ខ ក្នុងកាលនោះឯង នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធ បុគ្គលឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួង ជាទុក្ខដូច្នេះ ក្នុងកាលណា រមែងនឿយណាយចំពោះទុក្ខ ក្នុងកាលនោះឯង នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធ បុគ្គលឃើញច្បាស់ដោយបញ្ញាថា ធម៌ទាំងឡាយទាំងពួង ជាអនត្តាដូច្នេះ ក្នុងកាលណា រមែងនឿយណាយចំពោះទុក្ខ ក្នុងកាលនោះឯង នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលត្រាស់ដឹងហើយ ទើបធ្វើទុកក្នុងចិត្តមែន ។*

ចប់ អធិគ្គយ្ហមនសិការកថា ។

# រូបំ ហេតូតិកថា

[២២៨] រូបំ ហេតូតិ ។ អាមន្តា ។ អលោ-ភោ ហេតូតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អទោ-សោ ហេតុ ។ បេ ។ អមោហោ ហេតុ លោភោ ហេតុ ទោសោ ហេតុ មោហោ ហេតូតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ ហេតូតិ ។ អាមន្តា ។ សារម្មណំ អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ រូបំ ហេតូតិ ។

[២២៩] អលោភោ ហេតុ សារម្មណោ អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ រូបំ ហេតុ សារម្មណំ អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អទោសោ ហេតុ អមោហោ ហេតុ លោភោ ហេតុ ទោសោ ហេតុ អមោហោ ហេតុ សារម្មណោ អត្ថិ តស្ស អា-វដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ រូបំ ហេតុ

# រូបហេតុកថា

[២២៨] រូប ជាហេតុឬ ។ អើ ។ អលោភៈ ជាហេតុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អទោសៈ ជាហេតុឬ ។ បេ ។ អមោហៈ ជាហេតុ លោភៈ ជាហេតុ ទោសៈ ជាហេតុ មោហៈ ជាហេតុឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប ជាហេតុឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងរូប មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើរូប មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាហេតុទេ ។

[២២៩] អលោភៈ ជាហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះអលោភៈនោះ មានដែរឬ ។ អើ ។ រូប ជាហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អទោសៈ ជាហេតុ អមោហៈ ជាហេតុ លោភៈ ជាហេតុ ទោសៈ ជាហេតុ មោហៈ ជាហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះមោហៈនោះ មានដែរឬ ។ អើ ។ រូប ជាហេតុ

សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិ-ធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣០] រូបំ ហេតុ អនារម្មណំ នត្ថិ តស្ស អាវជ្ជ-នា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អលោភោ ហេតុ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ ហេតុ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធី-តិ ។ អាមន្តា ។ អទោសោ ហេតុ អមោហោ ហេតុ លោភោ ហេតុ ទោសោ ហេតុ មោហោ ហេតុ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិ-ធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣១] ន វត្តព្វំ រូបំ ហេតូតិ ។ អាមន្តា ។ ននុ មហាភូតា ឧបាទាយរូបានំ[១] ឧបាទាយហេតូ-តិ ។ អាមន្តា ។ ហញ្ចិ មហាភូតា ឧបាទាយរូបានំ ឧបាទាយហេតុ តេន វត រេ វត្តព្វេ រូបំ ហេតូតិ ។

រូបំ ហេតូតិកថា ។

---

១ ម. ឧបាទារូបានំ ។

ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣០] រូប ជាហេតុ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អលោភៈ ជាហេតុ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះអលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប ជាហេតុ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អទោសៈ ជាហេតុ អមោហៈ ជាហេតុ លោភៈ ជាហេតុ ទោសៈ ជាហេតុ មោហៈ ជាហេតុ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះមោហៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣១] បុគ្គលមិនគួរនិយាយថា រូប ជាហេតុទេឬ ។ អើ ។ ក្រែងមហាភូត ជាហេតុជាទីអាស្រ័យ របស់ពួកឧបាទាយរូបឬ ។ អើ ។ ប្រសិនបើមហាភូត ជាហេតុជាទីអាស្រ័យ របស់ពួកឧបាទាយរូប ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ជាហេតុមែន ។

ចប់ រូបហេតូតិកថា ។

# រូបំ សហេតុកន្តិកថា

[២៣២] រូបំ សហេតុកន្តិ ។ អាមន្តា ។ អលោភហេតុជាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អទោសហេតុជាតិ ។ បេ ។ អមោហហេតុជាតិ ។ បេ ។ លោភហេតុជាតិ ។ បេ ។ ទោសហេតុជាតិ ។ បេ ។ មោហហេតុជាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣៣] រូបំ សហេតុកន្តិ ។ អាមន្តា ។ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ រូបំ សហេតុកន្តិ ។

[២៣៤] អលោភោ សហេតុកោ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ រូបំ សហេតុកំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អទោសោ សហេតុកោ ។ បេ ។ អមោហោ សទ្ធា វីរិយំ សតិ សមាធិ បញ្ញា លោភោ ទោសោ មោហោ

# រូបសហេតុកទុកថា

[២៣២] រូប ប្រកបដោយហេតុឬ ។ អើ ។ រូប (ប្រកប) ដោយហេតុគឺអលោភៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយហេតុគឺអទោសៈ ។ បេ ។ ដោយហេតុគឺអមោហៈ ។ បេ ។ ដោយហេតុគឺលោភៈ ។ បេ ។ ដោយហេតុគឺទោសៈ ។ បេ ។ ដោយហេតុគឺមោហៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣៣] រូប ប្រកបដោយហេតុឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងរូប មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើរូប មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ប្រកបដោយហេតុទេ ។

[២៣៤] អលោភៈ ប្រកបដោយហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះអលោភៈនោះ មានដែរឬ ។ អើ ។ រូប ប្រកបដោយហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អទោសៈ ប្រកបដោយហេតុ ។ បេ ។ អមោហៈ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា លោភៈ ទោសៈ មោហៈ

មានោ ទិដ្ឋិ វិចិកិច្ឆា ថីនំ ឧទ្ធច្ចំ អហិរិកំ អនោត្តប្បំ សហេតុកំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ រូបំ សហេតុកំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣៥] រូបំ សហេតុកំ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អលោភោ សហេតុកោ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ សហេតុកំ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អទោសោ សហេតុកោ ។ បេ ។ អនោត្តប្បំ សហេតុកំ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣៦] ន វត្តព្វំ រូបំ សហេតុកន្តិ ។ អាមន្តា ។ ននុ រូបំ សប្បច្ចយន្តិ ។ អាមន្តា ។ ហញ្ចិ រូបំ សប្បច្ចយំ តេន វត រេ វត្តព្វេ រូបំ សហេតុកន្តិ ។

រូបំ សហេតុកន្តិកថា ។

មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ប្រកប ដោយហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្ត ទុក ចំពោះអនោត្តប្បៈនោះ មានដែរឬ ។ អើ ។ រូប ប្រកបដោយ ហេតុ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំ-ពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣៥] រូប ប្រកបដោយហេតុ តែមិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អលោភៈ ប្រកបដោយហេតុ តែមិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំង ចិត្តទុក ចំពោះអលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។ បេ ។ រូប ប្រកបដោយហេតុ តែមិនមានអារម្មណ៍ ការ រំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អទោសៈ ប្រកបដោយហេតុ ។ បេ ។ អនោត្តប្បៈ ប្រកបដោយហេតុ តែមិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះអនោត្ត-ប្បៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣៦] បុគ្គលមិនគួរនិយាយថា រូប ប្រកបដោយហេតុទេឬ ។ អើ ។ ក្រែងរូប ប្រកបដោយបច្ច័យឬ ។ អើ ។ ប្រសិនបើរូប ប្រកប ដោយបច្ច័យមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោល ថា រូប ប្រកបដោយហេតុមែន ។

ចប់ រូបសហេតុកន្តិកថា ។

# រូបំ កុសលាកុសលន្តិកថា

[២៣៧] រូបំ កុសលន្តិ ។ អាមន្តា ។ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ រូបំ កុសលន្តិ ។

[២៣៨] អលោភោ កុសលោ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ រូបំ កុសលំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អទោសោ កុសលោ ។ បេ ។ អមោហោ កុសលោ ។ បេ ។ សទ្ធា វីរិយំ សតិ សមាធិ ។ បេ ។ បញ្ញា កុសលា សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ រូបំ កុសលំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# រូបកុសលាកុសលន្តិកថា

[២៣៧] រូប ជាកុសលឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង រូបមិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើរូបមិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាកុសលទេ ។

[២៣៨] អលោភៈ ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះអលោភៈនោះ មានដែរឬ ។ អើ ។ រូប ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អទោសៈ ជាកុសល ។ បេ ។ អមោហៈ ជាកុសល ។ បេ ។ សទ្ធា វីរិយៈ សតិ សមាធិ ។ បេ ។ បញ្ញា ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះបញ្ញានោះ មានដែរឬ ។ អើ ។ រូប ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣៩] រូបំ កុសលំ អជារម្មណំ ជត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អលោភោ កុសលោ អជារម្មណោ ជត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ជ ហេវំ វត្តព្វេ ។ បេ ។ រូបំ កុស-លំ អជារម្មណំ ជត្ថិ តស្ស អាវជ្ជនា ។ បេ ។ ប-ណិធីតិ ។ អាមន្តា ។ អទោសោ កុសលោ ។ បេ ។ បញ្ញា កុសលា អជារម្មណា ជត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ជ ហេវំ វត្តព្វេ ។ បេ ។

[២៤០] រូបំ អកុសលន្តិ ។ អាមន្តា ។ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ជ ហេវំ វត្តព្វេ ។ បេ ។ ជនុ អជារម្មណំ ជត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អជារម្មណំ ជត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ ជោ វត រេ វត្តព្វេ រូបំ អកុសលន្តិ ។ បេ ។

[២៤១] លោភោ អកុសលោ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។

[២៣៩] រូប ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អលោភៈ ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះអលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ អទោសៈ ជាកុសល ។ បេ ។ បញ្ញា ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះបញ្ញានោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤០] រូប ជាអកុសលឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងរូប មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើរូប មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាអកុសលទេ ។ បេ ។

[២៤១] លោភៈ ជាអកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះលោភៈនោះ មានដែរឬ ។ អើ ។

១៣៣

រូបំ កុសលាកុសលន្តិកថា

រូបំ អកុសលំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ធោសោ មោហោ មានោ ។ បេ ។ អធោត្តប្បំ អកុសលំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ រូបំ អកុសលំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤២] រូបំ អកុសលំ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ លោភោ អកុសលោ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ អកុសលំ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ធោសោ មោហោ មានោ ។ បេ ។ អធោត្តប្បំ អកុសលំ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

រូបកុសលាកុសលន្តិកថា

រូប ជាអកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទោសៈ មោហៈ មានះ ។ បេ ។ អនោត្តប្បៈ ជាអកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះអនោត្តប្បៈនោះ មានដែរឬ ។ អើ ។ រូប ជាអកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤២] រូប ជាអកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ លោភៈ ជាអកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប ជាអកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ទោសៈ មោហៈ មានះ ។ បេ ។ អនោត្តប្បៈ ជាអកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះអនោត្តប្បៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤៣] ន វត្តព្វំ រូបំ កុសលម្បិ អកុសលម្បី-តិ ។ អាមន្តា ។ ននុ កាយកម្មំ វចីកម្មំ កុស-លម្បិ អកុសលម្បីតិ ។ អាមន្តា ។ ហញ្ចិ កាយ-កម្មំ វចីកម្មំ កុសលម្បិ អកុសលម្បិ តេន វត រេ វត្តព្វេ រូបំ កុសលម្បិ អកុសលម្បីតិ ។

រូបំ កុសលាកុសលន្តិកថា ។

## រូបំ វិបាកោតិកថា

[២៤៤] រូបំ វិបាកោតិ ។ អាមន្តា ។ រូបំ សុខវេទ-និយំ ទុក្ខវេទនិយំ អទុក្ខមសុខវេទនិយំ សុខាយ វេទ-នាយ សម្បយុត្តំ ទុក្ខាយ វេទនាយ សម្បយុត្តំ អទុក្ខ-មសុខាយ វេទនាយ សម្បយុត្តំ ផស្សេន សម្បយុត្តំ ។ បេ ។ ចិត្តេន សម្បយុត្តំ សារម្មណំ អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ រូបំ វិបាកោតិ ។

[២៤៣] បុគ្គលមិនគួរនិយាយថា រូប ជាកុសល ក៏មាន ជាអកុសលក៏មានទេឬ ។ អើ ។ ក្រែងកាយកម្មនិងវចីកម្ម ជាកុសល ក៏មាន ជាអកុសល ក៏មានឬ ។ អើ ។ ប្រសិនបើកាយកម្មនិងវចីកម្ម ជាកុសល ក៏មាន ជាអកុសល ក៏មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ជាកុសលក៏មាន ជាអកុសលក៏មាន ។

ចប់ រូបកុសលាកុសលន្តិកថា ។

# រូបវិបាកោតិកថា

[២៤៤] រូប ជាវិបាកឬ ។ អើ ។ រូប គួរដល់ការរងសុខ គួរដល់ការរងទុក្ខ គួរដល់ការរងអទុក្ខមសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ។ បេ ។ ប្រកបដោយចិត្ត ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង រូបមិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើរូប មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាវិបាកទេ ។

## រូបំ វិបាកោតិកថា

[២៤៥] ផស្សោ វិបាកោ ផស្សោ សុខវេទនិយោ ទុក្ខវេទនិយោ ។ បេ ។ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ រូបំ វិបាកោ រូបំ សុខវេទនិយំ ទុក្ខវេទនិយំ ។ បេ ។ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤៦] រូបំ វិបាកោ រូបំ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ផស្សោ វិបាកោ ផស្សោ ន សុខវេទនិយោ ន ទុក្ខវេទនិយោ ។ បេ ។ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤៧] ន វត្តព្វំ រូបំ វិបាកោតិ ។ អាមន្តា ។ ននុ កម្មស្ស កតត្តា ឧប្បន្នា ចិត្តចេតសិកា ធម្មា វិបាកោតិ ។ អាមន្តា ។ ហញ្ចិ កម្មស្ស កតត្តា ឧប្បន្នា ចិត្តចេតសិកា ធម្មា វិបាកោ តេន វត រេ វត្តព្វេ កម្មស្ស កតត្តា ឧប្បន្នំ រូបំ វិបាកោតិ ។

រូបំ វិបាកោតិកថា ។

## រូបវិបាកោតិកថា

[២៤៥] ផស្សៈ ជាវិបាក ផស្សៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ ។ បេ ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះផស្សៈនោះ មានដែរឬ ។ អើ ។ រូប ជាវិបាក រូប គួរដល់ការរងសុខ គួរដល់ការរងទុក្ខ ។ បេ ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤៦] រូប ជាវិបាក រូប មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ផស្សៈ ជាវិបាក ផស្សៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤៧] បុគ្គលមិនគួរនិយាយថា រូប ជាវិបាកទេឬ ។ អើ ។ ក្រែងធម៌ទាំងឡាយ ប្រកបដោយចិត្តនិងចេតសិកដែលកើតឡើងព្រោះធ្វើនូវកម្ម ជាវិបាកឬ ។ អើ ។ ប្រសិនបើធម៌ទាំងឡាយ ប្រកបដោយចិត្តនិងចេតសិកដែលកើតឡើងព្រោះធ្វើនូវកម្ម ជាវិបាកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ដែលកើតឡើងព្រោះធ្វើនូវកម្ម ជាវិបាក ។

ចប់ រូបវិបាកោតិកថា ។

# រូបំ រូបាវចររូបាវចរន្តិកថា

[២៤៨] អត្ថិ រូបំ រូបាវចរន្តិ ។ អាមន្តា ។ សមាបត្តេសិយំ ឧបបត្តេសិយំ ទិដ្ឋធម្មសុខវិហារំ សមាបត្តេសិយេន ចិត្តេន ឧបបត្តេសិយេន ចិត្តេន ទិដ្ឋធម្មសុខវិហារេន ចិត្តេន សហគតំ សហជាតំ សំសដ្ឋំ សម្បយុត្តំ ឯកុប្បាទំ ឯកនិរោធំ ឯកវត្ថុកំ ឯការម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សមាបត្តេសិយំ ន ឧបបត្តេសិយំ ន ទិដ្ឋធម្មសុខវិហារំ ន សមាបត្តេសិយេន ចិត្តេន(១) ឧបបត្តេសិយេន ចិត្តេន(២) ទិដ្ឋធម្មសុខវិហារេន ចិត្តេន សហគតំ សហជាតំ សំសដ្ឋំ សម្បយុត្តំ ឯកុប្បាទំ ឯកនិរោធំ ឯកវត្ថុកំ ឯការម្មណន្តិ ។ អាមន្តា ។ ហញ្ចិ ន សមាបត្តេសិយំ ន ឧបបត្តេសិយំ ន ទិដ្ឋធម្មសុខវិហារំ ន សមាបត្តេសិយេន ចិត្តេន ។ បេ ។ ឯការម្មណំ នោ វត រេ វត្តព្វេ អត្ថិ រូបំ រូបាវចរន្តិ ។

---

១-២ ឱ. ម. ឯត្ថន្តរេ នសទ្ទោ អត្ថិ ។

# រូបរូបាវចររូបាវចរន្តិកថា

[២៤៨] រូប ជារូបាវចរៈ មានដែរឬ ។ អើ ។ រូប ស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងរូប មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រ-កបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ចិត្តដែលមិនស្វែងរកកំណើត ចិត្តដែលមិននៅជាសុខក្នុងបច្ចុប្បន្នឬ ។ អើ ។ ប្រសិនបើរូប មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមា-បត្តិ ។ បេ ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជារូបាវចរៈមានទេ ។

១៣៧

## រូបំ រូបាវចរារូបាវចរន្តិកថា

[២៤៩] អត្ថិ រូបំ អរូបាវចរន្តិ ។ អាមន្តា ។ សមាបត្តេសិយំ ឧបបត្តេសិយំ ទិដ្ឋធម្មសុខវិហារំ សមាបត្តេសិយេន ចិត្តេន ឧបបត្តេសិយេន ចិត្តេន ទិដ្ឋធម្មសុខវិហារេន ចិត្តេន សហគតំ សហជាតំ សំសដ្ឋំ សម្បយុត្តំ ឯកុប្បាទំ ឯកនិរោធំ ឯកវត្ថុកំ ឯការម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សមាបត្តេសិយំ ន ឧបបត្តេសិយំ ន ទិដ្ឋធម្មសុខវិហារំ ន សមាបត្តេសិយេន ចិត្តេន ។ បេ ។ ឯការម្មណន្តិ ។ អាមន្តា ។ ហញ្ចិ ន សមាបត្តេសិយំ ន ឧបបត្តេសិយំ ។ បេ ។ ឯកវត្ថុកំ ឯការម្មណំ នោ វត រេ វត្តព្វេ អត្ថិ រូបំ អរូបាវចរន្តិ ។

[២៥០] ន វត្តព្វំ អត្ថិ រូបំ រូបាវចរំ អត្ថិ រូបំ អរូបាវចរន្តិ ។ អាមន្តា ។ ននុ កាមាវចរកម្មស្ស កតត្តា រូបំ កាមាវចរន្តិ ។ អាមន្តា ។ ហញ្ចិ កាមាវចរកម្មស្ស កតត្តា រូបំ កាមាវចរំ តេន វត រេ វត្តព្វេ រូបាវចរកម្មស្ស កតត្តា រូបំ រូបាវចរំ អរូបាវចរកម្មស្ស កតត្តា រូបំ អរូបាវចរន្តិ ។

រូបំ រូបាវចរារូបាវចរន្តិកថា ។

រូបរូបាវចរារូបាវចរន្តិកថា

[២៤៩] រូប ជាអរូបាវចរៈ មានដែរឬ ។ អើ ។ រូប ដែលស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំ-ណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ។ បេ ។ ក្រែងរូប មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន ។ បេ ។ មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ឬ ។ អើ ។ ប្រសិនបើរូប មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត ។ បេ ។ មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាអរូបាវចរៈ មានទេ ។

[២៥០] បុគ្គលមិនគួរនិយាយថា រូប ជារូបាវចរៈ ក៏មាន រូប ជាអរូបាវចរៈ ក៏មានទេឬ ។ អើ ។ ក្រែងរូប ជាកាមាវចរៈ ព្រោះធ្វើកម្មជាកាមាវចរៈឬ ។ អើ ។ ប្រសិនបើរូប ជាកាមាវចរៈ ព្រោះធ្វើកម្មជាកាមាវចរៈមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ជារូបាវចរៈ ព្រោះធ្វើកម្មជារូបាវចរៈ រូប ជាអរូបាវចរៈ ព្រោះធ្វើកម្មជាអរូបាវចរៈដែរ ។

ចប់ រូបរូបាវចរារូបាវចរន្តិកថា ។

# រូបរាគោ រូបធាតុបរិយាបន្នោតិអាទិកថា

[២៨១] រូបរាគោ រូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ សមាបត្តេសិយោ ឧបបត្តេសិយោ ទិដ្ឋធម្មសុខវិហារោ សមាបត្តេសិយេន ចិត្តេន ឧបបត្តេសិយេន ចិត្តេន ទិដ្ឋធម្មសុខវិហារេន ចិត្តេន សហគតោ សហជាតោ សំសដ្ឋោ សម្បយុត្តោ ឯកុប្បាទោ ឯកនិរោធោ ឯកវត្ថុកោ ឯការម្មណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សមាបត្តេសិយោ ន ឧបបត្តេសិយោ ន ទិដ្ឋធម្មសុខវិហារោ ន សមាបត្តេសិយេន ចិត្តេន ។ បេ ។ ឯកវត្ថុកោ ឯការម្មណោតិ ។ អាមន្តា ។ ហញ្ចិ ន សមាបត្តេសិយោ ន ឧបបត្តេសិយោ ន ទិដ្ឋធម្មសុខវិហារោ ន សមាបត្តេសិយេន ចិត្តេន ។ បេ ។ ឯកវត្ថុកោ ឯការម្មណោ នោ ច វត រេ វត្តព្វេ រូបរាគោ រូបធាតុបរិយាបន្នោតិ ។

[២៨២] រូបរាគោ រូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ សទ្ទរាគោ សទ្ទធាតុបរិយាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបរាគោ រូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ គន្ធរាគោ ។ បេ ។ រសរាគោ ។ បេ ។ ផោដ្ឋព្វរាគោ ផោដ្ឋព្វធាតុបរិយាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# រូបរាគរូបធាតុបរិយាបន្នោតិអាទិកថា

[២៥១] រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ រូបរាគៈ ដែលស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងរូបរាគៈ មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។ បេ ។ ទេឬ ។ អើ ។ ប្រសិនបើ រូបរាគៈ មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។ បេ ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុទេ ។

[២៥២] រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ សទ្ទរាគៈ រាប់បញ្ចូលក្នុងសទ្ទធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុដែរឬ ។ អើ ។ គន្ធរាគៈ ។ បេ ។ រសរាគៈ ។ បេ ។ ផោដ្ឋព្វរាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១៣៩

## រូបរាគោ រូបធាតុបរិយាបន្នោតិអាទិកថា

[២៤៣] សទ្ទរាគោ ន វត្តព្វំ សទ្ទធាតុបរិយា-
បន្នោតិ ។ អាមន្តា ។ រូបរាគោ ន វត្តព្វំ រូបធាតុ-
បរិយាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ គន្ធរា-
គោ ។ បេ ។ រសរាគោ ។ បេ ។ ផោដ្ឋព្វរាគោ ន
វត្តព្វំ ផោដ្ឋព្វធាតុបរិយាបន្នោតិ ។ អាមន្តា ។ រូប-
រាគោ ន វត្តព្វំ រូបធាតុបរិយាបន្នោតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

[២៤៤] អរូបរាគោ អរូបធាតុបរិយាបន្នោតិ ។
អាមន្តា ។ អរូបរាគោ ន វត្តព្វំ អរូបធាតុបរិយា-
បន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបរាគោ
អរូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ សមាបត្តេ-
សិយោ ឧបបត្តេសិយោ ទិដ្ឋធម្មសុខវិហារោ សមា-
បត្តេសិយេន ចិត្តេន ឧបបត្តេសិយេន ចិត្តេន ទិដ្ឋ-
ធម្មសុខវិហារេន ចិត្តេន សហគតោ សហជាតោ សំ-
សដ្ឋោ សម្បយុត្តោ ឯកុប្បាទោ ឯកនិរោធោ ឯក-
វត្ថុកោ ឯការម្មណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
ននុ ន សមាបត្តេសិយោ ន ឧបបត្តេសិយោ ន
ទិដ្ឋធម្មសុខវិហារោ ន សមាបត្តេសិយេន ចិត្តេន
។ បេ ។ ឯកវត្ថុកោ ឯការម្មណោតិ ។ អាមន្តា ។

រូបរាគរូបធាតុបរិយាបន្នោតិអាទិកថា

[២៥៣] បុគ្គលមិនគួរនិយាយថា សទ្ទរាគៈ រាប់បញ្ចូលក្នុងសទ្ទ-ធាតុទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា រូបរាគៈ រាប់បញ្ចូលក្នុងរូប-ធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល មិនគួរនិយាយថា គន្ធរាគៈ ។ បេ ។ រសរាគៈ ។ បេ ។ ផោដ្ឋព្វរាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុទេឬ ។ អើ ។ បុគ្គល មិនគួរនិយាយថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥៤] អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុឬ ។ អើ ។ អរូបរាគៈ ដែលស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រមមានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងអរូបរាគៈ ដែលមិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។ បេ ។ ឬ ។ អើ ។

ហាញ្ចិ ន សមាបត្តេសិយោ ន ឧបបត្តេសិយោ ន ទិដ្ឋ-
ធម្មសុខវិហារោ ន សមាបត្តេសិយេន ចិត្តេន ន ឧប-
បត្តេសិយេន ចិត្តេន ន ទិដ្ឋធម្មសុខវិហារេន ចិត្តេន
សហគតោ សហជាតោ សំសដ្ឋោ សម្បយុត្តោ ឯ-
កុប្បាទោ ឯកនិរោធោ ឯកវត្ថុកោ ឯការម្មណោ
នោ វត រេ វត្តព្វេ អរូបភវោ អរូបធាតុបរិយាបន្នោតិ ។

[២៨៥] អរូបភវោ អរូបធាតុបរិយាបន្នោតិ ។
អាមន្តា ។ សទ្ទភវោ សទ្ទធាតុបរិយាបន្នោតិ ។ ន
ហេវំ វត្តព្វេ ។ បេ ។ អរូបភវោ អរូបធាតុបរិយា-
បន្នោតិ ។ អាមន្តា ។ គន្ធភវោ ។ បេ ។ រសភវោ
។ បេ ។ ផោដ្ឋព្វភវោ ផោដ្ឋព្វធាតុបរិយាបន្នោតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[២៨៦] សទ្ទភវោ ន វត្តព្វំ សទ្ទធាតុបរិយា-
បន្នោតិ ។ អាមន្តា ។ អរូបភវោ ន វត្តព្វំ អរូប-
ធាតុបរិយាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ គន្ធ-
ភវោ ។ បេ ។ រសភវោ ។ បេ ។ ផោដ្ឋព្វភវោ
ន វត្តព្វំ ផោដ្ឋព្វធាតុបរិយាបន្នោតិ ។ អាមន្តា ។
អរូបភវោ ន វត្តព្វំ អរូបធាតុបរិយាបន្នោតិ ។ ន
ហេវំ វត្តព្វេ ។ បេ ។

ប្រសិនបើអរូបរាគៈ ដែលមិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ចិត្តដែលមិនស្វែងរកកំណើត ចិត្តដែលមិននៅជាសុខក្នុងបច្ចុប្បន្ន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេ ។

[២៥៥] អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុឬ ។ អើ ។ សទ្ទរាគៈ រាប់បញ្ចូលក្នុងសទ្ទធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុដែរឬ ។ អើ ។ គន្ធរាគៈ ។ បេ ។ រសរាគៈ ។ បេ ។ ផោដ្ឋព្វរាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥៦] បុគ្គលមិនគួរនិយាយថា សទ្ទរាគៈ រាប់បញ្ចូលក្នុងសទ្ទធាតុទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលមិនគួរនិយាយថា គន្ធរាគៈ ។ បេ ។ រសរាគៈ ។ បេ ។ ផោដ្ឋព្វរាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

រូបរាគោ រូបធាតុបរិយាបន្នោតិអាទិកថា

[២៤៧] ន វត្តព្វំ រូបរាគោ រូបធាតុបរិយាបន្នោ អរូបរាគោ អរូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ ននុ កាមរាគោ កាមធាតុបរិយាបន្នោតិ អាមន្តា ។ ហញ្ចិ កាមរាគោ កាមធាតុបរិយាបន្នោ តេន វត រេ វត្តព្វេ រូបរាគោ រូបធាតុបរិយាបន្នោ អរូបរាគោ អរូបធាតុបរិយាបន្នោតិ ។

រូបរាគោ រូបធាតុបរិយាបន្នោតិអាទិកថា ។

សោឡសមោ វគ្គោ ។

## តស្ស ឧទ្ទានំ

ចិត្តនិគ្គហោ ចិត្តបគ្គហោ សុខានុប្បទានំ អធិគ្គយ្ហមនសិការោ រូបំ ហេតុ រូបំ សហេតុកំ រូបំ កុសលម្បិ អកុសលម្បិ រូបំ វិបាកោ អត្ថិ រូបំ រូបាវចរំ អត្ថិ រូបំ អរូបាវចរំ សព្វេ កិលេសា កាមធាតុបរិយាបន្នាតិ ។

រូបរាគរូបធាតុបរិយាបន្នោតិអាទិកថា

[២៤៧] បុគ្គលមិនគួរនិយាយថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អើ ។ ក្រែងកាមរាគៈ រាប់បញ្ចូលក្នុងកាមធាតុឬ ។ អើ ។ ប្រសិនបើកាមរាគៈ រាប់បញ្ចូលក្នុងកាម-ធាតុមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុ អរូបរាគៈ រាប់បញ្ចូលក្នុងអរូបធាតុបាន ។

ចប់ រូបរាគអរូបធាតុបរិយាបន្នោតិអាទិកថា ។

ចប់ សោឡសមវគ្គ ។

## ឧទ្ទាននៃសោឡសមវគ្គនោះ គឺ

និយាយ អំពីការសង្កត់សង្កិនចិត្ត ១ ការទំនុកបម្រុងចិត្ត ១ ការប្រគល់ឲ្យនូវសេចក្ដីសុខ ១ ការត្រាស់ដឹងហើយទើបធ្វើទុកក្នុងចិត្ត ១ រូប ជាហេតុ ១ រូប ប្រកបដោយហេតុ ១ រូប ជាកុសលក៏មាន ជាអកុសលក៏មាន ១ រូប ជាវិបាក ១ រូប ជារូបាវចរៈក៏មាន រូប ជាអរូបាវចរៈក៏មាន ១ កិលេសទាំងអស់ រាប់បញ្ចូលក្នុងកាមធាតុ ១ ។

# អត្ថិ អរហតោ បុញ្ញូបចយោតិកថា

[២៤៨] អត្ថិ អរហតោ បុញ្ញូបចយោតិ ។ អាមន្តា ។ អត្ថិ អរហតោ អបុញ្ញូបចយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ អរហតោ អបុញ្ញូបចយោតិ ។ អាមន្តា ។ នត្ថិ អរហតោ បុញ្ញូបចយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤៩] អត្ថិ អរហតោ បុញ្ញូបចយោតិ ។ អាមន្តា ។ អរហា បុញ្ញាភិសង្ខារំ អភិសង្ខរោតិ អានេញ្ជាភិសង្ខារំ អភិសង្ខរោតិ គតិសំវត្តនិយំ កម្មំ ករោតិ ភវសំវត្តនិយំ កម្មំ ករោតិ អធិប្បច្ចយសំវត្តនិយំ កម្មំ ករោតិ មហាភោគសំវត្តនិយំ កម្មំ ករោតិ មហាបរិវារសំវត្តនិយំ កម្មំ ករោតិ ទេវសោភគ្យសំវត្តនិយំ កម្មំ ករោតិ មនុស្សសោភគ្យសំវត្តនិយំ កម្មំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦០] អត្ថិ អរហតោ បុញ្ញូបចយោតិ ។ អាមន្តា ។ អរហា អាចិនាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា អបចិនាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អត្ថិអរហតោបុញ្ញូបចយោតិកថា

[២៥៨] ការសន្សំបុណ្យ របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ការសន្សំបាប របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសន្សំបាប របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ការសន្សំបុណ្យ របស់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥៩] ការសន្សំបុណ្យ របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត តាក់តែងបុញ្ញាភិសង្ខារ តាក់តែងអានេញ្ជាភិសង្ខារ ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីគតិ ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីភព ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីបច្ច័យដ៏ក្រៃលែង ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីភោគៈច្រើន ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីមានបរិវារច្រើន ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីភាពដ៏ល្អលើសលែងក្នុងទេវលោក ធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីភាពដ៏ល្អលើសលែងក្នុងមនុស្សលោកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៦០] ការសន្សំបុណ្យ របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត សន្សំទុកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះអរហន្ត មិនមានការសន្សំទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១៤៣

## អត្ថិ អរហតោ បុញ្ញូបចយោតិកថា

អរហា បជហតីតិ ។ បេ ។ អរហា ឧចាជិយតីតិ ។ បេ ។ អរហា វិសិនេតីតិ ។ បេ ។ អរហា ឧស្សិនេតីតិ ។ បេ ។ អរហា វិធូបេតីតិ ។ បេ ។ អរហា សន្ធូបេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អរហា នេវាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា នេវាចិនាតិ នាបចិនាតិ អបចិនិត្វា ឋិតោ នោ វត រេ វត្តព្វេ អត្ថិ អរហតោ បុញ្ញូបចយោតិ ។

[២៦១] ននុ អរហា នេវ បជហតិ ន ឧចាជិយតិ បជហិត្វា ឋិតោ នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនិត្វា ឋិតោ នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ នោ វត រេ វត្តព្វេ អត្ថិ អរហតោ បុញ្ញូបចយោតិ ។

ព្រះអរហន្ត លះបង់ ។ បេ ។ ព្រះអរហន្ត ប្រកាន់ខ្ជាប់ ។ បេ ។ ព្រះអរហន្ត កកាយចេញ ។ បេ ។ ព្រះអរហន្ត ប្រមូលយក ។ បេ ។ ព្រះអរហន្ត កម្ចាត់ចេញ ។ បេ ។ ព្រះអរហន្ត ក្រសាវយកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្ត មិនសន្សំ មិនមែនជាមិនសន្សំ គឺលែងសន្សំហើយ ឋិតនៅឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត មិនសន្សំ មិនមែនជាមិនសន្សំ គឺលែងសន្សំហើយ ឋិតនៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យ របស់ព្រះអរហន្ត មានទេ ។

[២៦១] ក្រែងព្រះអរហន្ត មិនលះបង់ មិនប្រកាន់ខ្ជាប់ លុះលះបង់ហើយឋិតនៅ មិនកកាយចេញ មិនប្រមូលយក លុះកកាយចេញហើយឋិតនៅ មិនកម្ចាត់ចេញ មិនក្រសាវយក លុះកម្ចាត់ចេញហើយឋិតនៅឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត មិនកម្ចាត់ចេញ មិនក្រសាវយក លុះកម្ចាត់ចេញហើយឋិតនៅមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យ របស់ព្រះអរហន្ត មានទេ ។

[២៦២] ននុ អរហតោ បុញ្ញូបចយោតិ ។ អាមន្តា ។ អរហា ទានំ ទទេយ្យាតិ ។ អាមន្តា ។ ហញ្ចិ អរហា ទានំ ទទេយ្យ នោ វត រេ វត្តព្វេ ននុ អរហតោ បុញ្ញូបចយោតិ ។

[២៦៣] អរហា ចីវរំ ទទេយ្យ ។ បេ ។ បិណ្ឌបាតំ ទទេយ្យ សេនាសនំ ទទេយ្យ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទទេយ្យ ខាទនីយំ ទទេយ្យ ភោជនីយំ ទទេយ្យ បានីយំ ទទេយ្យ ចេតិយំ វន្ទេយ្យ ចេតិយេ មាលំ អារោបេយ្យ គន្ធំ អារោបេយ្យ វិលេបនំ អារោបេយ្យ ។ បេ ។ ចេតិយំ អភិទក្ខិណំ ករេយ្យាតិ ។ អាមន្តា ។ ហញ្ចិ អរហា ចេតិយំ អភិទក្ខិណំ ករេយ្យ នោ វត រេ វត្តព្វេ ននុ អរហតោ បុញ្ញូបចយោតិ ។

អត្ថិ អរហតោ បុញ្ញូបចយោតិកថា ។

# នត្ថិ អរហតោ អកាលមច្ចូតិកថា

[២៦៤] ននុ អរហតោ អកាលមច្ចូតិ ។ អាមន្តា ។ ននុ អរហន្តឃាតកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អរហន្តឃាតកោតិ ។ អាមន្តា ។

[២៦២] ការសន្សំបុណ្យ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ព្រះអរហន្ត គប្បីឲ្យទានដែរឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត គប្បីឲ្យទានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យ របស់ព្រះអរហន្ត មិនមានទេ ។

[២៦៣] ព្រះអរហន្ត គប្បីឲ្យចីវរ ។ បេ ។ គប្បីឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យវត្ថុគួរទំពាស៊ី ឲ្យវត្ថុគួរបរិភោគ ឲ្យទឹកគួរផឹក ថ្វាយបង្គំចេតិយ លើកឡើងនូវផ្កាកម្រងលើកឡើងនូវគ្រឿងក្រអូប លើកឡើងនូវគ្រឿងលាប ឮដ៏ចេតិយ ។ បេ ។ គប្បីធ្វើអភិទក្សិណាចេតិយដែរឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត គប្បីធ្វើអភិទក្សិណាចេតិយដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យ របស់ព្រះអរហន្ត មិនមានទេ ។

ចប់ អត្ថិ អរហតោ បុញ្ញូបចយោតិកថា ។

# នត្ថិ អរហតោ អកាលមច្ចូតិកថា

[២៦៤] សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មានដែរឬ ។ អើ ។

១៤៨

## នត្ថិ អរហតោ អកាលមច្ចូតិកថា

អត្ថិ អរហតោ អកាលមច្ចូតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ អរហតោ អកាលមច្ចូតិ ។ អាមន្តា ។ យោ អរហន្តំ ជីវិតា វោរោបេតិ សោ សតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតិ អសតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតីតិ ។ សតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតីតិ ។ ហញ្ចិ សតិ ជីវិតេ ជីវិតេវសេសេ ជីវិតា វោរោបេតិ នោ វត រេ វត្តព្វេ នត្ថិ អរហតោ អកាលមច្ចូតិ ។ អសតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតីតិ ។ នត្ថិ អរហន្តឃាតកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦៨] នត្ថិ អរហតោ អកាលមច្ចូតិ ។ អាមន្តា ។ អរហតោ កាយេ វិសំ ន កមេយ្យ សត្ថំ ន កមេយ្យ អគ្គិ ន កមេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អរហតោ កាយេ វិសំ កមេយ្យ សត្ថំ កមេយ្យ អគ្គិ កមេយ្យាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ កាយេ វិសំ កមេយ្យ សត្ថំ កមេយ្យ អគ្គិ កមេយ្យ

នត្ថិ អរហតោ អកាលមច្ចូតិកថា

សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បុគ្គលណា ផ្តាច់បង់ព្រះអរហន្តចាកជីវិត បុគ្គលនោះ កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិត កាលបើជីវិតមិនមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរឬ ។ (បុគ្គលនោះ) កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិត ។ ប្រសិនបើ (បុគ្គលនោះ) កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេ ។ (បុគ្គលនោះ) កាលបើជីវិតមិនមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៦៥] សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ថ្នាំពិសមិនគប្បីចូលទៅ គ្រឿងសស្ត្រាមិនគប្បីមុត ភ្លើងមិនគប្បីឆេះ ចំពោះកាយ របស់ព្រះអរហន្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង ថ្នាំពិសគប្បីចូលទៅ គ្រឿងសស្ត្រាគប្បីមុត ភ្លើងគប្បីឆេះ ចំពោះកាយ របស់ព្រះអរហន្តដែរឬ ។ អើ ។ ប្រសិនបើ ថ្នាំពិសគប្បីចូលទៅ គ្រឿងសស្ត្រាគប្បីមុត ភ្លើងគប្បីឆេះ ចំពោះកាយ របស់ព្រះអរហន្តដែរ ម្នាលអ្នកដ៏ចម្រើន

នោ វត រេ វត្តព្វេ នត្ថិ អរហតោ អកាលមច្ចូតិ ។

[២៦៦] អរហតោ កាយេ វិសំ ន កមេយ្យ សត្ថំ ន កមេយ្យ អគ្គិ ន កមេយ្យាតិ ។ អាមន្តា ។ នត្ថិ អរហន្តឃាតកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦៧] អត្ថិ អរហតោ អកាលមច្ចូតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា នាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវេទេត្វា ព្យន្តីភាវំ វទាមិ តញ្ច ខោ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ នត្ថិ អរហតោ អកាលមច្ចូតិ ។

នត្ថិ អរហតោ អកាលមច្ចូតិកថា ។

## សព្វមិទំ កម្មតោតិកថា

[២៦៨] សព្វមិទំ កម្មតោតិ ។ អាមន្តា ។ កម្មម្បិ កម្មតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វមិទំ កម្មតោតិ ។ អាមន្តា ។ សព្វមិទំ បុព្វេកតហេតូតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អ្នកមិនគួរពោលថា សេចក្ដីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេ ។

[២៦៦] ថ្នាំពិសមិនគប្បីចូលទៅ គ្រឿងសស្ត្រាមិនគប្បីមុត ភ្លើងមិនគប្បីឆេះ ចំពោះកាយ របស់អរហន្តទេឬ ។ អើ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៦៧] សេចក្ដីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលថា កម្មទាំងឡាយ ប្រកបដោយចេតនាដែលសត្វធ្វើហើយ សន្សំហើយ អស់ទៅ ព្រោះតែមិនបានទទួលផលដូច្នេះឡើយ កម្មនោះឯង គប្បីឲ្យផល ក្នុងបច្ចុប្បន្ន ឬ ក្នុងអត្តភាពជាលំដាប់ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សេចក្ដីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេ ។

ចប់ នត្ថិ អរហតោ អកាលមច្ចុតិកថា ។

# សព្វមិទំ កម្មតោតិកថា

[២៦៨] ធម្មជាត[១] ទាំងអស់នេះ មាន ព្រោះកម្មឬ ។ អើ ។ ចុះកម្ម មាន ព្រោះកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម្មជាតទាំងអស់នេះ មាន ព្រោះកម្មឬ ។ អើ ។ ធម្មជាតទាំងអស់នេះ ជាហេតុដែលធ្វើក្នុងកាលមុនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១ សំដៅចំពោះកម្មក្កិលេស និងវិបាកវដ្ដៈ ។

១៤៧

## សព្វមិទំ កម្មតោតិកថា

សព្វមិទំ កម្មតោតិ ។ អាមន្តា ។ សព្វមិទំ កម្មវិបាកតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វមិទំ កម្មវិបាកតោតិ ។ អាមន្តា ។ កម្មវិបាកេន បាណំ ហនេយ្យាតិ ។ អាមន្តា ។ បាណាតិបាតោ សផលោតិ ។ អាមន្តា ។ កម្មវិបាកោ សផលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កម្មវិបាកោ អផលោតិ ។ អាមន្តា ។ បាណាតិបាតោ អផលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កម្មវិបាកេន អទិន្នំ អាទិយេយ្យ ។ បេ ។ មុសា ភណេយ្យ បិសុណំ ភណេយ្យ ផរុសំ ភណេយ្យ សម្ផំ បលបេយ្យ សន្ធឹ ឆិន្ទេយ្យ និល្លោបំ ហរេយ្យ ឯកាគារិកំ ករេយ្យ បរិបន្ថេ តិដ្ឋេយ្យ បរទារំ គច្ឆេយ្យ គាមឃាតកំ ករេយ្យ និគមឃាតកំ ករេយ្យ កម្មវិបាកេន ទានំ ទទេយ្យ ចីវរំ ទទេយ្យ បិណ្ឌបាតំ ទទេយ្យ សេនាសនំ ទទេយ្យ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទទេយ្យាតិ ។ អាមន្តា ។ គិលានប្បច្ចយភេសជ្ជបរិក្ខារោ សផលោតិ ។ អាមន្តា ។ កម្មវិបាកោ សផលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កម្មវិបាកោ អផលោតិ ។ អាមន្តា ។ គិលានប្បច្ចយភេសជ្ជបរិក្ខារោ អផលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ធម្មជាតទាំងអស់នេះ មាន ព្រោះកម្មឬ ។ អើ ។ ធម្មជាតទាំងអស់នេះ មាន ព្រោះវិបាករបស់កម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម្មជាតទាំងអស់នេះ មាន ព្រោះវិបាករបស់កម្មឬ ។ អើ ។ បុគ្គលសម្លាប់សត្វ ដោយវិបាករបស់កម្មឬ ។ អើ ។ បាណាតិបាត មានផលដែរឬ ។ អើ ។ វិបាករបស់កម្ម មានផលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិបាករបស់កម្ម មិនមានផលទេឬ ។ អើ ។ បាណាតិបាត មិនមានផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ និយាយកុហក និយាយពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ កាត់នូវទី-តនៃផ្ទះ ប្លន់ពួកអ្នកស្រុក ប្លន់យកទ្រព្យតែផ្ទះមួយ ឈរចាំក្បែរផ្លូវ (ដើម្បីដណ្តើមយកទ្រព្យ) លួចប្រពន្ធបុគ្គលដទៃ សម្លាប់អ្នកស្រុក សម្លាប់អ្នកនិគម ដោយវិបាករបស់កម្ម បុគ្គល គប្បីឲ្យទាន គឺឲ្យចីវរ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដោយវិបាករបស់កម្មឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលដែរឬ ។ អើ ។ វិបាករបស់កម្ម មានផលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិបាករបស់កម្ម មិនមានផលទេឬ ។ អើ ។ គិលា-នប្បច្ចយភេសជ្ជបរិក្ខារ មិនមានផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៦៩] ន វត្តព្វំ សព្វមិទំ កម្មតោតិ ។ អា-
មន្តា ។ ននុ វុត្តំ ភគវតា

កម្មុនា វត្តតី លោកោ កម្មុនា វត្តតី បជា
កម្មនិពន្ធនា សត្តា រថស្សាណីវ យាយតោ
កម្មេន កិត្តឹ លភតេ បសំសំ
កម្មេន ជានិញ្ច វធញ្ច ពន្ធំ
តំ កម្មំ នានាករណំ វិទិត្វា
កស្មា វទេ នត្ថិ កម្មន្តិ លោកេតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សព្វ-
មិទំ កម្មតោតិ ។

សព្វមិទំ កម្មតោតិកថា ។

## ឥន្ទ្រិយពទ្ធកថា

[២៧០] ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខន្តិ ។ អាមន្តា ។ ឥន្ទ្រិយពទ្ធញ្ញេវ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ វិបរិណាមធម្មន្តិ ។

[២៦៩] បុគ្គលមិនគួរនិយាយថា ធម្មជាតទាំងអស់នេះ មាន ព្រោះកម្មទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

លោក ប្រព្រឹត្តទៅដោយកម្ម ពពួកសត្វប្រព្រឹត្តទៅដោយកម្ម សត្វទាំងឡាយ មានកម្មជាចំណង (ហេតុ) ដូចជាប្រែកទប់របស់រថកាលប្រព្រឹត្តទៅ បុគ្គល រមែងបាននូវកិត្តិសព្ទដោយកម្ម បាននូវសេចក្តីសរសើរដោយកម្ម បាននូវសេចក្តីវិនាសផង បាននូវសេចក្តីបៀតបៀនផង បាននូវការជាប់ចំណងផង ក៏ដោយកម្ម បុគ្គល បានដឹងនូវកម្មនោះថា មានអំពើផ្សេង ៗ គ្នាហើយ ហេតុអ្វីក៏និយាយថា កម្ម មិនមាន ក្នុងលោក

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម្មជាតទាំងអស់នេះ មាន ព្រោះកម្ម ។

ចប់ សព្វមិទំ កម្មតោតិកថា ។

# ឥន្ទ្រិយពទ្ធកថា

[២៧០] ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខឬ ។ អើ ។ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនិន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ វិបរិណាមធម្មន្តិ ។ អាមន្តា ។ ហញ្ចិ អនិន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ វិបរិណាមធម្មំ តេន វត រេ វត្តព្វេ ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខន្តិ ។

[២៧១] អនិន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ។ បេ ។ វិបរិណាមធម្មំ តញ្ច ន ទុក្ខន្តិ ។ អាមន្តា ។ ឥន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ ។ បេ ។ វិបរិណាមធម្មំ តញ្ច ន ទុក្ខន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ ។ បេ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ[១]ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាដែរឬ ។ អើ ។ ប្រសិនបើ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេ ។

[២៧២] ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ ។ បេ ។ មានការប្រែប្រួលទៅជាធម្មតា នោះឯង មិនមែនជាទុក្ខទេឬ ។ អើ ។ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។ បេ ។ មានការប្រែប្រួលទៅជាធម្មតា នោះឯង មិនមែនជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។ បេ ។

---

១ ផែនដី ភ្នំ ថ្មជាដើម ជារបស់មិនជាប់ដោយឥន្ទ្រិយ គឺមិនមានឥន្ទ្រិយ ។

វិបរិណាមធម្មំ តញ្ច ទុក្ខន្តិ ។ អាមន្តា ។ អនិន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ ។ បេ ។ វិបរិណាមធម្មំ តញ្ច ទុក្ខន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧២] ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខន្តិ ។ អាមន្តា ។ ននុ យទនិច្ចំ តំ ទុក្ខំ វុត្តំ ភគវតា អនិន្ទ្រិយពទ្ធំ អនិច្ចន្តិ ។ អាមន្តា ។ ហញ្ចិ យទនិច្ចំ តំ ទុក្ខំ វុត្តំ ភគវតា អនិន្ទ្រិយពទ្ធំ អនិច្ចំ តេន វត រេ វត្តព្វេ ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខន្តិ ។

[២៧៣] ន វត្តព្វំ ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខន្តិ ។ អាមន្តា ។ យថា ឥន្ទ្រិយពទ្ធស្ស ទុក្ខស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ឯវមេវ អនិន្ទ្រិយពទ្ធស្ស ទុក្ខស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

មានការប្រែប្រួលទៅជាធម្មតា នោះឯង ជាទុក្ខឬ ។ អើ ។ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។ បេ ។ មានការប្រែប្រួលទៅជាធម្មតា នោះឯង ជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧២] ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះ ជាទុក្ខ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀងឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀងមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេ ។

[២៧៣] បុគ្គលមិនគួរនិយាយថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេឬ ។ អើ ។ បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ ដោយការកំណត់ដឹងនូវទុក្ខ ដែលជាប់ទាក់ទងដោយឥន្ទ្រិយ យ៉ាងណា បុគ្គលប្រព្រឹត្តនៅព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដោយការកំណត់ដឹងនូវទុក្ខ ដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

យថា ឥន្ទ្រិយពទ្ធំ ទុក្ខំ បរិញ្ញាតំ ន បុន ឧប្បជ្ជតិ ឯវមេវ អនិន្ទ្រិយពទ្ធំ ទុក្ខំ បរិញ្ញាតំ ន បុន ឧប្បជ្ជ-តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ ឥន្ទ្រិ-យពទ្ធញ្ញេវ ទុក្ខន្តិ ។

ឥន្ទ្រិយពទ្ធកថា ។

## ឋបេត្វា អរិយមគ្គន្តិកថា

[២៧៤] ឋបេត្វា អរិយមគ្គំ អវសេសា សង្ខារា ទុក្ខាតិ ។ អាមន្តា ។ ទុក្ខសមុទយោបិ ទុក្ខោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទុក្ខសមុទយោបិ ទុក្ខោ-តិ ។ អាមន្តា ។ តីណេវ អរិយសច្ចានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តីណេវ អរិយសច្ចានីតិ ។ អាមន្តា ។ ននុ ចត្តារិ អរិយសច្ចានិ វុត្តានិ ភគវតា ទុក្ខំ ទុក្ខសមុទយោ ទុក្ខនិរោធោ ទុក្ខនិរោធគា-មិនី បដិបទាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារិ អរិយសច្ចា-និ វុត្តានិ ភគវតា ទុក្ខំ ទុក្ខសមុទយោ ទុក្ខនិរោ-ធោ ទុក្ខនិរោធគាមិនី បដិបទា នោ ច វត រេ វត្តព្វេ តីណេវ អរិយសច្ចានីតិ ។

*ទុក្ខ ជាប់ទាក់ទងដោយឥន្ទ្រិយ ដែលបុគ្គលកំណត់ដឹងហើយ មិនកើតឡើងទៀត យ៉ាងណា ទុក្ខ មិនជាប់ទាក់ទងដោយឥន្ទ្រិយ ដែលបុគ្គលកំណត់ដឹងហើយ មិនកើតឡើងទៀត ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខមែន ។*

ចប់ ឥន្ទ្រិយពទ្ធកថា ។

# បបេត្វា អរិយមគ្គន្តិកថា

[២៧៤] *សង្ខារទាំងឡាយដ៏សេសសល់ លើកលែងតែអរិយមគ្គចេញ ជាទុក្ខឬ ។ អើ ។ ចុះទុក្ខសមុទយៈ ក៏ជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចុះទុក្ខសមុទយៈ ក៏ជាទុក្ខដែរឬ ។ អើ ។ អរិយសច្ច មានតែ ៣ យ៉ាងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរិយសច្ច មានតែ ៣ យ៉ាងទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា អរិយសច្ច មាន ៤ យ៉ាង គឺ ទុក្ខ ១ ទុក្ខសមុទយៈ ១ ទុក្ខនិរោធ ១ ទុក្ខនិរោធគាមិនីបដិបទា ១ ឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគទ្រង់ត្រាស់ថា អរិយសច្ច មាន ៤ យ៉ាង គឺ ទុក្ខ ១ ទុក្ខសមុទយៈ ១ ទុក្ខនិរោធ ១ ទុក្ខនិរោធគាមិនីបដិបទា ១ មែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អរិយសច្ច មានតែ ៣ យ៉ាងនេះទេ ។*

[២៧៥] ទុក្ខសមុទយោបិ ទុក្ខោតិ ។ អាមន្តា ។ កោនដ្ឋេនាតិ ។ អនិច្ចដ្ឋេនាតិ ។ អរិយមគ្គោ អនិច្ចោតិ ។ អាមន្តា ។ អរិយមគ្គោ ទុក្ខោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរិយមគ្គោ អនិច្ចោ សោ ច ន ទុក្ខោតិ ។ អាមន្តា ។ ទុក្ខសមុទយោ អនិច្ចោ សោ ច ន ទុក្ខោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទុក្ខសមុទយោ អនិច្ចោ សោ ច ទុក្ខោតិ ។ អាមន្តា ។ អរិយមគ្គោ អនិច្ចោ សោ ច ទុក្ខោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧៦] ន វត្តព្វំ ឋបេត្វា អរិយមគ្គំ អវសេសា សង្ខារា ទុក្ខាតិ ។ អាមន្តា ។ ននុ សា ទុក្ខនិរោធគាមិនី បដិបទាតិ ។ អាមន្តា ។ ហញ្ចិ សា ទុក្ខនិរោធគាមិនី បដិបទា តេន វត រេ វត្តព្វេ ឋបេត្វា អរិយមគ្គំ អវសេសា សង្ខារា ទុក្ខាតិ ។

ឋបេត្វា អរិយមគ្គន្តិកថា ។

[២៧៥] ចុះ ទុក្ខសមុទយៈ ជាទុក្ខដែរឬ ។ អើ ។ ដោយអត្ថដូចម្ដេច ។ ដោយអត្ថថាមិនទៀង ។ ចុះអរិយមគ្គ មិនទៀងដែរឬ ។ អើ ។ អរិយមគ្គ ជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរិយមគ្គ មិនទៀង ចុះអរិយមគ្គនោះ មិនមែនជាទុក្ខទេឬ ។ អើ ។ ទុក្ខសមុទយៈ មិនទៀង ចុះទុក្ខសមុទយៈនោះ មិនមែនជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទុក្ខសមុទយៈ មិនទៀង ចុះទុក្ខសមុទយៈនោះ ជាទុក្ខឬ ។ អើ ។ អរិយមគ្គ មិនទៀង ចុះអរិយមគ្គនោះ ជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧៦] បុគ្គលមិនគួរនិយាយថា សង្ខារទាំងឡាយ ដ៏សេសសល់ លើកលែងតែអរិយមគ្គចេញ ជាទុក្ខឬ ។ អើ ។ ក្រែងទុក្ខនិរោធគាមិនីបដិបទានោះ មានឬ ។ អើ ។ ប្រសិនបើ ទុក្ខនិរោធគាមិនីបដិបទា មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ខារទាំងឡាយ ដ៏សេសសល់ លើកលែងតែអរិយមគ្គចេញ ជាទុក្ខ ។

ចប់ បបេត្វា អរិយមគ្គន្តិកថា ។

## ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា

[២៧៧] ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ ននុ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អាមន្តា ។ ហញ្ចិ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។

[២៧៨] ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ ននុ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតា តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។

## ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា

[២៧៧] បុគ្គលមិនគួរនិយាយថា សង្ឃ ទទួលទក្ខិណាទានបាន ទេឬ ។ អើ ។ ក្រែងសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកឬ ។ អើ ។ ប្រសិនបើសង្ឃ ជាអាហុនេយ្យបុគ្គល បាហុ-នេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ទទួលទក្ខិណាទានបាន ។

[២៧៨] បុគ្គលមិនគួរនិយាយថា សង្ឃ ទទួលទក្ខិណាទានបាន ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ទទួលទក្ខិណាទានបាន ។

[២៧៩] ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ ននុ អត្ថិ កោចិ សង្ឃស្ស ទានំ ទេន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ សង្ឃស្ស ទានំ ទេន្តិ តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ ននុ អត្ថិ កោចិ សង្ឃស្ស ចីវរំ ទេន្តិ ។ បេ ។ បិណ្ឌបាតំ ទេន្តិ សេនាសនំ ទេន្តិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេន្តិ ខាទនីយំ ទេន្តិ ភោជនីយំ ទេន្តិ ។ បេ ។ បានីយំ ទេន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ សង្ឃស្ស បានីយំ ទេន្តិ តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។

[២៨០] ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អាហុតិ ជាតវេទោវ  មហាមេឃំវ មេទនី
សង្ឃោ សមាធិសម្បន្នោ  បដិគ្គណ្ហាតិ ទក្ខិណន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។

[២៧៩] បុគ្គលមិនគួរនិយាយថា សង្ឃ ទទួលទក្ខិណាទានបាន ទេឬ ។ អើ ។ ក្រែងជនពួកខ្លះ ឲ្យទានដល់សង្ឃ មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ ឲ្យទានដល់សង្ឃ មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ទទួលទក្ខិណាទានបាន ។ ក្រែងជនពួកខ្លះ ឲ្យចីវរ ។ បេ ។ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យខាទនីយៈ ឲ្យភោជនីយៈ ។ បេ ។ ឲ្យទឹកគួរផឹក ដល់សង្ឃ មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ ឲ្យទឹកគួរផឹក ដល់សង្ឃ មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ទទួលទក្ខិណាទានបាន ។

[២៨០] បុគ្គលមិនគួរនិយាយថា សង្ឃ ទទួលទក្ខិណាទានបាន ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

សង្ឃ បរិបូណ៌ដោយសមាធិ ទទួលទក្ខិណាទាន បីដូចជា
ភ្លើងទទួលគ្រឿងបូជា ឬ ដូចជាផែនដីទទួលភ្លៀងធំ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សង្ឃ ទទួលទក្ខិណាទានបាន ។

១៩៥



[២៨១] សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ មគ្គោ បដិគ្គណ្ហាតិ ផលំ បដិគ្គណ្ហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា ។

# ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា

[២៨២] ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។ អាមន្តា ។ ននុ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អាមន្តា ។ ហញ្ចិ សង្ឃោ អាហុនេយ្យោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។

[២៨៣] ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។ អាមន្តា ។ ននុ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតា តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។

[២៨១] សង្ឃ ទទួលទក្ខិណាទានបានឬ ។ អើ ។ មគ្គ ទទួលទក្ខិណាទាន ផល ទទួលទក្ខិណាទានបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា ។

# ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា

[២៨២] បុគ្គលមិនគួរនិយាយថា សង្ឃ ញ៉ាំងទក្ខិណាទានឲ្យស្អាតទេឬ ។ អើ ។ ក្រែងសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកឬ ។ អើ ។ ប្រសិនបើ សង្ឃ ជាអាហុនេយ្យបុគ្គល ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ញ៉ាំងទក្ខិណាទានឲ្យស្អាត ។

[២៨៣] បុគ្គលមិនគួរនិយាយថា សង្ឃ ញ៉ាំងទក្ខិណាទានឲ្យស្អាតទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ញ៉ាំងទក្ខិណាទានឲ្យស្អាត ។

[២៨៤] ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។ អាមន្តា ។ ននុ អត្ថិ កោចិ សង្ឃស្ស ទានំ ទត្វា ទក្ខិណំ អារាធេន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ សង្ឃស្ស ទានំ ទត្វា ទក្ខិណំ អារាធេន្តិ តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។

[២៨៥] ននុ អត្ថិ កោចិ សង្ឃស្ស ចីវរំ ទត្វា ។ បេ ។ បិណ្ឌបាតំ ទត្វា ។ បេ ។ សេនាសនំ ទត្វា គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទត្វា ខាទនីយំ ទត្វា ភោជនីយំ ទត្វា ។ បេ ។ បានីយំ ទត្វា ទក្ខិណំ អារាធេន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ សង្ឃស្ស បានីយំ ទត្វា ទក្ខិណំ អារាធេន្តិ តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។

[២៨៦] សង្ឃោ ទក្ខិណំ វិសោធេតីតិ ។ អាមន្តា ។ មគ្គោ វិសោធេតិ ផលំ វិសោធេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា ។

[២៨៤] បុគ្គលមិនគួរនិយាយថា សង្ឃ ញុាំងទក្ខិណាទានឲ្យស្អាតទេឬ ។ អើ ។ ក្រែងជនពួកខ្លះ បានឲ្យទានដល់សង្ឃ ហើយញុាំងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ បានឲ្យទានដល់សង្ឃ ហើយញុាំងសង្ឃឲ្យត្រេកអរនឹងទក្ខិណា-ទាន មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ញុាំងទក្ខិណាទានឲ្យស្អាត ។

[២៨៥] ក្រែងជនពួកខ្លះ បានឲ្យចីវរ ។ បេ ។ ឲ្យបិណ្ឌបាត ។ បេ ។ ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យខាទនីយៈ ឲ្យភោជនីយៈ ។ បេ ។ ឲ្យទឹកគួរផឹក ដល់សង្ឃ ហើយញុាំងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ បានឲ្យទឹកគួរផឹក ដល់សង្ឃ ហើយញុាំងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ញុាំងទក្ខិណាទានឲ្យស្អាត ។

[២៨៦] សង្ឃ ញុាំងទក្ខិណាទានឲ្យស្អាតឬ ។ អើ ។ មគ្គ ញុាំងទក្ខិណាទានឲ្យស្អាត ផល ញុាំងទក្ខិណាទានឲ្យស្អាតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា ។

# ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា

[២៨៧] ន វត្តព្វំ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ
សាយតីតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ សង្ឃ-
ភត្តានិ ករោន្តិ ឧទ្ទេសភត្តានិ ករោន្តិ យាគុបា-
នានិ ករោន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ
សង្ឃភត្តានិ ករោន្តិ ឧទ្ទេសភត្តានិ ករោន្តិ យាគុ-
បានានិ ករោន្តិ តេន វត រេ វត្តព្វេ សង្ឃោ ភុញ្ជតិ
បិវតិ ខាទតិ សាយតីតិ ។

[២៨៨] ន វត្តព្វំ សង្ឃោ ភុញ្ជតិ បិវតិ ខាទ-
តិ សាយតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា គ-
ណភោជនំ បរម្បរភោជនំ អតិរិត្តភោជនំ អនតិរិត្ត-
ភោជនន្តិ ។ អាមន្តា ។ ហញ្ចិ វុត្តំ ភគវតា គណ-
ភោជនំ បរម្បរភោជនំ អតិរិត្តភោជនំ អនតិរិត្ត-
ភោជនំ តេន វត រេ វត្តព្វេ សង្ឃោ ភុញ្ជតិ បិវតិ
ខាទតិ សាយតីតិ ។

[២៨៩] ន វត្តព្វំ សង្ឃោ ភុញ្ជតិ បិវតិ ខាទ-
តិ សាយតីតិ ។ អាមន្តា ។ ននុ អដ្ឋ បានានិ
វុត្តានិ ភគវតា អម្ពបានំ ជម្ពុបានំ ចោចបានំ
មោចបានំ មធុបានំ មុទ្ទិកបានំ សាលុកបានំ

## ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា

[២៨៧] បុគ្គលមិនគួរនិយាយថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភក្សទេឬ ។ អើ ។ ក្រែងជនពួកខ្លះ ធ្វើសង្ឃភត្ត ធ្វើឧទ្ទេសភត្ត ធ្វើបបរនិងទឹក មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ ធ្វើសង្ឃភត្ត ធ្វើឧទ្ទេសភត្ត ធ្វើបបរនិងទឹក មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភក្សដែរ ។

[២៨៨] បុគ្គលមិនគួរនិយាយថា សង្ឃ បរិភោគ ផឹក ទំពា-ស៊ី លិទ្ធភក្សទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គណភោជន បរម្បរភោជន អតិរិត្តភោជន អនតិរិត្តភោជន មែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គណភោជន បរម្បរភោជន អតិរិត្តភោជន អនតិរិត្តភោជន មែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភក្សដែរ ។

[២៨៩] បុគ្គលមិនគួរនិយាយថា សង្ឃ បរិភោគ ផឹក ទំពា-ស៊ី លិទ្ធភក្ស ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទឹកបាន ប្រាំបីយ៉ាងគឺ ទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកឥតគ្រាប់ ទឹកផ្លែស្រគំ ទឹកផ្លែច័ន ទឹកក្រឡឹឈូក

ផរុសកបានន្តិ ។ អាមន្តា ។ ហញ្ចិ អដ្ឋ បានានិ វុត្តានិ ភគវតា អម្ពបានំ ជម្ពុបានំ ចោចបានំ មោចបានំ មធុបានំ មុទ្ទិកបានំ សាលុកបានំ ផរុសកបានំ តេន វត រេ វត្តព្វេ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។

[២៩០] សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។ អាមន្តា ។ មគ្គោ ភុញ្ជតិ បិវតិ ខាទតិ សាយតិ ផលំ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា ។

## ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

[២៩១] ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អាមន្តា ។ ហញ្ចិ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស តេន វត រេ វត្តព្វេ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។

ទឹកផ្លែមាក់ប្រាង មែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទឹកបាន ប្រាំបីយ៉ាងគឺ ទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកឥតគ្រាប់ ទឹកផ្លែស្រគំ ទឹកផ្លែច័ន ទឹកក្រឱឃ្មុក ទឹកផ្លែមាក់ប្រាង មែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក្ស ដែរ ។

[២៩០] សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក្ស ដែរឬ ។ អើ ។ មគ្គ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក្ស ផល បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក្ស ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា ។

# ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

[២៩១] បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែង ព្រះសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកដែរឬ ។ អើ ។ ប្រសិនបើ ព្រះសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

១៤៩

## ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

[២៩២] ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ ចត្តារោ បុរិសយុគា អដ្ឋ បុរិស-
បុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតាតិ ។ អា-
មន្តា ។ ហញ្ចិ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតា តេន វត រេ វត្តព្វេ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។

[២៩៣] ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សង្ឃេ គោតមិ ទេហិ សង្ឃេ តេ ទិន្នេ អហញ្ចេវ បូជិតោ ភវិស្សាមិ សង្ឃោ ចាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។

[២៩៤] ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។ អា-
មន្តា ។ ននុ សក្កោ ទេវានមិន្ទោ ភគវន្តំ ឯតទវោច

ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

[២៩២] បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរសបួនគូឬបុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

[២៩៣] បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនាងគោតមី នាងចូរឲ្យទាន ចំពោះសង្ឃចុះ កាលបើនាងឲ្យទាន ចំពោះសង្ឃហើយ តថាគតឯងក្តី សង្ឃក្តី ក៏ឈ្មោះថានាងបានបូជាហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

[២៩៤] បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះឥន្ទ ជាធំជាងទេវតា បានក្រាបបង្គំទូលព្រះមានព្រះភាគថា

យជមានានំ មនុស្សានំ ពុញ្ញបេក្ខាន បាណិនំ
ករោតំ ឱបធិកំ បុញ្ញំ កត្ថ ទិន្នំ មហប្ផលន្តិ
ចត្តារោ ច បដិបន្នា ចត្តារោ ច ផលេ ឋិតា
ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ
យជមានានំ មនុស្សានំ ពុញ្ញបេក្ខាន បាណិនំ
ករោតំ ឱបធិកំ បុញ្ញំ សង្ឃេ ទិន្នំ មហប្ផលន្តិ

ឯសោ ហិ សង្ឃោ វិបុលោ មហគ្គតោ
ឯសប្បមេយ្យោ ឧទធីវ សាគរោ
ឯតេ ហិ សេដ្ឋា នរវីរសាវកា
បភង្ករា ធម្មមុទីរយន្តិ[១]
តេសំ សុទិន្នំ សុហុតំ សុយិដ្ឋំ
យេ សង្ឃមុទ្ទិស្ស ទទន្តិ ទានំ
សា ទក្ខិណា សង្ឃគតា បតិដ្ឋិតា
មហប្ផលា លោកវិទូន វណ្ណិតា
ឯតាទិសំ យញ្ញមនុស្សរន្តា
យេ វេទជាតា វិចរន្តិ លោកេ
វិនេយ្យ មច្ឆេរមលំ សមូលំ

១ ម. ធម្មមុទីរយិស្សរេ ។

បុណ្យឲ្យផលក្នុងបច្ចុប្បន្ន ដែលពួកសត្វ គឺមនុស្ស អ្នកប្រាថ្នានូវបុណ្យ កាលបូជាធ្វើ គេឲ្យទាន ចំពោះបុគ្គលពួកណា ទើបមានផលច្រើន បុគ្គលអ្នកប្រតិបត្តិដើម្បីផល ៤ ពួក បុគ្គលអ្នកឋិតនៅក្នុងផល ៤ ពួក បុគ្គលទាំងនុ៎ះ ជាសង្ឃ មានចិត្តត្រង់ មានចិត្តតម្កល់មាំក្នុងបញ្ញានិងសីល បុណ្យឲ្យផលក្នុងបច្ចុប្បន្ន ដែលពួកសត្វ គឺមនុស្សអ្នកប្រាថ្នានូវបុណ្យ កាលបូជាធ្វើ គេឲ្យទានចំពោះសង្ឃ ទើបមានផលច្រើន ព្រោះបុគ្គលនុ៎ះ ជាសង្ឃ មានគុណ ដ៏ធំទូលាយ ដល់នូវភាពដ៏ប្រសើរ សង្ឃនុ៎ះ មានគុណរាប់មិនបាន ដូចជាសាគរទ្រទ្រង់នូវទឹក សង្ឃទាំងនុ៎ះឯង ជាសាវ័ក របស់ព្រះពុទ្ធមានព្យាយាមជាធំនរៈ អ្នកប្រសើរបំផុត ជាអ្នកធ្វើនូវពន្លឺ រមែងសម្តែងនូវធម៌ ទាន ដែលគេឲ្យដោយល្អ ដែលគេបូជាតូចដោយល្អ ដែលគេបូជាធំដោយល្អ ចំពោះសង្ឃទាំងនោះ (រមែងមានផលច្រើន) ពួកជនណា ឲ្យទាន ឧទ្ទិសចំពោះសង្ឃ ទក្ខិណាទាននោះ (របស់ពួកជននោះ) ឈ្មោះថាតាំងនៅក្នុងសង្ឃ ជាទានមានផលច្រើន ដែលព្រះពុទ្ធអ្នកជ្រាបច្បាស់នូវលោក ទ្រង់សរសើរហើយ ពួកជនណា កាលរឭកឃើញនូវការបូជា ដូច្នោះហើយ ជាអ្នកមានចិត្តរីករាយ គប្បីកម្ចាត់បង់នូវមន្ទិលគឺសេចក្តីកំណាញ់ ព្រមទាំងឫស ក្នុងលោក

អនិច្ឆិតា សក្កមុបេន្តិ ហានន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។

ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា ។

## ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា

[២៩៨] ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ ភគវា ទិបទានំ អគ្គោ ទិបទានំ សេដ្ឋោ ទិបទានំ បមោក្ខោ ទិបទានំ ឧត្តមោ ទិបទានំ បវរោ អសមោ អសមសមោ អប្បដិសមោ អប្បដិភាគោ អប្បដិបុគ្គលោតិ ។ អាមន្តា ។ ហញ្ចិ ភគវា ទិបទានំ អគ្គោ ទិបទានំ សេដ្ឋោ ទិបទានំ បមោក្ខោ ទិបទានំ ឧត្តមោ ទិបទានំ បវរោ អសមោ អសមសមោ អប្បដិសមោ អប្បដិភាគោ អប្បដិបុគ្គលោ តេន វត រេ វត្តព្វេ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។

ជនទាំងនោះ មិនមានគេនិន្ទា រមែងចូលទៅកាន់ឋានសួគ៌ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទាន ដែលបុគ្គលឲ្យចំពោះសង្ឃ ជាទានមានផលច្រើន ។

ចប់ ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា ។

# ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា

[២៩៥] បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ព្រះអង្គប្រសើរជាងពួកសត្វមានជើងពីរ វិសេសជាងពួកសត្វមានជើងពីរ ជាប្រធានរបស់ពួកសត្វមានជើងពីរ ខ្ពង់ខ្ពស់ជាងពួកសត្វមានជើងពីរ ថ្លៃថ្លាជាងពួកសត្វមានជើងពីរ មិនមានបុគ្គលស្មើ ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបស្មើ មិនមានចំណែកប្រៀប មិនមានបុគ្គលប្រៀបបានឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ព្រះអង្គប្រសើរជាងពួកសត្វមានជើងពីរ វិសេសជាងពួកសត្វមានជើងពីរ ជាប្រធានរបស់ពួកសត្វមានជើងពីរ ខ្ពង់ខ្ពស់ជាងពួកសត្វមានជើងពីរ ថ្លៃថ្លាជាងពួកសត្វមានជើងពីរ មិនមានបុគ្គលស្មើ ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបស្មើ មិនមានចំណែកប្រៀប មិនមានបុគ្គលប្រៀបបានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើន ។

[២៩៦] ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។ អា-
មន្តា ។ អត្ថិ កោចិ ពុទ្ធេន សមសមោ សីលេន
សមាធិនា បញ្ញាយាតិ ។ នត្ថិ ។ ហញ្ចិ នត្ថិ កោចិ
ពុទ្ធេន សមសមោ សីលេន សមាធិនា បញ្ញាយ
តេន វត រេ វត្តព្វេ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។

[២៩៧] ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។
អាមន្តា ។ ននុ វុត្តំ ភគវតា

នយិមស្មឹ វា លោកស្មឹ បរស្មឹ វា បន
ពុទ្ធេន សេដ្ឋោ ច សមោ ច វិជ្ជតិ
យមាហុនេយ្យានំ អគ្គតំ គតោ
បុញ្ញត្ថិកានំ វិបុលផលេសិនន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពុទ្ធស្ស
ទិន្នំ មហប្ផលន្តិ ។

ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា ។

[២៩៦] បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនទេឬ ។ អើ ។ បុគ្គលណាមួយ សមស្មើនឹងព្រះពុទ្ធ ដោយសីល សមាធិ និងបញ្ញា មានដែរឬ ។ មិនមានទេ ។ ប្រសិនបើ បុគ្គលណាមួយ សមស្មើនឹងព្រះពុទ្ធ ដោយសីល សមាធិ និងបញ្ញា មិនមានទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើន ។

[២៩៧] បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា

បុគ្គល ប្រសើរជាងព្រះពុទ្ធក្តី ស្មើនឹងព្រះពុទ្ធក្តី មិនមានក្នុង
លោកនេះ និងក្នុងលោកខាងមុខឡើយ ព្រោះថា ព្រះពុទ្ធ
ទ្រង់ដល់នូវភាវៈប្រសើរ ជាងពួកអាហុនេយ្យបុគ្គល របស់ពួក
ជនអ្នកត្រូវការដោយបុណ្យ អ្នកស្វែងរកផលដ៏ធំទូលាយ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើន ។

ចប់ ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា ។

# ទក្ខិណាវិសុទ្ធិកថា

[២៩៨] ឆាយកាតោ វ ធានំ វិសុជ្ឈតិ ដោ បដិ-
ក្គាហកតោតិ ។ អាមន្តា ។ ឆនុ អត្ថិ កោចិ បដិក្គា-
ហកា អាហុនេយ្យា ចាហុនេយ្យា ឧក្ខិណេយ្យា
អញ្ជលិករណីយា អឆុត្តរំ បុញ្ញក្ខេត្តំ លោកស្សា-
តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ បដិក្គាហកា
អាហុនេយ្យា ចាហុនេយ្យា ឧក្ខិណេយ្យា អញ្ជលិ-
ករណីយា អឆុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ដោ វត
វេ វត្តព្វេ ឆាយកាតោ វ ធានំ វិសុជ្ឈតិ ដោ បដិក្គា-
ហកតោតិ ។

[២៩៩] ឆាយកាតោ វ ធានំ វិសុជ្ឈតិ ដោ បដិ-
ក្គាហកតោតិ ។ អាមន្តា ។ ឆនុ ចត្តារោ បុរិស-
យុគា អដ្ឋ បុរិសបុគ្គលា ឧក្ខិណេយ្យា វុត្តា ភគវ-
តាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ បុរិសយុគា អដ្ឋ
បុរិសបុគ្គលា ឧក្ខិណេយ្យា វុត្តា ភគវតា ដោ វត
វេ វត្តព្វេ ឆាយកាតោ វ ធានំ វិសុជ្ឈតិ ដោ បដិក្គា-
ហកតោតិ ។

# ទក្ខិណាវិសុទ្ធិកថា

[២៩៨] ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេឬ ។ អើ ។ ក្រែងបដិគ្គាហកៈពួកខ្លះ គួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលអាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្ត ដ៏ប្រសើរ របស់សត្វលោក មានដែរឬ ។ អើ ។ ប្រសិនបើ បដិគ្គាហកៈពួកខ្លះ គួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលអាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្ត ដ៏ប្រសើរ របស់សត្វលោក មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេ ។

[២៩៩] ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរស ៤ គូ ឬ បុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរស ៤ គូ ឬ បុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេ ។

[៣០០] ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។ អាមន្តា ។ ននុ អត្ថិ កោចិ សោតាបន្នោ ទានំ ទត្វា ទក្ខិណំ អារាធេតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ សោតាបន្នោ ទានំ ទត្វា ទក្ខិណំ អារាធេតិ នោ វត រេ វត្តព្វេ ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។ ននុ អត្ថិ កោចិ សកទាគាមិស្ស ។ បេ ។ អនាគាមិស្ស ។ បេ ។ អរហតោ ទានំ ទត្វា ទក្ខិណំ អារាធេតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អរហតោ ទានំ ទត្វា ទក្ខិណំ អារាធេតិ នោ វត រេ វត្តព្វេ ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។

[៣០១] បដិគ្គាហកតោ វ ទានំ វិសុជ្ឈតិ នោ ទាយកតោតិ ។ អាមន្តា ។ អញ្ញោ អញ្ញស្ស ការកោ បរកតំ សុខទុក្ខំ អញ្ញោ ករោតិ អញ្ញោ បដិសំវេទេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចតស្សោ ខោ ឥមា អានន្ទ ទក្ខិណាវិសុទ្ធិយោ ។ កតមា ចតស្សោ ។

[៣០០] ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេឬ ។ អើ ។ ក្រែងបុគ្គលពួកខ្លះ ឲ្យទាន ចំពោះសោតាបន្នបុគ្គល ហើយញ៉ាំងសោតាបន្នបុគ្គល ឲ្យត្រេកអរ ចំពោះទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលពួកខ្លះ ឲ្យទានចំពោះសោតាបន្នបុគ្គល ហើយញ៉ាំងសោតាបន្នបុគ្គល ឲ្យត្រេកអរ ចំពោះទក្ខិណាទាន មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេ ។ ក្រែងបុគ្គលពួកខ្លះ ឲ្យទាន ចំពោះសកទាគាមិបុគ្គល ។ បេ ។ ចំពោះអនាគាមិបុគ្គល ។ បេ ។ ចំពោះព្រះអរហន្ត ហើយញ៉ាំងព្រះអរហន្ត ឲ្យត្រេកអរ ចំពោះទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលពួកខ្លះ ឲ្យទាន ចំពោះព្រះអរហន្ត ហើយញ៉ាំងព្រះអរហន្ត ឲ្យត្រេកអរ ចំពោះទក្ខិណាទាន មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេ ។

[៣០១] ទាន បរិសុទ្ធតែអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយកទេឬ ។ អើ ។ បុគ្គលដទៃ ជាអ្នកធ្វើ ដល់បុគ្គលដទៃ សុខទុក្ខដែលបុគ្គលដទៃធ្វើ បុគ្គលដទៃ ធ្វើ បុគ្គលដទៃ ទទួលផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិនេះ មាន ៤ យ៉ាង ។ ទក្ខិណាវិសុទ្ធិ ៤ យ៉ាង តើដូចម្តេច ។

អត្ថានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ ប-
ដិគ្គាហកតោ អត្ថានន្ទ ទក្ខិណា បដិគ្គាហកតោ
វិសុជ្ឈតិ នោ ទាយកតោ អត្ថានន្ទ ទក្ខិណា នេវ
ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ អត្ថានន្ទ
ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ
ច កថញ្ចានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ
នោ បដិគ្គាហកតោ ឥធានន្ទ ទាយកោ ហោតិ
សីលវា កល្យាណធម្មោ បដិគ្គាហកា ហោន្តិ ទុស្សី-
លា បាបធម្មា ឯវំ ខោ អានន្ទ ទក្ខិណា ទាយ-
កតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ កថញ្ចានន្ទ
ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ
ឥធានន្ទ ទាយកោ ហោតិ ទុស្សីលោ បាបធម្មោ
បដិគ្គាហកា ហោន្តិ សីលវន្តោ កល្យាណធម្មា ឯវំ
ខោ អានន្ទ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ
ទាយកតោ កថញ្ចានន្ទ ទក្ខិណា នេវ ទាយក-
តោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ឥធានន្ទ ទាយ-
កោ ច ហោតិ ទុស្សីលោ បាបធម្មោ បដិគ្គា-
ហកា ច ហោន្តិ ទុស្សីលា បាបធម្មា ឯវំ ខោ
អានន្ទ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ

## ទក្ខិណាវិសុទ្ធិកថា

ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ ក៏មាន ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក ក៏មាន ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ ក៏មាន ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធ អំពីទាយកផង អំពីបដិគ្គាហកៈផង ក៏មាន ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ មានសីល មានធម៌ល្អ ពួកបដិគ្គាហកៈ ទ្រុស្តសីល មានធម៌អាក្រក់ ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ ទ្រុស្តសីល មានធម៌អាក្រក់ ពួកបដិគ្គាហកៈ មានសីល មានធម៌ល្អ ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ ទ្រុស្តសីល មានធម៌អាក្រក់ ពួកបដិគ្គាហកៈ ក៏ទ្រុស្តសីល មានធម៌អាក្រក់ដូចគ្នា ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក

នោ បដិគ្គាហកតោ កថញ្ចានន្ទ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ឥធានន្ទ ទាយកោ ច ហោតិ សីលវា កល្យាណធម្មោ បដិគ្គាហកា ច ហោន្តិ សីលវន្តោ កល្យាណធម្មា ឯវំ ខោ អានន្ទ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ឥមា ខោ អានន្ទ ចតស្សោ ទក្ខិណាវិសុទ្ធិយោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។

ទក្ខិណាវិសុទ្ធិកថា ។

សត្តរសមោ វគ្គោ ។

## តស្ស ឧទ្ទានំ

អត្ថិ អរហតោ បុញ្ញូបចយោ នត្ថិ អរហតោ អកាលមច្ចុ សព្វមិទំ កម្មតោ ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខំ ឋបេត្វា អរិយមគ្គំ អវសេសា សង្ខារា ទុក្ខា សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតិ សង្ឃោ ទក្ខិណំ វិសោធេតិ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតិ សង្ឃស្ស ទិន្នំ មហប្ផលំ អត្ថិ ទានំ វិសុជ្ឈតីតិ ។

*មិនបរិសុទ្ធអំពីបដិគ្គាហកៈ យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធ អំពីទាយកផង អំពីបដិគ្គាហកៈផង តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ មានសីល មានធម៌ល្អ ពួកបដិគ្គាហកៈ ក៏មាន សីល មានធម៌ល្អដូចគ្នា ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធ អំពី ទាយកផង អំពីបដិគ្គាហកៈផង យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិ មាន ៤ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទាន បរិសុទ្ធអំពីតែទាយក មិន បរិសុទ្ធអំពីបដិគ្គាហកៈទេ ។*

ចប់ ទក្ខិណាវិសុទ្ធិកថា ។

ចប់ សត្តរសមវគ្គ ។

# ឧទ្ទាននៃសត្តរសមវគ្គនោះ គឺ

*និយាយ អំពីការសន្សំបុណ្យ របស់ព្រះអរហន្ត មាន ១ អកាលមច្ចុ របស់ព្រះអរហន្ត មិនមាន ១ ធម្មជាតទាំងអស់នេះមាន ព្រោះ កាម ១ ធម្មជាតជាប់ដោយឥន្ទ្រិយ ជាទុក្ខ ១ សង្ខារដ៏សេស វៀរលែងតែអរិយមគ្គ ជាទុក្ខ ១ ព្រះសង្ឃ តែងទទួលទក្ខិណាទាន ១ ព្រះសង្ឃ តែងជម្រះទក្ខិណាទាន ១ ព្រះសង្ឃតែង ឆាន់ ផឹក ទំពាស៊ី ភ្លក្ស ១ ទាន ដែលបុគ្គលឲ្យដល់សង្ឃ មាន ផលច្រើន ១ ទាន បរិសុទ្ធ ក៏មាន ១ ។*

# មនុស្សលោកកថា

[៣០២] ន វត្តព្វំ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។ អាមន្តា ។ ននុ អត្ថិ ពុទ្ធវុត្ថានិ ចេតិយានិ អារាមវិហារគាមនិគមនគរានិ រដ្ឋានិ ជនបទានីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ ពុទ្ធវុត្ថានិ ចេតិយានិ អារាមវិហារគាមនិគមនគរានិ រដ្ឋានិ ជនបទានិ តេន វត រេ វត្តព្វេ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។

[៣០៣] ន វត្តព្វំ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។ អាមន្តា ។ ននុ ភគវា លុម្ពិនិយា ជាតោ ពោធិយា មូលេ អភិសម្ពុទ្ធោ ពារាណសិយំ ភគវតា ធម្មចក្កំ បវត្តិតំ ចាបាលេ ចេតិយេ អាយុសង្ខារោ ឱស្សដ្ឋោ កុសិនារាយំ ភគវា បរិនិព្ពុតោតិ ។ អាមន្តា ។ ហញ្ចិ ភគវា លុម្ពិនិយា ជាតោ ។ បេ ។ កុសិនារាយំ ភគវា បរិនិព្ពុតោ តេន វត រេ វត្តព្វេ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។

[៣០៤] ន វត្តព្វំ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

# មនុស្សលោកកថា

[៣០២] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងចេតិយ អារាម វិហារ ស្រុក និគម នគរ ដែន ជនបទ ដែលព្រះពុទ្ធគង់នៅហើយ មានដែរឬ ។ អើ ។ ប្រសិនបើ ចេតិយ អារាម វិហារ ស្រុក និគម នគរ ដែន ជនបទ ដែលព្រះពុទ្ធគង់នៅហើយ មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកដែរ ។

[៣០៣] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ប្រសូតក្នុងលុម្ពិនីវ័ន ត្រាស់ដឹងទៀបគល់ពោធិព្រឹក្ស ព្រះមានព្រះភាគ ទ្រង់ញុំាំងធម្មចក្កឲ្យប្រព្រឹត្តទៅជិតក្រុងពារាណសី ព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារជិតបាវាលចេតិយ ព្រះមានព្រះភាគ ទ្រង់បរិនិព្វានជិតក្រុងកុសិនារាឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគទ្រង់ប្រសូត ក្នុងលុម្ពិនីវ័ន ។ បេ ។ ព្រះមានព្រះភាគ ទ្រង់បរិនិព្វានជិតក្រុងកុសិនារា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះពុទ្ធមានព្រះ-ភាគ ទ្រង់គង់នៅក្នុងមនុស្សលោកដែរ ។

[៣០៤] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ឯកមិទាហំ ភិក្ខវេ សមយំ ឧក្កដ្ឋាយំ វិហរាមិ សុភ-គវនេ សាលរាជមូលេតិ ឯកមិទាហំ ភិក្ខវេ សម-យំ ឧរុវេលាយំ វិហរាមិ អជបាលនិគ្រោធេ បឋមា-ភិសម្ពុទ្ធោតិ ឯកមិទាហំ ភិក្ខវេ សមយំ រាជគហេ វិហរាមិ វេឡុវនេ កលន្ទកនិវាបេតិ ឯកមិទាហំ ភិក្ខវេ សមយំ សាវត្ថិយំ វិហរាមិ ជេតវនេ អនាថ-បិណ្ឌិកស្ស អារាមេតិ ឯកមិទាហំ ភិក្ខវេ សមយំ វេសាលិយំ វិហរាមិ មហាវនេ កូដាគារសាលាយន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។

[៣០៨] ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។ អាមន្តា ។ ននុ ភគវា លោកេ ជាតោ លោកេ សំវឌ្ឍោ លោកំ អភិភុយ្យ វិហរតិ អនុបលិត្តោ លោកេនាតិ ។ អាមន្តា ។ ហញ្ចិ ភគវា លោកេ ជាតោ លោកេ សំវឌ្ឍោ លោកំ អភិភុយ្យ វិហរតិ អនុបលិត្តោ លោកេន តេន វត រេ វត្តព្វេ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។

មនុស្សលោកកថា ។

ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគត គង់នៅទៀបគល់សាល-រាជព្រឹក្ស ក្នុងព្រៃសុភគៈ ជិតក្រុងឈ្មោះឧក្កដ្ឋា ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគត បានត្រាស់ដឹងជាដំបូង ទៀបអជបាលនិគ្រោធ ក្នុងឧរុវេលប្រទេស ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគត គង់នៅក្នុងវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគហៈ ម្នាលភិក្ខុទាំង-ឡាយ សម័យមួយ តថាគត គង់នៅក្នុងវត្តជេតពន ជាអារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគត គង់នៅក្នុងកុដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅក្នុងមនុស្សលោកដែរ ។

[៣០៥] ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅ ក្នុងមនុស្សលោកដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ កើតក្នុងលោក ចម្រើនក្នុងលោក គ្របសង្កត់លោក មិនជាប់ដោយលោកឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ កើតក្នុងលោក ចម្រើនក្នុងលោក គ្របសង្កត់លោក មិនជាប់ដោយលោក ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅ ក្នុងមនុស្សលោកទេ ។

ចប់ មនុស្សលោកកថា ។

# ធម្មទេសនាកថា

[៣០៦] ន វត្តព្វំ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។ អាមន្តា ។ កេន ទេសិតោតិ ។ អភិនិម្មិតេន ទេសិតោតិ ។ អភិនិម្មិតោ ជិនោ សត្ថា សម្មាសម្ពុទ្ធោ សព្វញ្ញូ សព្វទស្សាវី ធម្មស្សាមី ធម្មប្បដិសរណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ន វត្តព្វំ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។ អាមន្តា ។ កេន ទេសិតោតិ ។ អាយស្មតា អានន្ទេន ទេសិតោតិ ។ អាយស្មា អានន្ទោ ជិនោ សត្ថា សម្មាសម្ពុទ្ធោ សព្វញ្ញូ សព្វទស្សាវី ធម្មស្សាមី ធម្មប្បដិសរណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣០៧] ន វត្តព្វំ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សង្ខិត្តេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ វិត្ថារេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ សង្ខិត្តវិត្ថារេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ អញ្ញាតារោ ច ទុល្លភាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។

# ធម្មទេសនាកថា

[៣០៦] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ទេឬ ។ អើ ។ ចុះអ្នកណា សម្តែងធម៌ ។ ព្រះពុទ្ធ-និម្មិតសម្តែង ។ ចុះព្រះពុទ្ធនិម្មិត ជាព្រះជិនស្រី ជាសាស្តា ជាសម្មា-សម្ពុទ្ធ ជាសព្វញ្ញុពុទ្ធ ឃើញនូវធម៌ទាំងពួង ជាធម្មស្សាមី មានធម៌ជាទីរលឹកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ទេឬ ។ អើ ។ ចុះអ្នកណា សម្តែង ។ ព្រះអានន្ទមានអាយុ សម្តែង ។ ព្រះអានន្ទមានអាយុ ជាព្រះជិនស្រី ជាសាស្តា ជាសម្មាសម្ពុទ្ធ ជាសព្វញ្ញុពុទ្ធ ឃើញនូវធម៌ទាំងពួង ជាធម្មស្សាមី មានធម៌ជាទីរលឹកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣០៧] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត តថាគត គប្បីសម្តែងធម៌ ដោយសង្ខេបខ្លះ ម្នាលសារីបុត្ត តថាគត គប្បីសម្តែងធម៌ ដោយពិស្តារខ្លះ ម្នាលសារីបុត្ត តថាគត គប្បីសម្តែងធម៌ ដោយសង្ខេបនិងពិស្តារខ្លះ ព្រោះបុគ្គលអ្នកត្រាស់ដឹង រកបានដោយកម្រ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ ។

[៣០៨] ន វត្តព្វំ ពុទ្ធេន ភគវតា ធម្មោ ទេសិ-
តោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា អភិញ្ញា-
យាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អនភិញ្ញាយ ស-
និទានាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អនិទានំ
សប្បាដិហារិយាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អប្បា-
ដិហារិយំ យញ្ច មយ្ហំ ភិក្ខវេ អភិញ្ញាយ ធម្មំ ទេ-
សយតោ នោ អនភិញ្ញាយ សនិទានំ ធម្មំ ទេស-
យតោ នោ អនិទានំ សប្បាដិហារិយំ ធម្មំ ទេស-
យតោ នោ អប្បាដិហារិយំ ករណីយោ ឱវាទោ
ករណីយា អនុសាសនី អលញ្ច បន វោ ភិក្ខវេ
តុដ្ឋិយា អលំ អត្តមនតាយ អលំ សោមនស្សាយ
សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ធម្មោ សុបដិបន្នោ
សង្ឃោតិ ឥមស្មឹ ច បន វេយ្យាករណស្មឹ ភញ្ញ-
មានេ ទសសហស្សី លោកធាតុ អកម្បិត្ថាតិ
អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពុទ្ធេន
ភគវតា ធម្មោ ទេសិតោតិ ។

ធម្មទេសនាកថា ។

[៣០៨] បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ សម្តែងនូវធម៌ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត សម្តែងធម៌ ដើម្បីត្រាស់ដឹង មិនសម្តែងធម៌ ដើម្បីមិនត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ តថាគត សម្តែងធម៌ ប្រកបដោយហេតុ មិនសម្តែងធម៌ មិនប្រកបដោយហេតុទេ ម្នាលភិក្ខុទាំងឡាយ តថាគត សម្តែងធម៌ ប្រកបដោយបាដិហារ្យ មិនសម្តែងធម៌ មិនប្រកបដោយបាដិហារ្យទេ ម្នាលភិក្ខុទាំងឡាយ តថាគត កាលសម្តែងធម៌ណា ដើម្បីត្រាស់ដឹង មិនសម្តែងធម៌ ដើម្បីមិនត្រាស់ដឹងទេ កាលសម្តែងធម៌ប្រកបដោយហេតុ មិនសម្តែងធម៌ មិនប្រកបដោយហេតុទេ កាលសម្តែងធម៌ ប្រកបដោយបាដិហារ្យ មិនសម្តែងធម៌ មិនប្រកបដោយបាដិហារ្យទេ ឱវាទ អ្នកគួរធ្វើ អនុសាសនី អ្នកគួរធ្វើ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរត្រេកអរ គួរពេញចិត្ត គួររីករាយថា ព្រះសម្មាសម្ពុទ្ធមានព្រះភាគ ព្រះធម៌ គឺព្រះពុទ្ធសម្តែងល្អហើយ ព្រះសង្ឃ ប្រតិបត្តិហើយដោយប្រពៃ កាលដែលព្រះមានព្រះភាគ ទ្រង់សម្តែងវេយ្យាករណៈនេះ លោកធាតុដប់ពាន់ ក៏កម្រើក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់សម្តែងនូវធម៌ ។

ចប់ ធម្មទេសនាកថា ។

១៧១

# ករុណាកថា

[៣០៩] នត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។ អាមន្តា ។ នត្ថិ ពុទ្ធស្ស ភគវតោ មេត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ ពុទ្ធស្ស ភគវតោ ការុ-ណាតិ ។ អាមន្តា ។ នត្ថិ ពុទ្ធស្ស ភគវតោ មុទិតា ។ បេ ។ ឧបេក្ខាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣១០] អត្ថិ ពុទ្ធស្ស ភគវតោ មេត្តាតិ ។ អា-មន្តា ។ អត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ពុទ្ធស្ស ភគវតោ មុទិតា ។ បេ ។ ឧបេក្ខាតិ ។ អាមន្តា ។ អត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣១១] នត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។ អាមន្តា ។ ភគវា អការុណិកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ភគវា ការុណិកោ លោក-ហិតោ លោកានុកម្បកោ លោកត្ថចរោតិ ។ អា-មន្តា ។ ហញ្ចិ ភគវា ការុណិកោ លោកហិតោ លោកានុកម្បកោ លោកត្ថចរោ នោ វត រេ វត្តព្វេ នត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។

# ករុណាកថា

[៣០៩] *ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ មេត្តា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ មុទិតា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ បេ ។ ឧបេក្ខា* (មិនមានទេឬ) *។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៣១០] *មេត្តា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ អើ ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មុទិតា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ បេ ។ ឧបេក្ខា* (មានដែរឬ) *។ អើ ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៣១១] *ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ ព្រះមានព្រះភាគ មិនប្រកបដោយសេចក្តីករុណាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះមានព្រះភាគ ប្រកបដោយសេចក្តីករុណា ជាប្រយោជន៍ដល់សត្វលោក ជាអ្នកអនុគ្រោះដល់សត្វលោក ប្រព្រឹត្តប្រយោជន៍ដល់សត្វលោកដែរឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ប្រកបដោយសេចក្តីករុណា ជាប្រយោជន៍ដល់សត្វលោក ជាអ្នកអនុគ្រោះដល់សត្វលោក ប្រព្រឹត្តប្រយោជន៍ដល់សត្វលោក ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។*

[៣១២] នត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។ អាមន្តា ។ ននុ ភគវា មហាករុណាសមាបត្តឹ សមាបជ្ជីតិ ។ អាមន្តា ។ ហញ្ចិ ភគវា មហាករុណាសមាបត្តឹ សមាបជ្ជិ តេន វត រេ វត្តព្វេ នត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។

[៣១៣] អត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។ អាមន្តា ។ ភគវា សរាគោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ នត្ថិ ពុទ្ធស្ស ភគវតោ ការុណាតិ ។

ករុណាកថា ។

# គន្ធជាតកថា

[៣១៤] ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវោ អតិវិយ អញ្ញេ គន្ធជាតេ អធិគ្គណ្ហាតីតិ ។ អាមន្តា ។ ភគវា គន្ធភោជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ភគវា ឱទនកុម្មាសំ ភុញ្ជតីតិ ។ អាមន្តា ។ ហញ្ចិ ភគវា ឱទនកុម្មាសំ ភុញ្ជតិ តេន វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវោ អតិវិយ អញ្ញេ គន្ធជាតេ អធិគ្គណ្ហាតីតិ ។

[៣១២] *ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ចូលមហាករុណាសមាបត្តិដែរឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ចូលមហាករុណាសមាបត្តិដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។*

[៣១៣] *ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អើ ។ ព្រះមានព្រះភាគ ប្រកបដោយរាគៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ករុណា*[១] *របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។*

ចប់ ករុណាកថា ។

# គន្ធជាតកថា

[៣១៤] *ឧច្ចារៈនិងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃក្រៃពេកឬ ។ អើ ។ ព្រះមានព្រះភាគ សោយគ្រឿងក្រអូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះមានព្រះភាគ សោយបាយនិងនំដែរឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ សោយបាយនិងនំដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ឧច្ចារៈនិងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធ-ជាតដទៃក្រៃពេកទេ ។*

---

១ សំដៅយកករុណាដោយរាគៈ ។

[៣១៥] ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវោ អតិ-វិយ អញ្ញេ គន្ធជាតេ អធិគ្គណ្ហាតីតិ ។ អាមន្តា ។ អត្ថិ កោចិ ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវំ ន្ហាយន្តិ វិលិបន្តិ ឧច្ឆាទេន្តិ បេឡាយ បដិសាមេន្តិ ករណ្ឌាយ និក្ខិបន្តិ អាបណេ បសារេន្តិ តេន ច គន្ធេន គន្ធ-ករណីយំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

គន្ធជាតកថា ។

# ឯកមគ្គកថា

[៣១៦] ឯកេន អរិយមគ្គេន ចត្តារិ សាមញ្ញ-ផលានិ សច្ឆិករោតីតិ ។ អាមន្តា ។ ចតុន្នំ ផស្សានំ ។ បេ ។ ចតស្សន្នំ បញ្ញានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឯកេន អរិយមគ្គេន ចត្តារិ សាមញ្ញផលានិ សច្ឆិករោតីតិ ។ អាមន្តា ។ សោតា-បត្តិមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទា-គាមិមគ្គេន ។ បេ ។ អនាគាមិមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កតមេន មគ្គេនាតិ ។ អរហត្តមគ្គេ-នាតិ ។ អរហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សី-លព្វតបរាមាសំ ជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

*[៣១៥] ឧច្ចារៈនិងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ គ្រប សង្កត់នូវពួកគន្ធជាតដទៃក្រៃពេកឬ ។ អើ ។ ជនពួកខ្លះ ង៉ូត លាប ជុសខាត់ នូវឧច្ចារៈនិងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ ទុកក្នុង ហិប ដាក់ក្នុងទូ តាំងផ្សាយលើពានផ្សារ ធ្វើនូវកិច្ចដែលខ្លួនត្រូវធ្វើ ដោយគ្រឿងក្រអូប ដោយគ្រឿងក្រអូបនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។*

ចប់ គន្ធជាតកថា ។

# ឯកមគ្គកថា

*[៣១៦] បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញផល ៤ ដោយអរិយ-មគ្គ ១ ឬ ។ អើ ។ ការប្រជុំ នៃផស្សៈទាំង ៤ ។ បេ ។ នៃបញ្ញាទាំង ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញ-ផល ៤ ដោយអរិយមគ្គ ១ ឬ ។ អើ ។ ដោយសោតាបត្តិមគ្គឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយសកទាគាមិមគ្គ ។ បេ ។ ដោយ អនាគាមិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយមគ្គ ដូច ម្តេច ។ ដោយអរហត្តមគ្គ ។ បុគ្គលលះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វ-តបរាមាសៈ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

អរហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរា-
មាសំ ជហាតីតិ ។ អាមន្តា ។ ននុ តិណ្ណំ សញ្ញោ-
ជនានំ បហានំ សោតាបត្តិផលំ វុត្តំ ភគវតាតិ ។
អាមន្តា ។ ហញ្ចិ តិណ្ណំ សញ្ញោជនានំ បហានំ
សោតាបត្តិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អ-
រហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ
ជហាតីតិ ។ បេ ។ អរហត្តមគ្គេន ឱឡារិកំ កាមរាគំ
ឱឡារិកំ ព្យាបាទំ ជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
អរហត្តមគ្គេន ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ
ជហាតីតិ ។ អាមន្តា ។ ននុ កាមរាគព្យាបាទានំ
តនុភាវំ សកទាគាមិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។
ហញ្ចិ កាមរាគព្យាបាទានំ តនុភាវំ សកទាគាមិផលំ
វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហត្តមគ្គេន
ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ ជហាតីតិ ។
អរហត្តមគ្គេន អណុសហគតំ កាមរាគំ អណុ-
សហគតំ ព្យាបាទំ ជហាតីតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ អរហត្តមគ្គេន អណុសហគតំ កាមរាគំ
អណុសហគតំ ព្យាបាទំ ជហាតីតិ ។ អាមន្តា ។

បុគ្គល លះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្ត-មគ្គឬ ។ អើ ។ ក្រែងការលះបង់សញ្ញោជនៈ ៣ ព្រះមានព្រះភាគត្រាស់ថា សោតាបត្តិផលឬ ។ អើ ។ ប្រសិនបើ ការលះបង់សញ្ញោជនៈ ៣ ព្រះមានព្រះភាគត្រាស់ថា សោតាបត្តិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល លះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គទេ ។ បេ ។ បុគ្គល លះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យា-បាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលលះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងភាវៈស្រាលស្តើង នៃកាមរាគៈនិងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា សកទាគាមិផលឬ ។ អើ ។ ប្រ-សិនបើ ភាវៈស្រាលស្តើង នៃកាមរាគៈនិងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា សកទាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល លះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរ-ហត្តមគ្គទេ ។ បុគ្គល លះបង់កាមរាគៈប្រកបដោយប្រមាណតិច ព្យា-បាទប្រកបដោយប្រមាណតិច ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល លះបង់កាមរាគៈប្រកបដោយប្រមាណតិច ព្យាបាទប្រកបដោយប្រមាណតិច ដោយអរហត្តមគ្គឬ ។ អើ ។

ននុ កាមរាគព្យាបាទានំ អនវសេសប្បហានំ អនាគាមិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ កាមរាគព្យាបាទានំ អនវសេសប្បហានំ អនាគាមិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហត្តមគ្គេន អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ ជហាតីតិ ។

[៣១៧] ន វត្តព្វំ ឯកេន អរិយមគ្គេន ចត្តារិ សាមញ្ញផលានិ សច្ឆិករោតីតិ ។ អាមន្តា ។ ភគវតា សោតាបត្តិមគ្គោ ភាវិតោតិ ។ អាមន្តា ។ ភគវា សោតាបន្នោតិ ។ នេ ហេវំ វត្តព្វេ ។ បេ ។ ភគវតា សកទាគាមិមគ្គោ ។ បេ ។ អនាគាមិមគ្គោ ភាវិតោតិ ។ អាមន្តា ។ ភគវា អនាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣១៨] ភគវា ឯកេន អរិយមគ្គេន ចត្តារិ សាមញ្ញផលានិ សច្ឆិករោតិ សាវកា ចតូហិ អរិយមគ្គេហិ ចត្តារិ សាមញ្ញផលានិ សច្ឆិករោន្តីតិ ។ អាមន្តា ។ សាវកា ពុទ្ធស្ស ភគវតោ អទិដ្ឋំ ទក្ខន្តិ អនធិគតំ អធិគច្ឆន្តិ អសច្ឆិកតំ សច្ឆិករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ក្រែងការលះបង់ មិនសេសសល់ នូវកាមរាគៈនិងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា អនាគាមិផលឬ ។ អើ ។ ប្រសិនបើ ការលះបង់មិនសេសសល់ នូវកាមរាគៈនិងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា អនាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល លះបង់កាមរាគៈប្រកបដោយប្រមាណតិច ព្យាបាទប្រកបដោយប្រមាណតិច ដោយអរហត្តមគ្គទេ ។

[៣១៧] បុគ្គលមិនគួរនិយាយថា បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ១ ទេឬ ។ អើ ។ ព្រះមានព្រះភាគចម្រើនសោតាបត្តិមគ្គឬ ។ អើ ។ ព្រះមានព្រះភាគ ជាសោតាបន្នបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមានព្រះភាគ ចម្រើនសកទាគាមិមគ្គ ។ បេ ។ ចម្រើនអនាគាមិមគ្គឬ ។ អើ ។ ព្រះមានព្រះភាគ ជាអនាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣១៨] ព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ១ ពួកសាវ័ក ធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ៤ ឬ ។ អើ ។ ពួកសាវ័ក ឃើញធម៌ដែលព្រះមានព្រះភាគមិនឃើញហើយ ត្រាស់ដឹងធម៌ដែលព្រះមានព្រះភាគមិនត្រាស់ដឹងហើយ ធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលព្រះមានព្រះភាគមិនធ្វើឲ្យជាក់ច្បាស់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ឯកមគ្គកថា ។

# ឈានសង្កន្តិកថា

[៣១៩] ឈានា ឈានំ សង្កមតីតិ ។ អាមន្តា ។ បឋមា ឈានា តតិយំ ឈានំ សង្កមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឈានា ឈានំ សង្កមតីតិ ។ អាមន្តា ។ ទុតិយា ឈានា ចតុត្ថំ ឈានំ សង្កមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣២០] បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ យា បឋមស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ ទុតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ ន វត្តព្វំ យា បឋមស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ ទុតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ទុតិយំ ឈានំ អនាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ អបណិទហន្តស្ស ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ទុតិយំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។

# ឈានសង្កន្តិកថា

[៣១៩] បុគ្គល ចេញអំពីឈាន មួយ រំកិលទៅកាន់ឈាន មួយ បានដែរឬ ។ អើ ។ បុគ្គល ចេញអំពីបឋមជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីឈានមួយ រំកិលទៅកាន់ឈានមួយ បានដែរឬ ។ អើ ។ បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈាន បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣២០] បុគ្គល ចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈាន បានដែរឬ ។ អើ ។ ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា ដើម្បីញុំាំងបឋមជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាំងទុតិយជ្ឈានឲ្យកើតឡើង ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈានឬ ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា ដើម្បីញុំាំងបឋមជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាំងទុតិយជ្ឈានឲ្យកើតឡើងឬ ។ អើ ។ ទុតិយជ្ឈាន របស់បុគ្គលកាលមិនរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលមិនតាំងចិត្តទុក កើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងទុតិយជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។

១៧៧

ឈានសង្កន្តិកថា

បណិធហន្តស្ស ឧប្បជ្ជតីតិ ។ អាមន្តា ។ ហញ្ចិ ទុតិយំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ បណិធហន្តស្ស ឧប្បជ្ជតិ នោ វត រេ វត្តព្វេ បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ បឋមំ ឈានំ កាមេ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ អាមន្តា ។ ទុតិយំ ឈានំ កាមេ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមំ ឈានំ សវិតក្កំ សវិចារន្តិ ។ អាមន្តា ។ ទុតិយំ ឈានំ សវិតក្កំ សវិចារន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ តញ្ញេវ បឋមំ ឈានំ តំ ទុតិយំ ឈានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

របស់បុគ្គលកាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើ ទុតិ-យជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចេញអំពីបឋមជ្ឈាន វិកិលទៅកាន់ទុតិយជ្ឈាន បានទេ ។ បុគ្គលចេញអំពីបឋមជ្ឈាន វិកិលទៅកាន់ទុតិយជ្ឈាន បានដែរឬ ។ អើ ។ បឋ-មជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវកាមទាំងឡាយ ថាជាទោស កើតឡើងដែរឬ ។ អើ ។ ទុតិយជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវកាមទាំងឡាយ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈដែរឬ ។ អើ ។ ទុតិយជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីបឋ-មជ្ឈាន វិកិលទៅកាន់ទុតិយជ្ឈាន បានដែរឬ ។ អើ ។ បឋមជ្ឈាននោះឯង គឺទុតិយជ្ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦១] ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ យា ទុតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ តតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ ន វត្តព្វំ យា ទុតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ តតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ តតិយំ ឈានំ អនាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ អបណិធហន្តស្ស ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ តតិយំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ បណិធហន្តស្ស ឧប្បជ្ជតីតិ ។ អាមន្តា ។ ហញ្ចិ តតិយំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ បណិធហន្តស្ស ឧប្បជ្ជតិ នោ វត រេ វត្តព្វេ ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។

[៣២១] បុគ្គល ចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន បានដែរឬ ។ អើ ។ ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងទុតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងតតិយជ្ឈានឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា ដើម្បីញ៉ាំងទុតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញ៉ាំងតតិយជ្ឈានឲ្យកើតឡើងដែរឬ ។ អើ ។ តតិយជ្ឈាន របស់បុគ្គលកាលមិនរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលមិនតាំងចិត្តទុក កើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងតតិយជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើ តតិយជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈានបានទេ ។ បុគ្គលចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន បានដែរឬ ។ អើ ។

ទុតិយំ ឈានំ វិតក្កវិចារេ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ អាមន្តា ។ តតិយំ ឈានំ វិតក្កវិចារេ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទុតិយំ ឈានំ សប្បីតិកន្តិ ។ អាមន្តា ។ តតិយំ ឈានំ សប្បីតិកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ តញ្ញេវ ទុតិយំ ឈានំ តំ តតិយំ ឈានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣២២] តតិយា ឈានា ចតុត្ថំ ឈានំ សង្កមតីតិ ។ អាមន្តា ។ យា តតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ ចតុត្ថស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តតិយា ឈានា ចតុត្ថំ ឈានំ សង្កមតីតិ ។ ន វត្តព្វំ ។ យា តតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ ចតុត្ថស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ចតុត្ថំ ឈានំ អនាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។

ទុតិយជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវវិតក្កៈនិងវិចារៈ ថាជាទោស កើតឡើងឬ ។ អើ ។ តតិយជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវវិតក្កៈនិងវិចារៈ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទុតិយជ្ឈាន ប្រកបដោយបីតិដែរឬ ។ អើ ។ តតិយជ្ឈាន ប្រកបដោយបីតិដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈានបានដែរឬ ។ អើ ។ ទុតិយជ្ឈាននោះឯង គឺតតិយជ្ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣២២] បុគ្គល ចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានដែរឬ ។ អើ ។ ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងចតុត្ថជ្ឈានឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានដែរឬ ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងចតុត្ថជ្ឈានឲ្យកើតឡើងដែរឬ ។ អើ ។ ចតុត្ថជ្ឈាន របស់បុគ្គលកាលមិនរំពឹង កើតឡើង ។ បេ ។

អបណិហិតហន្តស្ស ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ចតុត្ថំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជ-តិ ។ បេ ។ បណិហិតហន្តស្ស ឧប្បជ្ជតីតិ ។ អា-មន្តា ។ ហញ្ចិ ចតុត្ថំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជ-តិ ។ បេ ។ បណិហិតហន្តស្ស ឧប្បជ្ជតិ តេន វត រេ វត្តព្វេ តតិយា ឈានា ចតុត្ថំ ឈានំ សង្កម-តីតិ ។ តតិយា ឈានា ចតុត្ថំ ឈានំ សង្កម-តីតិ ។ អាមន្តា ។ តតិយំ ឈានំ បីតឹ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចតុត្ថំ ឈា-នំ បីតឹ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តតិយំ ឈានំ សុខស-ហាគតន្តិ ។ អាមន្តា ។ ចតុត្ថំ ឈានំ សុខសហាគ-តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តតិយា ឈានា ចតុត្ថំ ឈានំ សង្កមតីតិ ។ អាមន្តា ។ តញ្ញេវ តតិយំ ឈានំ តំ ចតុត្ថំ ឈានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

របស់បុគ្គលកាលមិនតាំងចិត្តទុក កើតឡើងដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ក្រែងចតុត្ថជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើ ចតុត្ថជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាល តាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានទេ ។ បុគ្គល ចេញអំពី តតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈាន បានដែរឬ ។ អើ ។ តតិយជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបីតិ ថាជាទោស កើតឡើងដែរឬ ។ អើ ។ ចតុត្ថជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបីតិ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ តតិយជ្ឈាន ប្រកបដោយសុខឬ ។ អើ ។ ចតុត្ថជ្ឈាន ប្រកបដោយសុខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈាន បានដែរឬ ។ អើ ។ តតិយជ្ឈាននោះឯង គឺចតុត្ថជ្ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១៨១

ឈានន្តរិកកថា

[៣២៣] ន វត្តព្វំ ឈានា ឈានំ សង្កមតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខវេ ភិក្ខុ វិ- វិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ឈានា ឈានំ សង្កមតីតិ ។

ឈានសង្កន្តិកថា ។

# ឈានន្តរិកកថា

[៣២៤] អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ អត្ថិ ផស្សន្តរិកា ។ បេ ។ អត្ថិ បញ្ញន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ឈានន្តរិកាតិ ។ អា- មន្តា ។ ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ តតិ- យស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣២៣] បុគ្គលមិនគួរនិយាយថា បុគ្គល ចេញអំពីឈានមួយ រំកិលទៅកាន់ឈានមួយ បានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ទាំងឡាយ ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ពាក្យដូច្នេះ មានក្នុងព្រះ សូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល ចេញអំពីឈានមួយ រំកិល ទៅកាន់ឈានមួយបាន ។

ចប់ ឈានសង្កន្តិកថា ។

# ឈានន្តរិកកថា

[៣២៤] ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជា ចន្លោះនៃផស្សៈ មានដែរឬ ។ បេ ។ ធម៌ជាចន្លោះនៃបញ្ញា មានដែរ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃ ទុតិយជ្ឈាននិងតតិយជ្ឈានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃតតិយជ្ឈាននិងចតុត្ថជ្ឈានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[៣២៥] ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ នត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ ហញ្ចិ ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ នត្ថិ ឈានន្តរិកា នោ វត រេ វត្តព្វេ អត្ថិ ឈានន្តរិកាតិ ។ តតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ នត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ ហញ្ចិ តតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ នត្ថិ ឈានន្តរិកា នោ វត រេ វត្តព្វេ អត្ថិ ឈានន្តរិកាតិ ។

[៣២៦] បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ តតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣២៥] ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃទុតិយជ្ឈាននិងតតិយជ្ឈានទេឬ ។ អើ ។ ប្រសិនបើ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃទុតិយជ្ឈាននិងតតិយជ្ឈានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ជាចន្លោះនៃឈាន មានទេ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃតតិយជ្ឈាននិងចតុត្ថជ្ឈានទេឬ ។ អើ ។ ប្រសិនបើ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃតតិយជ្ឈាននិងចតុត្ថជ្ឈានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ជាចន្លោះនៃឈាន មានទេ ។

[៣២៦] ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃបឋមជ្ឈាននិងទុតិយជ្ឈានឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃទុតិយជ្ឈាននិងតតិយជ្ឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃបឋមជ្ឈាននិងទុតិយជ្ឈានឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃតតិយជ្ឈាននិងចតុត្ថជ្ឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ឈានន្តរិកកថា

[៣២៧] ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ ឧត្តិ ឈានន្តរិកាតិ ។ អាមន្តា ។ បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស អន្តរេ ឧត្តិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ ឧត្តិ ឈានន្តរិកាតិ ។ អាមន្តា ។ បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស អន្តរេ ឧត្តិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣២៨] អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។ អាមន្តា ។ សវិតក្កោ សវិចារោ សមាធិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។ អាមន្តា ។ អវិតក្កោ អវិចារោ សមាធិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣២៩] សវិតក្កោ សវិចារោ សមាធិ ន ឈានន្តរិកាតិ ។ អាមន្តា ។ អវិតក្កោ វិចារមត្តោ សមាធិ ន ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិតក្កោ អវិចារោ សមាធិ

ឈានន្តរិកកថា

[៣២៧] ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃទុតិយជ្ឈាន និងតតិយជ្ឈានទេឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃបឋមជ្ឈាននិងទុតិយជ្ឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃតតិយជ្ឈាន និងចតុត្ថជ្ឈានទេឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃបឋមជ្ឈាននិងទុតិយជ្ឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣២៨] សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាធម៌ជាចន្លោះនៃឈានឬ ។ អើ ។ សមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ជាធម៌ជាចន្លោះនៃឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាធម៌ជាចន្លោះនៃឈានឬ ។ អើ ។ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ ជាធម៌ជាចន្លោះនៃឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣២៩] សមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ

ន ឈានន្តរិកាតិ ។ អាមន្តា ។ អវិតក្កោ វិចារ-
មត្តោ សមាធិ ន ឈានន្តរិកាតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

[៣៣០] ទ្វិន្នំ ឈានានំ បដុប្បន្នានំ អន្តរេ អវិ-
តក្កោ វិចារមត្តោ សមាធីតិ ។ អាមន្តា ។ ននុ អវិតក្កេ
វិចារមត្តេ សមាធិម្ហិ វត្តមានេ បឋមំ ឈានំ និរុទ្ធំ ទុ-
តិយំ ឈានំ អនុប្បន្នន្តិ ។ អាមន្តា ។ ហញ្ចិ អវិ-
តក្កេ វិចារមត្តេ សមាធិម្ហិ វត្តមានេ បឋមំ ឈានំ
និរុទ្ធំ ទុតិយំ ឈានំ អនុប្បន្នំ នោ វត រេ វត្តព្វេ
ទ្វិន្នំ ឈានានំ បដុប្បន្នានំ អន្តរេ អវិតក្កោ វិចារ-
មត្តោ សមាធិ ឈានន្តរិកាតិ[១] ។

[៣៣១] អវិតក្កោ វិចារមត្តោ សមាធិ ន ឈា-
នន្តរិកាតិ ។ អាមន្តា ។ អវិតក្កោ វិចារមត្តោ ស-
មាធិ បឋមំ ឈានំ ។ បេ ។ ទុតិយំ ឈានំ
។ បេ ។ តតិយំ ឈានំ ។ បេ ។ ចតុត្ថំ ឈានន្តិ ។
ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អវិតក្កោ វិ-
ចារមត្តោ សមាធិ ឈានន្តរិកាតិ ។

---

១ ឱ. អយំ បាឋោ នត្ថិ ។

មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៣០] សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានក្នុងចន្លោះ នៃឈានទាំងពីរ ដែលកើតចំពោះហើយឬ ។ អើ ។ ក្រែងកាលសមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ កំពុងប្រព្រឹត្តទៅ បឋមជ្ឈានរលត់ ទុតិយជ្ឈាន មិនទាន់កើតឡើងទេឬ ។ អើ ។ ប្រសិនបើ កាលសមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ កំពុងប្រព្រឹត្តទៅ បឋមជ្ឈានរលត់ ទុតិយជ្ឈានមិនទាន់កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានក្នុងចន្លោះ នៃឈានទាំងពីរ ដែលកើតចំពោះហើយ ថាជាធម៌ជាចន្លោះនៃឈានទេ ។

[៣៣១] សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាបឋមជ្ឈាន ។ បេ ។ ជាទុតិយជ្ឈាន ។ បេ ។ ជាតតិយជ្ឈាន ។ បេ ។ ជាចតុត្ថជ្ឈានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាធម៌ជាចន្លោះនៃឈាន ។

[៣៣២] អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។ អាមន្តា ។ ននុ តយោ សមាធី វុត្តា ភគវតា សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចារោ សមាធីតិ ។ អាមន្តា ។ ហញ្ចិ តយោ សមាធី វុត្តា ភគវតា សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចារោ សមាធិ នោ វត រេ វត្តព្វេ អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។

ឈានន្តរិកកថា ។

## សមាបន្នោ សទ្ទំ សុណាតីតិកថា

[៣៣៣] សមាបន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ សមាបន្នោ ចក្ខុនា រូបំ បស្សតិ ។ បេ ។ សោតេន ។ បេ ។ ឃានេន ។ បេ ។ ជិវ្ហាយ ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមាបន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ សោតវិញ្ញាណសមង្គី សមាបន្នោតិ ។

[៣៣២] សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាធម៌ជាចន្លោះនៃឈានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ពួកសមាធិ ៣ យ៉ាងគឺ សមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ពួកសមាធិ ៣ យ៉ាងគឺ សមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាធម៌ជាចន្លោះនៃឈានទេ ។

ចប់ ឈានន្តរិកកថា ។

# សមាបន្នោ សទ្ទំ សុណាតីតិកថា

[៣៣៣] បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងដែរឬ ។ អើ ។ បុគ្គលចូលកាន់សមាបត្តិ ឃើញរូប ដោយចក្ខុ ។ បេ ។ ដោយត្រចៀក ។ បេ ។ ដោយច្រមុះ ។ បេ ។ ដោយអណ្តាត ។ បេ ។ ពាល់ត្រូវនូវផោដ្ឋព្វៈ ដោយកាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងដែរឬ ។ អើ ។ បុគ្គលចូលកាន់សមាបត្តិ ព្រមព្រៀងដោយសោតវិញ្ញាណដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ននុ សមាធិ មនោវិញ្ញាណ-សមង្គិស្សាតិ ។ អាមន្តា ។ ហញ្ចិ សមាធិ មនោ-វិញ្ញាណសមង្គិស្ស នោ វត រេ វត្តព្វេ សមាបន្នោ សទ្ទំ សុណាតីតិ ។

[៣៣៤] សមាធិ មនោវិញ្ញាណសមង្គិស្ស សោ-តវិញ្ញាណសមង្គី សទ្ទំ សុណាតីតិ ។ អាមន្តា ។ ហញ្ចិ សមាធិ មនោវិញ្ញាណសមង្គិស្ស សោតវិញ្ញា-ណសមង្គី សទ្ទំ សុណាតិ នោ វត រេ វត្តព្វេ ស-មាបន្នោ សទ្ទំ សុណាតីតិ ។ សមាធិ មនោវិញ្ញា-ណសមង្គិស្ស សោតវិញ្ញាណសមង្គី សទ្ទំ សុណា-តីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៣៥] ន វត្តព្វំ សមាបន្នោ សទ្ទំ សុណា-តីតិ ។ អាមន្តា ។ ននុ បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ បឋ-មស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតា តេន វត រេ វត្តព្វេ សមាបន្នោ សទ្ទំ សុណាតីតិ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងសមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណឬ ។ អើ ។ ប្រសិនបើ សមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងទេ ។

[៣៣៤] សមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោ-វិញ្ញាណ ចុះបុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសំឡេងដែរឬ ។ អើ ។ ប្រសិនបើ សមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ បុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសំឡេងដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងទេ ។ សមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោ-វិញ្ញាណ ចុះបុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសំឡេងដែរឬ ។ អើ ។ ការប្រជុំ នៃផស្សៈទាំងពីរ ។ បេ ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៣៥] បុគ្គលមិនគួរនិយាយថា បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងទេឬ ។ អើ ។ ក្រែងសំឡេង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈានឬ ។ អើ ។ ប្រសិនបើ សំឡេង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសំឡេងដែរ ។

១៨៧

## សមាបន្នោ សទ្ទំ សុណាតីតិកថា

បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតាតិ ។ សមាបន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ ទុតិយស្ស ឈានស្ស វិតក្កោ វិចារោ កណ្ដកោ វុត្តោ ភគវតា អត្ថិ តស្ស វិតក្កវិចា-
រាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមស្ស ឈា-
នស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតាតិ ។ សមា-
បន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ តតិយស្ស ឈានស្ស បីតិ កណ្ដកោ ចតុត្ថស្ស ឈានស្ស អស្សាសបស្សាសោ កណ្ដកោ អាកាសានញ្ចាយ-
តនំ សមាបន្នស្ស រូបសញ្ញា កណ្ដកោ វិញ្ញាណញ្ចា-
យតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញា កណ្ដកោ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញា-
ណញ្ចាយតនសញ្ញា កណ្ដកោ នេវសញ្ញានាសញ្ញា-
យតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញា កណ្ដ-
កោ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេ-
ទនា ច កណ្ដកោ វុត្តា ភគវតា អត្ថិ តស្ស សញ្ញា ច វេទនា ចាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សមាបន្នោ សទ្ទំ សុណាតីតិកថា ។

សមាបន្នោ សទ្ទំ សុណាតីតិកថា

[៣៨៦] អត្ថិ បុថុជ្ជនស្ស ញាណន្តិ ។ អាមន្តា ។ បុថុជ្ជនោ តេន ញាណេន ទុក្ខំ បរិជានាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ញាណកថា ។

# និរយបាលកថា

[៣៨៧] នត្ថិ និរយេសុ និរយបាលាតិ ។ អាមន្តា ។ នត្ថិ និរយេសុ កម្មការណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ និរយេសុ កម្មការណាតិ ។ អាមន្តា ។ អត្ថិ និរយេសុ និរយបាលាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

គប្បីឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ របស់បុថុជ្ជន មិនមានទេ ។

[៣៨៦] ញាណ របស់បុថុជ្ជន មានដែរឬ ។ អើ ។ បុថុជ្ជនកំណត់ដឹងទុក្ខ លះបង់សមុទយៈ ធ្វើឲ្យជាក់ច្បាស់និរោធ ចម្រើនមគ្គដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ញាណកថា ។

# និរយបាលកថា

[៣៨៧] ពួកនិរយបាល ក្នុងឋាននរក[១] មិនមានទេឬ ។ អើ ។ ហេតុនៃកម្ម ក្នុងឋាននរក មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ហេតុនៃកម្ម ក្នុងឋាននរក មានដែរឬ ។ អើ ។ ពួកនិរយបាល ក្នុងឋាននរក មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

---

១ លទ្ធិរបស់មនុស្សខ្មៅយល់ថា កម្មរបស់ខ្លួនឯងបៀតបៀនសត្វ ដែលកើតក្នុងនរកដោយសភាពជានាយនិរយបាល, ឯពួកសត្វដែលឈ្មោះថា នាយនិរយបាលនោះ មិនមានឡើយ, សកវាទីសួរដូច្នេះ អាស្រ័យកាត់សេចក្តីឲ្យដឹងថា និរយបាលប្រាកដជាមានក្នុងឋាននរក (អដ្ឋកថា) ។

[៣៨៨] អត្ថិ មនុស្សេសុ កម្មការណា អត្ថិ ច ការណិកាតិ ។ អាមន្តា ។ អត្ថិ និរយេសុ កម្មការណា អត្ថិ ច ការណិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ និរយេសុ កម្មការណា នត្ថិ ច ការណិកាតិ ។ អាមន្តា ។ អត្ថិ មនុស្សេសុ កម្មការណា នត្ថិ ច ការណិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៨៩] អត្ថិ និរយេសុ និរយបាលាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ន វេស្សភូ នោបិ ច បេត្តិរាជា
សោមោ យមោ វេស្សវណោ ច រាជា
សកានិ កម្មានិ ហនន្តិ តត្ថ
ឥតោ បណុន្នំ បរលោកបត្តន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ នត្ថិ និរយេសុ និរយបាលាតិ ។

[៣៩០] នត្ថិ និរយេសុ និរយបាលាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា តមេនំ ភិក្ខវេ និរយបាលា

[៣៨៨] ហេតុនៃកម្ម ក្នុងឋានមនុស្ស មាន ចុះពួកអ្នកធ្វើកម្ម (ធ្វើទោស) មានដែរឬ ។ អើ ។ ហេតុនៃកម្ម ក្នុងឋាននរក មាន ចុះពួកនិរយបាល មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ហេតុនៃកម្ម ក្នុងឋាននរក មាន ចុះពួកនិរយបាល មិនមានទេឬ ។ អើ ។ ហេតុនៃកម្ម ក្នុងឋានមនុស្ស មាន ចុះពួកនិរយបាល មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៨៩] ពួកនិរយបាល ក្នុងស្ថាននរក មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ស្តេចវេស្សភូ មិនបៀតបៀន ស្តេចប្រេត ស្តេចសោមៈ
ស្តេចយមៈ ស្តេចវេស្សវ័ណ ក៏មិនបៀតបៀនដែរ មាន
តែកម្មរបស់ខ្លួន រមែងបៀតបៀនសត្វដែលច្យុតចាកលោក
នេះ ទៅកាន់បរលោក ក្នុងឋាននរកនោះ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយបាល ក្នុងឋាននរក មិនមានទេ ។

[៣៩០] ពួកនិរយបាល ក្នុងឋាននរក មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល

២២១

និរយបាលកថា

បញ្ចវិធំ ពន្ធនំ នាម ការណំ ការេន្តិ តត្តំ អយោខិលំ ហត្ថេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ ហត្ថេ គមេន្តិ តត្តំ អយោខិលំ បាទេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ បាទេ គមេន្តិ តត្តំ អយោខិលំ មជ្ឈេឧរស្មឹ គមេន្តិ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តី ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ និរយេសុ និរយបាលាតិ ។

[៣៩១] នត្ថិ និរយេសុ និរយបាលាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា តមេនំ ភិក្ខវេ និរយបាលា សំវេសិត្វា កុឋារីហិ តច្ឆន្តិ ។ បេ ។ តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ ឋបេត្វា វាសីហិ តច្ឆន្តិ ។ បេ ។ តមេនំ ភិក្ខវេ និរយបាលា រថេ យោជេត្វា អាទិត្តាយ បឋវិយា សម្បជ្ជលិតាយ សជោតិភូតាយ សារេន្តិបិ បច្ចាសារេន្តិបិ ។ បេ ។

ឲ្យធ្វើនូវហេតុ ឈ្មោះថាចំណង ៥ យ៉ាង ចំពោះបុគ្គលនោះ គឺយកដែក-គោលក្តៅ មកបោះត្រង់ដៃ ។ យកដែកគោលក្តៅ មកបោះត្រង់ដៃទីពីរ ។ យកដែកគោលក្តៅ មកបោះត្រង់ជើង ។ យកដែកគោលក្តៅ មកបោះត្រង់ជើងទីពីរ ។ យកដែកគោលក្តៅ មកបោះត្រង់កណ្តាលដើមទ្រូង ។ បុគ្គលនោះ រងវេទនា ជាទុក្ខ ក្លៀវក្លា រឹងរូស ក្នុងនរកនោះ បាបកម្មនោះ មិនទាន់អស់ទៅ ដរាបណា ក៏មិនធ្វើមរណកាលដរាបនោះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយបាល ក្នុងឋាននរក មាន ។

[៣៩១] ពួកនិរយបាល ក្នុងឋាននរក មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកនិរយ-បាលផ្តេកបុគ្គលនោះ ហើយចាំងដោយដឹងទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ដាក់បុគ្គលនោះ ឲ្យមានជើងឡើងលើមានក្បាលចុះក្រោម ហើយច្រាសដោយកាំបិតទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមបុគ្គលនោះក្នុងរថ បរទៅផងបរត្រឡប់មកវិញផង លើផែនដីដែលភ្លើងឆេះរន្ទាលច្រាលឆ្អៅ ។ បេ ។

តមេនំ ភិក្ខវេ និរយបាលា មហន្តំ អង្គារបព្ពតំ អាទិត្តំ សម្បជ្ជលិតំ សញ្ជោតិភូតំ អារោបេន្តិបិ ឱរោបេន្តិបិ ។ បេ ។ តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហ-កុម្ភិយា បក្ខិបន្តិ អាទិត្តាយ សម្បជ្ជលិតាយ ស-ញ្ជោតិភូតាយ សោ តត្ថ ផេណុទ្ទេហកំ បច្ចតិ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆតិ សកិម្បិ អធោ គច្ឆតិ សកិម្បិ តិរិយំ គច្ឆតិ សោ តត្ថ ទុក្ខា ។ បេ ។ តមេនំ ភិក្ខវេ និរយបាលា មហានិរយេ បក្ខិបន្តិ សោ ខោ បន ភិក្ខវេ មហានិរយោ

ចតុក្កណ្ណោ ចតុទ្វារោ វិភត្តោ ភាគសោ មិតោ
អយោបាការបរិយន្តោ អយសា បដិកុជ្ជិតោ
តស្ស អយោមយា ភូមិ ជលិតា តេជសា យុតា
សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ សព្វទាតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ និរយេសុ និរយបាលាតិ ។

និរយបាលកថា ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ញ៉ាំងបុគ្គលនោះ ឲ្យឡើងផង ឲ្យចុះផង កាន់ភ្នំរងើកភ្លើងធំ ដែលភ្លើងឆេះរន្ទាលច្រាលឆ្អៅ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុគ្គលនោះ ឲ្យមានជើងឡើងលើ ក្បាលចុះក្រោម ហើយបោះទៅក្នុងខ្ទះ ដ៏ពេញដោយទឹកទង់ដែងក្តៅ ដែលភ្លើងឆេះរន្ទាលច្រាលឆ្អៅ បុគ្គលនោះ រមែងឆេះ នៅមានពពុះព្រួច ៗ ក្នុងនរកនោះ បុគ្គលនោះ កាលឆេះ នៅមានពពុះព្រួច ៗ ក្នុងនរកនោះ ទៅខាងលើម្តង ទៅខាងក្រោមម្តង ទៅទទឹងម្តង បុគ្គលនោះ ដល់នូវសេចក្តីទុក្ខ ក្នុងនរកនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល បោះបុគ្គលនោះ ទៅក្នុងមហានរក ម្នាលភិក្ខុទាំងឡាយ មហានរកនោះឯង

> មានជ្រុង ៤ មានទ្វារ ៤ ដែលធម្មតាចែក រាប់ដោយចំណែក
> មានកំពែងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ភូមិរបស់
> មហានរក នោះជាវិការនៃដែក ដែលរុងរឿង ប្រកបដោយ
> កម្តៅ ផ្សាយទៅអស់ទីមួយរយយោជន៍ដោយជុំវិញ ហើយ
> ឋិតនៅសព្វកាល

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយបាល ក្នុងឋាននរក មាន ។

ចប់ និរយបាលកថា ។

# តិរច្ឆានកថា

[៣៩២] អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ អត្ថិ តិរច្ឆានគតេសុ ទេវាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ ទេវលោកោ តិរច្ឆានយោនីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ អត្ថិ តត្ថ កីដា បដង្គា មកសា មក្ខិកា អហី វិច្ឆិកា សតបទី គណ្ឌុប្បាទាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៩៣] នត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ ននុ អត្ថិ តត្ថ ឯរាវណោ នាម ហត្ថិនាគោ សហស្សស្សយុត្តំ ទិព្វំ យានន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ តត្ថ ឯរាវណោ នាម ហត្ថិនាគោ សហស្សស្សយុត្តំ ទិព្វំ យានំ តេន វត រេ វត្តព្វេ អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។

# តិរច្ឆានកថា

[៣៩២] ពួកសត្វតិរច្ឆាន[១]ក្នុងទេវលោក មានដែរឬ ។ អើ ។ ពួកទេវតា ក្នុងឋានសត្វតិរច្ឆាន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វតិរច្ឆាន ក្នុងទេវលោក មានដែរឬ ។ អើ ។ ទេវលោក មានកំណើតជាតិរច្ឆានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វតិរច្ឆាន ក្នុងទេវលោក មានដែរឬ ។ អើ ។ ពួកកន្ធាត កន្ធុំរុយ របោម រុយ ពស់ ខ្ជួយ ក្អែប ជន្លេន ក្នុងទេវលោកនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៩៣] ពួកសត្វតិរច្ឆាន ក្នុងទេវលោក មិនមានទេឬ ។ អើ ។ ក្រែងដំរីដ៏ប្រសើរ ឈ្មោះឯរាវ័ណ យានជាទិព្វ ដែលទឹមដោយសេះមួយពាន់ ក្នុងទេវលោកនោះ មានឬ ។ អើ ។ ប្រសិនបើ ដំរីដ៏ប្រសើរ ឈ្មោះឯរាវ័ណ យានជាទិព្វ ដែលទឹមដោយសេះមួយពាន់ ក្នុងទេវលោកនោះ មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកសត្វតិរច្ឆាន ក្នុងទេវលោក មាន ។

---

១ តាមពិតក្នុងឋានទេវលោក មានតែពួកទេវបុត្រឈ្មោះឯរាវណៈជាដើម សម្តែងឫទ្ធិជាភេទដំរី សេះ ពួកសត្វតិរច្ឆានមែន ៗ នោះមិនមានឡើយ ប៉ុន្តែលទ្ធិរបស់អ្នកល្ងង់ខ្លៅអាស្រ័យដោយបានឃើញពួកទេវបុត្ត មានភេទជាសត្វតិរច្ឆាន ទើបចូលចិត្តថា តិរច្ឆានក្នុងឋានទេវ-លោកក៏មាន (អដ្ឋកថា) ។

[៣៩៤] អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អា-
មន្តា ។ អត្ថិ តត្ថ ហត្ថិពន្ធា អស្សពន្ធា យាវសិកា
ការណិកា ភត្តការកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
តេន ហិ នត្ថិ ទេវេសុ តិរច្ឆានគតាតិ ។

តិរច្ឆានកថា ។

# មគ្គកថា

[៣៩៥] បញ្ចង្គិកោ មគ្គោតិ ។ អាមន្តា ។
ននុ អដ្ឋង្គិកោ មគ្គោ វុត្តោ ភគវតា ។ សេយ្យ-
ថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធីតិ ។ អា-
មន្តា ។ ហញ្ចិ អដ្ឋង្គិកោ មគ្គោ វុត្តោ ភគវតា ។
សេយ្យថីទំ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ
នោ វត បេ វត្តព្វេ បញ្ចង្គិកោ មគ្គោតិ ។ បញ្ចង្គិ-
កោ មគ្គោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

[៣៩៤] ពួកសត្វតិរច្ឆាន ក្នុងទេវលោក មានដែរឬ ។ អើ ។ ហ្មដំរី ហ្មសេះ ជនអ្នកឲ្យស្រូវដំណើប ជនអ្នកធ្វើកម្ម ជនអ្នកធ្វើភត្ត ក្នុងទេវលោកនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ពួកសត្វតិរច្ឆាន ក្នុងទេវលោក មិនមានទេ ។

ចប់ តិរច្ឆានកថា ។

# មគ្គកថា

[៣៩៥] មគ្គ ប្រកបដោយអង្គ ៥ ឬ ។ អើ ។ ក្រែងមគ្គ ប្រកបដោយអង្គ ៨ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ។ មគ្គ ប្រកបដោយអង្គ ៨ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ឬ ។ អើ ។ ប្រសិនបើ មគ្គ ប្រកបដោយអង្គ ៨ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ។ មគ្គ ប្រកបដោយអង្គ ៨ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គ ប្រកបដោយអង្គ ៥ ទេ ។ មគ្គ ប្រកបដោយអង្គ ៥ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ ទិបទានញ្ច ចក្ខុមាតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អដ្ឋង្គិកោ មគ្គោតិ ។

[៣៩៦] សម្មាវាចា មគ្គង្គំ សា ច ន មគ្គោតិ ។ អាមន្តា ។ សម្មាទិដ្ឋិ មគ្គង្គំ សា ច ន មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាវាចា មគ្គង្គំ សា ច ន មគ្គោតិ ។ អាមន្តា ។ សម្មាសង្កប្បោ ។ បេ ។ សម្មាវាយាមោ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ មគ្គង្គំ សោ ច ន មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គង្គំ សោ ច ន មគ្គោតិ ។ អាមន្តា ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ មគ្គង្គំ សោ ច ន មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

*អដ្ឋង្គិកមគ្គ ប្រសើរជាងមគ្គទាំងឡាយ បទគឺអរិយសច្ច ៤*
*ប្រសើរជាងសច្ចៈទាំងឡាយ ធម៌មានរាគៈទៅប្រាសហើយ*
*ប្រសើរជាងធម៌ទាំងឡាយ ព្រះមានព្រះភាគព្រះអង្គមានចក្ខុ*
*ប្រសើរជាងសត្វជើងពីរទាំងឡាយ*

*ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គ ឈ្មោះថា ប្រកបដោយអង្គ ៨ ។*

[៣៩៦] *សម្មាវាចា ជាអង្គនៃមគ្គ សម្មាវាចានោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាទិដ្ឋិ ជាអង្គនៃមគ្គ សម្មាទិដ្ឋិនោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាវាចាជាអង្គនៃមគ្គ សម្មាវាចានោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាសង្កប្បៈ ។ បេ ។ សម្មាវាយាមៈ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ ជាអង្គនៃមគ្គ សម្មាសមាធិនោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាអង្គនៃមគ្គ សម្មាអាជីវៈនោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ ជាអង្គនៃមគ្គ សម្មាសមាធិនោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៣៩៧] សម្មាទិដ្ឋិ មគ្គង្គំ សា ច មគ្គោតិ ។ អាមន្តា ។ សម្មាវាចា មគ្គង្គំ សា ច មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាទិដ្ឋិ មគ្គង្គំ សា ច មគ្គោតិ ។ អាមន្តា ។ សម្មាកម្មន្តោ ។ បេ ។ សម្មា-អាជីវោ មគ្គង្គំ សោ ច មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាសង្កប្បោ ។ បេ ។ សម្មាវាយា-មោ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ មគ្គង្គំ សោ ច មគ្គោតិ ។ អាមន្តា ។ សម្មាវាចា ។ បេ ។ សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គង្គំ សោ ច មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៩៨] អរិយោ អដ្ឋង្គិកោ មគ្គោតិ ។ អា-មន្តា ។ ននុ វុត្តំ ភគវតា បុព្វេវ ខោ បនស្ស កាយកម្មំ វចីកម្មំ អាជីវោ សុបរិសុទ្ធោ ហោតិ ឯវមស្សាយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវនាបារិ-បូរឹ គច្ឆតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បញ្ចង្គិកោ មគ្គោតិ ។

[៣៩៧] សម្មាទិដ្ឋិ ជាអង្គនៃមគ្គ សម្មាទិដ្ឋិនោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាវាចា ជាអង្គនៃមគ្គ សម្មាវាចានោះឯង ជាតួមគ្គឬ ។ អ្នក អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាទិដ្ឋិ ជាអង្គនៃមគ្គ សម្មា-ទិដ្ឋិនោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាអង្គនៃមគ្គ សម្មាអាជីវៈនោះឯង ជាតួមគ្គឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ សម្មាសង្កប្បៈ ។ បេ ។ សម្មាវាយាមៈ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ ជាអង្គនៃមគ្គ សម្មាសមាធិនោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាវាចា ។ បេ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាអង្គនៃមគ្គ សម្មាអាជីវៈនោះឯង ជាតួមគ្គឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៩៨] អរិយមគ្គ ប្រកបដោយអង្គ ៨ ឬ ។ អើ ។ ក្រែងព្រះមាន ព្រះភាគ ទ្រង់ត្រាស់ថា ឯកាយកម្ម វចីកម្ម អាជីវៈ របស់បុគ្គលនោះ ជាធម៌ដ៏បរិសុទ្ធស្អាត មានក្នុងកាលមុនពិត អរិយមគ្គ ប្រកបដោយអង្គ ៨ នេះ របស់បុគ្គលនោះ ដល់នូវកិរិយាពេញដោយភាវនា យ៉ាងនេះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គ ឈ្មោះថា ប្រកបដោយអង្គ ៥ ។

២២៧

## មគ្គកថា

[៣៩៩] បញ្ចង្គិកោ មគ្គោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា យស្មឹ ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ន ឧបលព្ភតិ សមណោបិ តត្ថ ន ឧបលព្ភតិ ទុតិយោបិ តត្ថ សមណោ ន ឧបលព្ភតិ តតិយោបិ តត្ថ សមណោ ន ឧបលព្ភ-តិ ចតុត្ថោបិ តត្ថ សមណោ ន ឧបលព្ភតិ យស្មិ-ញ្ច ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ឧបលព្ភតិ សមណោបិ តត្ថ ឧបលព្ភតិ ទុតិ-យោបិ ។ បេ ។ តតិយោបិ ។ បេ ។ ចតុត្ថោបិ តត្ថ សមណោ ឧបលព្ភតិ ឥមស្មឹ ខោ សុភទ្ទ ធម្ម-វិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ឧបលព្ភតិ ឥធេវ សុភទ្ទ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ សុញ្ញា បរប្បវាទា សមណេភិ អញ្ញេហីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អដ្ឋង្គិកោ មគ្គោតិ ។

មគ្គកថា

[៣៩៩] មគ្គ ប្រកបដោយអង្គ ៥ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មិនមានក្នុងធម្មវិន័យណា សមណៈទី ១ មិនមានក្នុងធម្មវិន័យនោះ សមណៈទី ២ មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៣ មិនមានក្នុងធម្មវិន័យនោះ សមណៈទី ៤ ក៏មិនមានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ លុះតែអរិយមគ្គ ប្រកបដោយអង្គ ៨ មានក្នុងធម្មវិន័យណា សមណៈទី ១ មានក្នុងធម្មវិន័យនោះ សមណៈ ទី ២ ។ បេ ។ សមណៈទី ៣ ។ បេ ។ សមណៈទី ៤ ក៏មានក្នុងធម្មវិន័យនោះដែរ ម្នាលសុភទ្ទ អរិយមគ្គប្រកបដោយអង្គ ៨ មានតែក្នុងធម្មវិន័យនេះឯង ម្នាលសុភទ្ទ សមណៈទី ១ ក៏មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ក៏មានតែក្នុងសាសនានេះ បរប្បវាទ (ពាក្យតិះដៀល) អំពីពួកសមណៈដទៃក៏សូន្យទៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គ ឈ្មោះថាប្រកបដោយអង្គ ៨ ។

ចប់ មគ្គកថា ។

# ញាណកថា

[៤០០] ចូទ្ទសវត្ថុកំ ញាណំ លោកុត្តរន្តិ ។ អាមន្តា ។ ចូទ្ទស លោកុត្តរញ្ញាណានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចូទ្ទស លោកុត្តរញ្ញាណានីតិ ។ អាមន្តា ។ ចូទ្ទស សោតាបត្តិមគ្គាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចូទ្ទស សោតាបត្តិមគ្គាតិ ។ អាមន្តា ។ ចូទ្ទស សោតាបត្តិផលានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចូទ្ទស សកទាគាមិមគ្គា ។ បេ ។ អនាគាមិមគ្គា ។ បេ ។ អរហត្តមគ្គាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចូទ្ទស អរហត្តមគ្គាតិ ។ អាមន្តា ។ ចូទ្ទស អរហត្តផលានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០១] ន វត្តព្វំ ចូទ្ទសវត្ថុកំ ញាណំ លោកុត្តរន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ ។ បេ ។ បរិញ្ញាតន្តិ មេ ភិក្ខវេ ។ បេ ។

# ញាណកថា

[៤០០] ញាណ មានវត្ថុ ១២[១] ជាលោកុត្តរៈឬ ។ អើ ។ លោកុត្តរញ្ញាណ មាន ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ លោកុត្តរញ្ញាណមាន ១២ ឬ ។ អើ ។ សោតាបត្តិមគ្គ មាន ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សោតាបត្តិមគ្គ មាន ១២ ឬ ។ អើ ។ សោតាបត្តិផល មាន ១២ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សកទាគាមិមគ្គ ។ បេ ។ អនាគាមិមគ្គ ។ បេ ។ អរហត្តមគ្គ មាន ១២ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរហត្តមគ្គ មាន ១២ ឬ ។ អើ ។ អរហត្តផល មាន ១២ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០១] បុគ្គលមិនគួរនិយាយថា ញាណ មានវត្ថុ ១២ ជាលោកុត្តរៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮក្នុងកាលមុនថា នេះទុក្ខឈ្មោះថាអរិយសច្ចដូច្នេះ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា ទុក្ខឈ្មោះថាអរិយសច្ចនោះឯង បុគ្គលគួរកំណត់ដឹង ម្នាលភិក្ខុទាំងឡាយ ។ បេ ។

១ សំដៅយកញាណមានអាការៈ ១២ ក្នុងកាលសម្ដែងធម្មចក្រត្រង់សច្ចៈទាំង ៤ ក្នុងសច្ចៈមួយមានញាណបី ។ គឺសច្ចញ្ញាណ ១ កិច្ចញ្ញាណ ១ កតញ្ញាណ ១ រួមជាញាណ ១២ ។

ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ ។ បេ ។ បហីនន្តិ មេ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកា-តព្វន្តិ មេ ភិក្ខវេ ។ បេ ។ សច្ឆិកាតន្តិ មេ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយ-សច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិ-រោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ ។ បេ ។ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អន-នុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។

ដល់តថាគត ថា ទុក្ខ ឈ្មោះថាអរិយសច្ចនោះ តថាគត បានកំណត់ដឹងហើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា តណ្ហា នាំឲ្យកើតទុក្ខនេះ ឈ្មោះថាអរិយសច្ច ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា តណ្ហា នាំឲ្យកើតទុក្ខ ឈ្មោះថាអរិយ-សច្ចនោះឯង បុគ្គលគួរលះបោល ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា តណ្ហា នាំឲ្យកើតទុក្ខ ឈ្មោះថាអរិយសច្ចនោះ តថាគតបានលះបោលហើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា ទីរលត់ទុក្ខនេះ ឈ្មោះថាអរិយសច្ច ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា ទីរលត់ទុក្ខ ឈ្មោះថាអរិយសច្ចនោះឯង បុគ្គលគួរធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា ទីរលត់ទុក្ខ ឈ្មោះថាអរិយសច្ចនោះ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខនេះ ឈ្មោះថាអរិយ-សច្ច ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា សេចក្តីប្រតិ-បត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថាអរិយសច្ចនោះឯង បុគ្គលគួរចម្រើន ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ។ បេ ។

អាលោកោ ឧទបាទីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ទ្វាទសវត្ថុកំ ញាណំ លោកុត្តរន្តិ ។

ញាណកថា ។

វីសតិមោ វគ្គោ ។

## តស្ស ឧទ្ទានំ

មាតុឃាតកោ អានន្តរិកោ
បិតុឃាតកោ អានន្តរិកោ
អរហន្តឃាតកោ អានន្តរិកោ
រុហិរុប្បាទកោ អានន្តរិកោ
សង្ឃភេទកោ អានន្តរិកោ
នត្ថិ បុថុជ្ជនស្ស ញាណំ
នត្ថិ និរយេសុ និរយបាលា
អត្ថិ ទេវេសុ តិរច្ឆានគតា
បញ្ចង្គិកោ មគ្គោ ទ្វាទសវត្ថុកំ
ញាណំ លោកុត្តរន្តិ ។

ចតុត្ថោ បណ្ណាសកោ ។

និក្ខេហោ បុញ្ញសំចយោ[១] អដ្ឋាសិ អតីតេន ច មាតុឃាតកោតិ ។

១ ម. បុញ្ញុបចយោ ។

*ពន្ទឹកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនដែលបានឮក្នុងកាលមុនថា សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថាអរិយសច្ចនោះ តថាគតបានចម្រើនហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។ ព្រោះហេតុនោះ ញាណ មានវត្ថុ ១២ ជាលោកុត្តរៈ ។*

ចប់ ញាណកថា ។

ចប់ វីសតិមវគ្គ ។

# ឧទ្ទាននៃវីសតិមវគ្គនោះ គឺ

*និយាយ អំពីមាតុឃាតក៍ ដល់អនន្តរិយកម្ម បិតុឃាតក៍ ដល់អនន្តរិយកម្ម អរហន្តឃាតក៍ ដល់អនន្តរិយកម្ម រុហិរុប្បាទក៍ ដល់អនន្តរិយកម្ម សង្ឃភេទក៍ ដល់អនន្តរិយកម្ម ១ ញាណរបស់បុថុជ្ជន មិនមាន ១ ពួកនិរយបាល ក្នុងឋាននរក មិនមាន ១ ពួកសត្វតិរច្ឆាន ក្នុងទេវលោកមាន ១ មគ្គប្រកបដោយអង្គប្រាំ ១ ញាណ មានវត្ថុ ១២ ជាលោកុត្តរៈ ១ ។*

ចប់ ចតុត្ថបណ្ណាសកៈ ។

*(ក្នុងបណ្ណាសកៈនេះ) និយាយអំពីការសង្កត់សង្កិនជាដើម ១ ការសន្សំបុណ្យជាដើម ១ ព្រះមានព្រះភាគបិតនៅក្នុងមនុស្សលោកជាដើម ១ ការលះកិលេសជាអតីតជាដើម ១ មាតុឃាតក៍ ដល់អនន្តរិយកម្មជាដើម ១ ។*

# សាសនកថា

[៤០២] សាសនំ នវំ កាតព្វំ ។ អាមន្តា ។ សតិប្បដ្ឋានា នវំ កតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សាសនំ នវំ កាតព្វំ ។ អាមន្តា ។ សម្មប្បធានា ។ បេ ។ ឥទ្ធិបាទា ។ បេ ។ ឥន្ទ្រិយា ។ បេ ។ ពលា ។ បេ ។ ពោជ្ឈង្គា នវំ កតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បុព្វេ អកុសលំ បច្ឆា កុសលំ កាតព្វំ ។ ន ហេវំ វត្តព្វេ ។ បេ ។ បុព្វេ សាសវំ ។ បេ ។ សញ្ញោជនិយំ គន្ថនិយំ ឱឃនិយំ យោគនិយំ នីវរណិយំ បរាមដ្ឋំ ឧបាទានិយំ ។ បេ ។ សង្កិលេសិកំ បច្ឆា អសង្កិលេសិកំ កាតព្វំ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០៣] អត្ថិ កោចិ តថាគតស្ស សាសនំ នវំ ករោតីតិ ។ អាមន្តា ។ អត្ថិ កោចិ សតិប្បដ្ឋានេ នវំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កោចិ សម្មប្បធានេ ។ បេ ។ ឥទ្ធិបាទេ ។ បេ ។ ឥន្ទ្រិយេ ។ បេ ។ ពលេ ។ បេ ។ ពោជ្ឈង្គេ នវំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# សាសនកថា

[៤០២] សាសនា គេធ្វើជាថ្មី[១]បានដែរឬ ។ អើ ។ សតិប្បដ្ឋាន គេធ្វើជាថ្មីបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សាសនា គេធ្វើជាថ្មីបានដែរឬ ។ អើ ។ សម្មប្បធាន ។ បេ ។ ឥទ្ធិបាទ ។ បេ ។ ឥន្ទ្រិយ ។ បេ ។ ពលៈ ។ បេ ។ ពោជ្ឈង្គៈ គេធ្វើជាថ្មីបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អកុសល គេធ្វើក្នុងកាលមុន កុសល គេធ្វើក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អំពើប្រកបដោយអាសវៈ ។ បេ ។ គួរដល់សញ្ញោជនៈ គួរដល់គន្ថៈ គួរដល់ឱឃៈ គួរដល់យោគៈ គួរដល់នីវរណៈ ដែលបរាមាសៈគប្បីស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន ។ បេ ។ ប្រកបដោយកិលេស គេធ្វើក្នុងកាលមុន អំពើមិនប្រកបដោយកិលេស គេធ្វើក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៣] បុគ្គលណាមួយ ធ្វើសាសនា របស់ព្រះតថាគត ជាថ្មី មានដែរឬ ។ អើ ។ បុគ្គលណាមួយ ធ្វើសតិប្បដ្ឋានជាថ្មី មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលណាមួយ ធ្វើសម្មប្បធាន ។ បេ ។ ឥទ្ធិបាទ ។ បេ ។ ឥន្ទ្រិយ ។ បេ ។ ពលៈ ។ បេ ។ ពោជ្ឈង្គៈជាថ្មី មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

---

១ សំដៅយកការសង្គាយនាទាំង ៣ លើកខាងដើម គឺសង្គាយនាទី ១ ទី ២ ទី ៣ ។

អត្ថិ កោចិ បុព្វេ អកុសលំ បច្ឆា កុសលំ ករោ-តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កោចិ បុព្វេ សាសវំ ។ បេ ។ សង្កិលេសិកំ បច្ឆា អសង្កិលេសិកំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០៤] លព្ភា តថាគតស្ស សាសនំ បុន នវំ កាតុន្តិ ។ អាមន្តា ។ លព្ភា សតិប្បដ្ឋានា បុន នវំ កាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា សម្មប្បធានា ឥទ្ធិបាទា ឥន្ទ្រិយា ពលា ។ បេ ។ ពោជ្ឈង្គា បុន នវំ កាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា បុព្វេ អកុសលំ បច្ឆា កុសលំ កាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា បុព្វេ សាសវំ ។ បេ ។ សង្កិលេសិកំ បច្ឆា អសង្កិលេសិកំ កាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បុគ្គលណាមួយ ធ្វើអកុសល ក្នុងកាលមុន ធ្វើកុសល ក្នុងកាលជាខាងក្រោយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលណាមួយ ធ្វើអំពើប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយកិលេស ក្នុងកាលមុន ធ្វើអំពើមិនប្រកបដោយកិលេស ក្នុងកាលជាខាងក្រោយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៤] បុគ្គល បានធ្វើសាសនា របស់តថាគត ជាថ្មីវិញដែរឬ ។ អើ ។ បុគ្គល បានធ្វើសតិប្បដ្ឋាន ជាថ្មីវិញដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល បានធ្វើសម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ។ បេ ។ ពោជ្ឈង្គៈ ជាថ្មីវិញដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលបានធ្វើអកុសល ក្នុងកាលមុន ធ្វើកុសល ក្នុងកាលជាខាងក្រោយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលបានធ្វើអំពើប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយកិលេស ក្នុងកាលមុន ធ្វើអំពើមិនប្រកបដោយកិលេស ក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ សាសនកថា ។

# អវិវិត្តកថា

[៤០៥] បុថុជ្ជនោ តេធាតុកេហិ ធម្មេហិ អវិវិត្តោ-ති ។ អាមន្តា ។ បុថុជ្ជនោ តេធាតុកេហិ ផស្សេហិ ។ បេ ។ តេធាតុកាហិ វេទនាហិ សញ្ញាហិ ចេតនា-ហិ ចិត្តេហិ សទ្ធាហិ វីរិយេហិ សតីហិ សមាធីហិ តេធាតុកាហិ បញ្ញាហិ អវិវិត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បុថុជ្ជនោ តេធាតុកេហិ ធម្មេហិ អវិវិត្តោតិ ។ អាមន្តា ។ យស្មឹ ខណេ បុថុជ្ជនោ ចីវរំ ទេតិ តស្មឹ ខណេ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ យស្មឹ ខ-ណេ បុថុជ្ជនោ បិណ្ឌបាតំ ទេតិ ។ បេ ។ សេនា-សនំ ទេតិ ។ បេ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេតិ តស្មឹ ខណេ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហ-រតិ នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរ-តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០៦] ន វត្តព្វំ បុថុជ្ជនោ តេធាតុកេហិ ធម្មេហិ អវិវិត្តោតិ ។ អាមន្តា ។ បុថុជ្ជនស្ស រូបធាតុអរូបធា-តូបកំ កម្មំ បរិញ្ញាតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អវិវិត្តកថា

[៤០៥] បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ទេឬ ។ អើ ។ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកផស្សៈ ប្រកបដោយធាតុ ៣ ។ បេ ។ ចាកវេទនា សញ្ញា ចេតនា ចិត្ត សទ្ធា វិរិយៈ សតិ សមាធិ ប្រកបដោយធាតុ ៣ ចាកបញ្ញា ប្រកបដោយធាតុ ៣ ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ទេឬ ។ អើ ។ ក្នុងខណៈណា បុថុជ្ជន ឲ្យចីវរ ក្នុងខណៈនោះ ក៏បានដល់នូវបឋមជ្ឈាន ។ បេ ។ បានដល់នូវអាកាសានញ្ចាយតនៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្នុងខណៈណា បុថុជ្ជន ឲ្យបិណ្ឌបាត ។ បេ ។ ឲ្យទីសេនាសនៈ ។ បេ ។ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងខណៈនោះ ក៏បានដល់នូវចតុត្ថជ្ឈាន បានដល់នូវនេវសញ្ញានាសញ្ញាយតនៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៦] បុគ្គលមិនគួរនិយាយថា បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ទេឬ ។ អើ ។ កម្ម គួរដល់នូវរូបធាតុនិងអរូបធាតុ បុថុជ្ជន កំណាត់ដឹងហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

តេន ហិ បុថុជ្ជនោ តេធាតុកេហិ ធម្មេហិ អវីតរាគោតិ ។

អវីវិត្តកថា ។

# សញ្ញោជនកថា

[៤០៧] អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។ អាមន្តា ។ អត្ថិ កិញ្ចិ សក្កាយទិដ្ឋឹ អប្បហាយ ។ បេ ។ វិចិកិច្ឆំ អប្បហាយ ។ បេ ។ សីលព្វតបរាមាសំ អប្បហាយ រាគំ អប្បហាយ ទោសំ អប្បហាយ មោហំ អប្បហាយ ។ បេ ។ អនោត្តប្បំ អប្បហាយ អរហត្តប្បត្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០៨] អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។ អាមន្តា ។ អរហា សរាគោ សទោសោ សមោហោ សមានោ សមក្ខោ សបឡាសោ សឧបាយាសោ សកិលេសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អរហា វីតរាគោ និទ្ទោសោ និម្មោហោ និម្មានោ និម្មក្ខោ និប្បឡាសោ និរុបាយាសោ និក្កិលេសោតិ ។ អាមន្តា ។ ហញ្ចិ អរហា វីតរាគោ ។ បេ ។ និក្កិលេសោ នោ វត វេ វត្តព្វេ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។

ព្រោះហេតុនោះ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ទេ ។

ចប់អវិវិត្តកថា ។

# សញ្ញោជនកថា

[៤០៧] ការដល់ព្រះអរហត្ត ព្រោះមិនលះបង់សញ្ញោជនៈតិចតួចមានដែរឬ ។ អើ ។ ការដល់ព្រះអរហត្ត ព្រោះមិនលះសក្កាយទិដ្ឋិ ។ បេ ។ ព្រោះមិនលះវិចិកិច្ឆា ។ បេ ។ ព្រោះមិនលះសីលព្វតបរាមាសៈ ព្រោះមិនលះរាគៈ ព្រោះមិនលះទោសៈ ព្រោះមិនលះមោហៈ ។ បេ ។ ព្រោះមិនលះអនោត្តប្បៈតិចតួច មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៨] ការដល់ព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួចមានដែរឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ ប្រកបដោយមានះ ប្រកបដោយមក្ខៈ ប្រកបដោយបឡាសៈ ប្រកបដោយឧបាយាសៈ ប្រកបដោយកិលេសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្ត មិនមានរាគៈ មិនមានទោសៈ មិនមានមោហៈ មិនមានមានះ មិនមានមក្ខៈ មិនមានបឡាសៈ មិនមានឧបាយាសៈ មិនមានកិលេសទេឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត មិនមានរាគៈ ។ បេ ។ មិនមានកិលេសទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មានទេ ។

[៤០៩] ន វត្តព្វំ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។ អាមន្តា ។ អរហំ សព្វំ ពុទ្ធវិសយំ ជានាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។

សញ្ញោជនកថា ។

# ឥទ្ធិកថា

[៤១០] អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ អាមន្តា ។ និច្ចបណ្ណា រុក្ខា ហោន្តូតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និច្ចបុប្ផា រុក្ខា ហោន្តុ ។ បេ ។ និច្ចផលិកា រុក្ខា ហោន្តុ និច្ចំ ជុណ្ហំ ហោតុ និច្ចំ ខេមំ ហោតុ និច្ចំ សុភិក្ខំ ហោតុ និច្ចំ សុវុដ្ឋិកំ ហោតូតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ អាមន្តា ។ ឧប្បន្នោ ផស្សោ មា និរុជ្ឈីតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។

[៤០៩] បុគ្គលមិនគួរនិយាយថា ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មានទេឬ ។ អើ ។ ព្រះអរហន្ត ដឹងនូវពុទ្ធ-វិស័យទាំងអស់ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួចមាន ។

ចប់ សញ្ញោជនកថា ។

# ឥទ្ធិកថា

[៤១០] សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី មានដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី ថា ឈើទាំងឡាយ ចូរមានស្លឹកជានិច្ចដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី ថា ឈើទាំងឡាយ ចូរមានផ្កាជានិច្ច ។ បេ ។ ឈើទាំងឡាយ ចូរមានផ្លែជានិច្ច ចូរត្រជាក់ត្រជុំជានិច្ច ចូរមានសេចក្តីក្សេមជានិច្ច ចូរមានបាយធាយជានិច្ច ចូរមានភ្លៀងស្រួលជានិច្ចដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី មានដែរឬ ។ អើ ។ សេច-ក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី ថា ផស្សៈ កើតឡើងហើយ កុំរលត់ទៅវិញឡើយដូច្នេះ មានដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ឧប្បន្នា វេទនា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា ។ បេ ។ ចិត្តំ សទ្ធា វីរិយំ សតិ សមាធិ ។ បេ ។ បញ្ញា មា និរុជ្ឈីតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១១] អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ អាមន្តា ។ រូបំ និច្ចំ ហោតូតិ អត្ថិ អធិប្បាយឥទ្ធិ វេទនា សញ្ញា សង្ខារា ។ បេ ។ វិញ្ញាណំ និច្ចំ ហោតូតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១២] អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ អាមន្តា ។ ជាតិធម្មា សត្តា មា ជាយឹសូតិ អត្ថិ ។ បេ ។ ជរាធម្មា សត្តា មា ជីរឹសូតិ ។ បេ ។ ព្យាធិធម្មា សត្តា មា ព្យាធិយឹសូតិ ។ បេ ។ មរណធម្មា សត្តា មា មិយ្យឹសូតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី ថា វេទនា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា ។ បេ ។ ចិត្ត សទ្ធា វិរិយៈ សតិ សមាធិ ។ បេ ។ បញ្ញា កើតឡើងហើយ កុំរលត់ទៅវិញឡើយដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤១១] សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី មានដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នាថា រូប ចូរទៀងដូច្នេះ មានដែរឬ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី ថា វេទនា សញ្ញា សង្ខារទាំងឡាយ ។ បេ ។ វិញ្ញាណ ចូរទៀងដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤១២] សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី មានដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវ័កទាំងឡាយក្តី ថា ពួកសត្វ មានជាតិជាធម្មតា កុំកើតឡើយដូច្នេះ មានដែរឬ ។ បេ ។ ថា ពួកសត្វ មានជរាជាធម្មតា កុំចាស់គ្រាំគ្រាឡើយដូច្នេះ ។ បេ ។ ថា ពួកសត្វ មានព្យាធិជាធម្មតា កុំឈឺចាប់ឡើយដូច្នេះ ។ បេ ។ ថា ពួកសត្វ មានមរណៈជាធម្មតា កុំស្លាប់ឡើយដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

២៣៧

ពុទ្ធកថា

[៤១៣] ន វត្តព្វំ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ អាមន្តា ។ ននុ អាយស្មា បិលិន្ទវច្ឆោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស ចាសានំ សុវណ្ណន្តេ្វ អធិមុច្ចិ សុវណ្ណោ ច បន អាសីតិ ។ អាមន្តា ។ ហញ្ចិ អាយស្មា បិលិន្ទវច្ឆោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស ចាសានំ សុវណ្ណន្តេ្វ អធិមុច្ចិ សុវណ្ណោ ច បន អាសិ តេន វត រេ វត្តព្វេ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។

ឥទ្ធិកថា ។

# ពុទ្ធកថា

[៤១៤] អត្ថិ ពុទ្ធានំ ពុទ្ធេហិ ហីនាតិរេកតាតិ ។ អាមន្តា ។ សតិប្បដ្ឋានតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មប្បធានតោ ។ បេ ។ ឥទ្ធិបាទតោ ឥន្ទ្រិយតោ ពលតោ ពោជ្ឈង្គតោ វសីភាវតោ ។ បេ ។ សព្វញ្ញុតញ្ញាណទស្សនតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពុទ្ធកថា ។

[៦១៣] *បុគ្គលមិនគួរនិយាយថា សេចក្ដីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្ដី នៃសាវ័កទាំងឡាយក្ដី មានទេឬ ។ អើ ។ ក្រែងព្រះបិលិន្ទវច្ឆៈមានអាយុ មុជជ្រែកប្រាសាទមាស របស់ស្ដេច ទ្រង់ព្រះនាម មាគធសេនិយពិម្ពិសារ ចុះមាស មាននៅជាធម្មតាឬ ។ អើ ។ ប្រសិនបើ បិលិន្ទវច្ឆៈមានអាយុ មុជជ្រែកប្រាសាទមាស របស់ស្ដេច ទ្រង់ព្រះនាម មាគធសេនិយពិម្ពិសារ មាស មាននៅជាធម្មតា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សេចក្ដីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្ដី នៃសាវ័កទាំងឡាយក្ដី មាន ។*

ចប់ ឥទ្ធិកថា ។

# ពុទ្ធកថា

[៦១៤] *ការៈនៃព្រះពុទ្ធទាំងឡាយ ថោកទាបនិងថ្លៃថ្លា ជាងព្រះពុទ្ធទាំងឡាយ មានដែរឬ ។ អើ ។ (ការៈនៃព្រះពុទ្ធទាំងឡាយ ថោកទាបនិងថ្លៃថ្លា ជាងព្រះពុទ្ធទាំងឡាយ) ដោយសតិប្បដ្ឋានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយសម្មប្បធាន ។ បេ ។ ដោយឥទ្ធិបាទ ដោយឥន្ទ្រិយ ដោយពលៈ ដោយពោជ្ឈង្គៈ ដោយវសីភាព ។ បេ ។ ដោយសព្វញ្ញុតញ្ញាណទស្សនៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

ចប់ ពុទ្ធកថា ។

# សព្វទិសាកថា

[៤១៨] សព្វា ទិសា ពុទ្ធា តិដ្ឋន្តីតិ ។ អាមន្តា ។ បុរត្ថិមាយ ទិសាយ ពុទ្ធោ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បុរត្ថិមាយ ទិសាយ ពុទ្ធោ តិដ្ឋតីតិ ។ អាមន្តា ។ កិន្នាមោ សោ ភគវា កឹជច្ចោ កឹគោត្តោ កិន្នាមា តស្ស ភគវតោ មាតាបិតរោ កិន្នាមំ តស្ស ភគវតោ សាវកយុគំ កោនាមោ តស្ស ភគវតោ ឧបដ្ឋាកោ កីទិសំ ចីវរំ ធារេតិ កីទិសំ បត្តំ ធារេតិ កតរស្មឹ គាមេ វា និគមេ វា នគរេ វា រដ្ឋេ វា ជនបទេ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទក្ខិណាយ ទិសាយ ។ បេ ។ បច្ឆិមាយ ទិសាយ ។ បេ ។ ឧត្តរាយ ទិសាយ ។ បេ ។ ហេដ្ឋិមាយ ទិសាយ ពុទ្ធោ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ហេដ្ឋិមាយ ទិសាយ ពុទ្ធោ តិដ្ឋតីតិ ។ អាមន្តា ។ កិន្នាមោ សោ ភគវា ។ បេ ។ ជនបទេ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឧបរិមាយ ទិសាយ ពុទ្ធោ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឧបរិមាយ ទិសាយ ពុទ្ធោ តិដ្ឋតីតិ ។ អាមន្តា ។ ចាតុម្មហារាជិកេ តិដ្ឋតិ ។ បេ ។ តាវតឹសេ តិដ្ឋតិ

# សព្វទិសាកថា

[៤១៥] ព្រះពុទ្ធទាំងឡាយ ឋិតនៅសព្វទិសឬ ។ អើ ។ ព្រះពុទ្ធឋិតនៅ ក្នុងទិសខាងកើតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះពុទ្ធឋិតនៅ ក្នុងទិសខាងកើតឬ ។ អើ ។ ព្រះមានព្រះភាគអង្គនោះមានព្រះនាមដូចម្តេច មានជាតិដូចម្តេច មានគោត្រដូចម្តេច មាតាបិតារបស់ព្រះមានព្រះភាគអង្គនោះ មាននាមដូចម្តេច គូនៃសាវ័ក របស់ព្រះមានព្រះភាគអង្គនោះ មាននាមដូចម្តេច ឧបដ្ឋាក របស់ព្រះមានព្រះភាគអង្គនោះ មាននាមដូចម្តេច ទ្រទ្រង់ចីវរ យ៉ាងណា ទ្រទ្រង់បាត្រ យ៉ាងណា (គង់នៅ) ក្នុងស្រុកឬនិគម ក្នុងនគរឬដែន ឬក៏ជនបទណា ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះពុទ្ធឋិតនៅ ក្នុងទិសខាងត្បូង ។ បេ ។ ក្នុងទិសខាងលិច ។ បេ ។ ក្នុងទិសខាងជើង ។ បេ ។ ក្នុងទិសខាងក្រោមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះពុទ្ធឋិតនៅ ក្នុងទិសខាងក្រោមឬ ។ អើ ។ ព្រះមានព្រះភាគអង្គនោះមានព្រះនាមដូចម្តេច ។ បេ ។ (គង់នៅ) ក្នុងជនបទណា ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះពុទ្ធឋិតនៅ ក្នុងទិសខាងលើឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះពុទ្ធឋិតនៅ ក្នុងទិសខាងលើឬ ។ អើ ។ ព្រះពុទ្ធឋិតនៅ ក្នុងចាតុម្មហារាជិកា ។ បេ ។ ឋិតនៅក្នុងតាវត្តិង្ស

យាមេ តិដ្ឋតិ តុសិតេ តិដ្ឋតិ និម្មានរតិយា តិដ្ឋតិ បរនិម្មិតវសវត្តិយា តិដ្ឋតិ ។ បេ ។ ព្រហ្មលោកេ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សព្វទិសាកថា ។

# ធម្មកថា

[៤១៦] សព្វេ ធម្មា និយតាតិ ។ អាមន្តា ។ មិច្ឆត្តនិយតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មត្តនិយតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ អនិយតោ រាសីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អត្ថិ អនិយតោ រាសីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អនិយតោ រាសិ នោ វត រេ វត្តព្វេ សព្វេ ធម្មា និយតាតិ ។

[៤១៧] សព្វេ ធម្មា និយតាតិ ។ អាមន្តា ។ ននុ តយោ រាសី វុត្តា ភគវតា មិច្ឆត្តនិយតោ រាសិ សម្មត្តនិយតោ រាសិ អនិយតោ រាសីតិ ។ អាមន្តា ។ ហញ្ចិ តយោ រាសី វុត្តា ភគវតា មិច្ឆត្តនិយតោ រាសិ សម្មត្តនិយតោ រាសិ អនិយតោ រាសិ នោ វត រេ វត្តព្វេ សព្វេ ធម្មា និយតាតិ ។

*ឋិតនៅ ក្នុងយាមៈ ឋិតនៅ ក្នុងតុសិត ឋិតនៅ ក្នុងនិម្មានរតី ឋិតនៅ ក្នុងបរនិម្មិតវសវត្តី ។ បេ ។ ឋិតនៅ ក្នុងព្រហ្មលោកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

ចប់ សព្វទិសាកថា ។

# ធម្មកថា

[៦១៦] *ពួកធម៌ទាំងអស់ ជានិយតៈឬ ។ អើ ។ (ពួកធម៌ទាំងអស់) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (ពួកធម៌ទាំងអស់) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ គំនរ ជាអនិយតៈ មិនមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងគំនរ ជាអនិយតៈ មានដែរឬ ។ អើ ។ ប្រសិនបើ គំនរ ជាអនិយតៈ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌ទាំងអស់ ជានិយតៈទេ ។*

[៦១៧] *ពួកធម៌ទាំងអស់ជានិយតៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គំនរ ៣ យ៉ាង គឺគំនរ ជាមិច្ឆត្តនិយតៈ ១ គំនរ ជាសម្មត្តនិយតៈ ១ គំនរ ជាអនិយតៈ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គំនរ ៣ យ៉ាង គឺគំនរ ជាមិច្ឆត្តនិយតៈ ១ គំនរ ជាសម្មត្តនិយតៈ ១ គំនរ ជាអនិយតៈ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកធម៌ទាំងអស់ ជាអនិយតៈទេ ។*

[៤១៨] រូបំ រូបដ្ឋេន និយតន្តិ ។ អាមន្តា ។ មិច្ឆត្តនិយតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មត្តនិយតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ វិញ្ញាណដ្ឋេន និយតន្តិ ។ អាមន្តា ។ មិច្ឆត្តនិយតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មត្តនិយតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៩] ន វត្តព្វំ រូបំ រូបដ្ឋេន និយតំ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ វិញ្ញាណដ្ឋេន និយតន្តិ ។ អាមន្តា ។ រូបំ ហោតិ វេទនា ហោតិ សញ្ញា ហោតិ សង្ខារា ហោន្តិ វិញ្ញាណំ ហោតិ វេទនា សញ្ញា សង្ខារា ។ បេ ។ វិញ្ញាណំ រូបំ ហោតិ វេទនា ហោតិ សញ្ញា ហោតិ សង្ខារា ហោន្តីតិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ រូបំ រូបដ្ឋេន និយតំ វេទនា ។ បេ ។ សញ្ញា សង្ខារា ។ បេ ។ វិញ្ញាណំ វិញ្ញាណដ្ឋេន និយតន្តិ ។

ធម្មកថា ។

[៤១៨] រូប ជានិយតៈ ដោយអត្ថថាវិនាសឬ ។ អើ ។ (រូប) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (រូប) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារទាំងឡាយ ។ បេ ។ វិញ្ញាណ ជានិយតៈ ដោយអត្ថថាដឹងច្បាស់ឬ ។ អើ ។ (វិញ្ញាណ) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (វិញ្ញាណ) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤១៩] បុគ្គលមិនគួរនិយាយថា រូប ជានិយតៈ ដោយអត្ថថាវិនាស ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារទាំងឡាយ ។ បេ ។ វិញ្ញាណ ជានិយតៈ ដោយអត្ថថាដឹងច្បាស់ទេឬ ។ អើ ។ រូប ក៏មាន វេទនា ក៏មាន សញ្ញា ក៏មាន សង្ខារទាំងឡាយ ក៏មាន វិញ្ញាណ ក៏មាន វេទនា សញ្ញា សង្ខារទាំងឡាយ ។ បេ ។ វិញ្ញាណ រូប ក៏មាន វេទនា ក៏មាន សញ្ញា ក៏មាន សង្ខារទាំងឡាយ ក៏មាន ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រោះហេតុនោះ រូប ជានិយតៈ ដោយអត្ថថាវិនាស វេទនា ។ បេ ។ សញ្ញា សង្ខារទាំងឡាយ ។ បេ ។ វិញ្ញាណ ជានិយតៈ ដោយអត្ថថាដឹងច្បាស់ ។

ចប់ ធម្មកថា ។

# កម្មកថា

[៤២០] សព្វេ កម្មា និយតាតិ ។ អាមន្តា ។ មិច្ឆត្តនិយតាតិ ។ អាមន្តា ។ មិច្ឆត្តនិយតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មត្តនិយតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ អនិយតោ រាសីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អត្ថិ អនិយតោ រាសីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អនិយតោ រាសិ នោ វត រេ វត្តព្វេ សព្វេ កម្មា និយតាតិ ។

[៤២១] សព្វេ កម្មា និយតាតិ ។ អាមន្តា ។ ននុ តយោ រាសី វុត្តា ភគវតា មិច្ឆត្តនិយតោ រាសិ សម្មត្តនិយតោ រាសិ អនិយតោ រាសីតិ ។ អាមន្តា ។ ហញ្ចិ តយោ រាសី វុត្តា ភគវតា មិច្ឆត្តនិយតោ រាសិ សម្មត្តនិយតោ រាសិ អនិយតោ រាសិ នោ វត រេ វត្តព្វេ សព្វេ កម្មា និយតាតិ ។

[៤២២] ទិដ្ឋធម្មវេទនិយំ កម្មំ ទិដ្ឋធម្មវេទនិយដ្ឋេន និយតន្តិ ។ អាមន្តា ។ មិច្ឆត្តនិយតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មត្តនិយតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឧបបជ្ជវេទនិយំ កម្មំ ។ បេ ។

# កម្មកថា

[៤២០] ពួកកម្មទាំងអស់ ជានិយតៈឬ ។ អើ ។ (ពួកកម្មទាំងអស់) ជាមិច្ឆត្តនិយតៈឬ ។ អើ ។ (ពួកកម្មទាំងអស់) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (ពួកកម្មទាំងអស់) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ គំនរ ជាអនិយតៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងគំនរ ជាអនិយតៈ មានដែរឬ ។ អើ ។ ប្រសិនបើគំនរ ជាអនិយតៈ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកកម្មទាំងអស់ ជានិយតៈទេ ។

[៤២១] ពួកកម្មទាំងអស់ ជានិយតៈឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គំនរ មាន ៣ យ៉ាងគឺ គំនរ ជាមិច្ឆត្តនិយតៈ ១ គំនរ ជាសម្មត្តនិយតៈ ១ គំនរ ជាអនិយតៈ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គំនរ មាន ៣ យ៉ាងគឺ គំនរ ជាមិច្ឆត្តនិយតៈ ១ គំនរ ជាសម្មត្តនិយតៈ ១ គំនរ ជាអនិយតៈ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ពួកកម្មទាំងអស់ ជានិយតៈទេ ។

[៤២២] ទិដ្ឋធម្មវេទនិយកម្ម ជានិយតៈ ដោយអត្ថថាបុគ្គលគប្បីទទួលក្នុងបច្ចុប្បន្នឬ ។ អើ ។ (ទិដ្ឋធម្មវេទនិយកម្ម) ជាមិច្ឆត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (ទិដ្ឋធម្មវេទនិយកម្ម) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ឧបបជ្ជវេទនិយកម្ម ។ បេ ។

អបរាបរិយវេទនិយំ កម្មំ អបរាបរិយវេទនិយដ្ឋេន និយតន្តិ ។ អាមន្តា ។ មិច្ឆត្តនិយតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មត្តនិយតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២៣] ន វត្តព្វំ ទិដ្ឋធម្មវេទនិយំ កម្មំ ទិដ្ឋធម្មវេទនិយដ្ឋេន និយតំ ឧបបជ្ជវេទនិយំ កម្មំ ។ បេ ។ អបរាបរិយវេទនិយំ កម្មំ អបរាបរិយវេទនិយដ្ឋេន និយតន្តិ ។ អាមន្តា ។ ទិដ្ឋធម្មវេទនិយំ កម្មំ ឧបបជ្ជវេទនិយំ ហោតិ អបរាបរិយវេទនិយំ ហោតិ ។ បេ ។ ឧបបជ្ជវេទនិយំ កម្មំ ទិដ្ឋធម្មវេទនិយំ ហោតិ អបរាបរិយវេទនិយំ ហោតិ ។ បេ ។ អបរាបរិយវេទនិយំ កម្មំ ទិដ្ឋធម្មវេទនិយំ ហោតិ ឧបបជ្ជវេទនិយំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ ទិដ្ឋធម្មវេទនិយំ កម្មំ ទិដ្ឋធម្មវេទនិយដ្ឋេន និយតំ ឧបបជ្ជវេទនិយំ កម្មំ ។ បេ ។ អបរាបរិយវេទនិយំ កម្មំ អបរាបរិយវេទនិយដ្ឋេន និយតន្តិ ។

កម្មកថា ។

ឯកវីសតិមោ វគ្គោ ។

*អបរាបរិយវេទនិយកម្ម ជានិយតៈ ដោយអត្ថថាបុគ្គលគប្បីទទួលក្នុងជាតិជាលំដាប់តទៅឬ ។ អើ ។ (អបរាបរិយវេទនិយកម្ម) ជាមិច្ឆត្តនិយតៈ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (អបរាបរិយវេទនិយ-កម្ម) ជាសម្មត្តនិយតៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

*[៤២៣] បុគ្គលមិនគួរនិយាយថា ទិដ្ឋធម្មវេទនិយកម្ម ជានិយតៈ ដោយអត្ថថាបុគ្គលគប្បីទទួលក្នុងបច្ចុប្បន្ន ឧបបជ្ជវេទនិយកម្ម ។ បេ ។ អបរាបរិយវេទនិយកម្ម ជានិយតៈ ដោយអត្ថថា បុគ្គលគប្បីទទួលក្នុងជាតិជាលំដាប់តទៅឬ ។ អើ ។ ទិដ្ឋធម្មវេទនិយកម្ម ជាឧបបជ្ជវេទ-និយៈ ក៏មាន ជាអបរាបរិយវេទនិយៈ ក៏មាន ។ បេ ។ ឧបបជ្ជវេទនិយ-កម្ម ជាទិដ្ឋធម្មវេទនិយៈ ក៏មាន ជាអបរាបរិយវេទនិយៈ ក៏មាន ។ បេ ។ អបរាបរិយវេទនិយកម្ម ជាទិដ្ឋធម្មវេទនិយៈ ក៏មាន ជាឧបបជ្ជវេទនិយៈ ក៏មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ទិដ្ឋធម្មវេទនិយកម្ម ជានិយតៈ ដោយអត្ថថាបុគ្គលគប្បីទទួលក្នុងបច្ចុប្បន្ន ឧបបជ្ជវេទនិយកម្ម ។ បេ ។ អបរាបរិយវេទនិយកម្ម ជានិយតៈ ដោយអត្ថថា បុគ្គលគប្បីទទួលក្នុងជាតិជាលំដាប់តទៅ ។*

ចប់ កម្មកថា ។

ចប់ ឯកវីសតិមវគ្គ ។

២៤៣

# តស្ស ឧទ្ទានំ

សាសនំ នវំ កតំ អត្ថិ កោចិ តថាគតស្ស សាសនំ នវំ ករោតិ លព្ភា តថាគតស្ស សាសនំ បុន នវំ កាតុំ បុថុជ្ជនោ តេជាតុ-កោហិ ធម្មេហិ អរីរិត្តោ អត្ថិ កិញ្ចិ សញ្ញោ-ជនំ អប្បហាយ អរហត្តប្បត្តិ អត្ថិ អធិប្បាយ-ឥទ្ធិ ពុទ្ធានំ វា សាវកានំ វា អត្ថិ ពុទ្ធានំ ពុទ្ធេហិ ហីនាតិរេកតា សព្វា ទិសា ពុទ្ធា តិដ្ឋន្តិ សព្វេ ធម្មា និយតា សព្វេ កម្មា និយតាតិ ។

# ឧទ្ទាននៃវគ្គនោះ គឺ

និយាយអំពី សាសនា ដែលបុគ្គលធ្វើជាថ្មី បុគ្គលណាមួយធ្វើសាសនានៃតថាគតជាថ្មី មាន បុគ្គលបាន ដើម្បីធ្វើសាសនានៃតថាគត ជាថ្មីវិញ ១ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុបី ១ ការដល់នូវព្រះអរហត្តព្រោះមិនលះបង់សញ្ញោជនៈ តិចតួច មាន ១ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំង-ឡាយក្តី មាន ១ ភារៈនៃព្រះពុទ្ធទាំងឡាយ ថោកទាបនិងថ្លៃថ្លាជាងព្រះពុទ្ធទាំងឡាយ មាន ១ ព្រះពុទ្ធទាំងឡាយបិតនៅសព្វទិស ១ ពួកធម៌ទាំងអស់ ជានិយតៈ ១ ពួកកម្មទាំងអស់ ជានិយតៈ ១ ។

---

# បរិនិព្វានកថា

[៤២៤] អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ បរិនិព្វានន្តិ ។ អាមន្តា ។ អត្ថិ កិញ្ចិ សក្កាយទិដ្ឋឹ អប្បហាយ ។ បេ ។ អនោត្តប្បំ អប្បហាយ បរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២៥] អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ បរិនិព្វានន្តិ ។ អាមន្តា ។ អរហា សរាគោ ។ បេ ។ សកិលេសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អរហា វីតរាគោ ។ បេ ។ និក្កិលេសោតិ ។ អាមន្តា ។ ហញ្ចិ អរហា វីតរាគោ ។ បេ ។ និក្កិលេសោ នោ វត រេ វត្តព្វេ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ បរិនិព្វានន្តិ ។

[៤២៦] ន វត្តព្វំ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ បរិនិព្វានន្តិ ។ អាមន្តា ។ អរហា សព្វំ ពុទ្ធវិសយំ ជានាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ បរិនិព្វានន្តិ ។

បរិនិព្វានកថា ។

# បរិនិព្វានកថា

[៤២៤] បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈ តិចតួច មាន ដែរឬ ។ អើ ។ បរិនិព្វាន ព្រោះមិនលះបង់សក្កាយទិដ្ឋិ ។ បេ ។ ព្រោះមិនលះបង់អនោត្តប្បៈ តិចតួច មានដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[៤២៥] បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈ តិចតួច មានដែរ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយរាគៈ ។ បេ ។ ប្រកបដោយកិលេស ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្ត មិនមានរាគៈ ។ បេ ។ មិនមានកិលេសទេឬ ។ អើ ។ ប្រសិនបើ ព្រះ អរហន្ត មិនមានរាគៈ ។ បេ ។ មិនមានកិលេសទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈ តិចតួច មានទេ ។

[៤២៦] បុគ្គលមិនគួរនិយាយថា បរិនិព្វាន ព្រោះមិនលះបង់ សញ្ញោជនៈ តិចតួច មានទេឬ ។ អើ ។ ព្រះអរហន្ត ដឹងពុទ្ធវិស័យ ទាំងអស់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ បរិនិព្វាន ព្រោះមិនលះបង់សញ្ញោជនៈ តិចតួច មាន ។

ចប់ បរិនិព្វានកថា ។

# កុសលចិត្តកថា

[៤២៧] អរហា កុសលចិត្តោ បរិនិព្វាយតីតិ ។ អាមន្តា ។ អរហា បុញ្ញាភិសង្ខារំ អភិសង្ខរោន្តោ អានេញ្ជាភិសង្ខារំ អភិសង្ខរោន្តោ គតិសំវត្តនិយំ កម្មំ ករោន្តោ ភវសំវត្តនិយំ កម្មំ ករោន្តោ ឥស្សរិយសំវត្តនិយំ កម្មំ ករោន្តោ អធិបច្ចសំវត្តនិយំ កម្មំ ករោន្តោ មហាភោគសំវត្តនិយំ កម្មំ ករោន្តោ មហាបរិវារសំវត្តនិយំ កម្មំ ករោន្តោ ទេវសោភគ្យសំវត្តនិយំ កម្មំ ករោន្តោ មនុស្សសោភគ្យសំវត្តនិយំ កម្មំ ករោន្តោ បរិនិព្វាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២៨] អរហា កុសលចិត្តោ បរិនិព្វាយតីតិ ។ អាមន្តា ។ អរហា អាចិនន្តោ អបចិនន្តោ បជហន្តោ ឧបាទិយន្តោ វិសិនេន្តោ ឧស្សិនេន្តោ វិធូបេន្តោ ។ បេ ។ សន្ធូបេន្តោ បរិនិព្វាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អរហា នេវាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា នេវាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោ នោ វត រេ វត្តព្វេ អរហា កុសលចិត្តោ បរិនិព្វាយតីតិ ។

# កុសលចិត្តកថា

[៤២៧] ព្រះអរហន្ត មានកុសលចិត្ត ហើយបរិនិព្វានឬ ។ អើ ។ ព្រះអរហន្ត តាក់តែងបុញ្ញាភិសង្ខារ តាក់តែងអានេញ្ជាភិសង្ខារ ធ្វើកម្មប្រព្រឹត្តទៅដើម្បីគតិ ធ្វើកម្មប្រព្រឹត្តទៅដើម្បីភព ធ្វើកម្មប្រព្រឹត្តទៅដើម្បីភាពជាធំ ធ្វើកម្មប្រព្រឹត្តទៅដើម្បីភាពជាអធិបតី ធ្វើកម្មប្រព្រឹត្តទៅដើម្បីមានភោគៈច្រើន ធ្វើកម្មប្រព្រឹត្តទៅដើម្បីមានបរិវារច្រើន ធ្វើកម្មប្រព្រឹត្តទៅដើម្បីលម្អដ៏លើសក្នុងទេវលោក ធ្វើកម្មប្រព្រឹត្តទៅដើម្បីលម្អដ៏លើសក្នុងមនុស្សលោក ទើបបរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤២៨] ព្រះអរហន្ត មានកុសលចិត្ត ហើយបរិនិព្វានឬ ។ អើ ។ ព្រះអរហន្ត កាលសន្សំ កាលមិនសន្សំ កាលលះបង់ កាលប្រកាន់ កាលកកាយចេញ កាលកៀរគរ កាលកម្ចាត់ចេញ ។ បេ ។ កាលប្រមូលមក ទើបបរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្ត មិនសន្សំ មិនមែនជាមិនសន្សំ លុះមិនសន្សំហើយឋិតនៅឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត មិនសន្សំ មិនមែនជាមិនសន្សំ លុះមិនសន្សំហើយឋិតនៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត មានកុសលចិត្ត ហើយបរិនិព្វានទេ ។

ននុ អរហា នេវ បជហតិ ន ឧចាទិយតិ បជហិត្វា ឋិតោ នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ ននុ អរហា នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ នោ វត រេ វត្តព្វេ អរហា កុសលចិត្តោ បរិនិព្វាយតីតិ ។

[៤២៩] ន វត្តព្វំ អរហា កុសលចិត្តោ បរិនិព្វាយតីតិ ។ អាមន្តា ។ ននុ អរហា ឧបដ្ឋិតស្សតិ សតោ សម្បជានោ បរិនិព្វាយតីតិ ។ អាមន្តា ។ ហញ្ចិ អរហា ឧបដ្ឋិតស្សតិ សតោ សម្បជានោ បរិនិព្វាយតិ តេន វត រេ វត្តព្វេ អរហា កុសលចិត្តោ បរិនិព្វាយតីតិ ។

កុសលចិត្តកថា ។

# អានេញ្ជកថា

[៤៣០] អរហា អានេញ្ជេ ឋិតោ បរិនិព្វាយតីតិ ។ អាមន្តា ។ ននុ អរហា បកតិចិត្តេ ឋិតោ បរិនិព្វាយតីតិ ។ អាមន្តា ។ ហញ្ចិ អរហា

ក្រែងព្រះអរហន្ត មិនលះបង់ មិនប្រកាន់ លុះលះបង់ហើយឋិតនៅ មិនកកាយចេញ មិនកៀរគរ លុះមិនកកាយចេញហើយឋិតនៅ ក្រែងព្រះអរហន្ត មិនកម្ចាត់ចេញ មិនប្រមូលមក លុះកម្ចាត់ចេញហើយឋិតនៅ ឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត មិនកម្ចាត់ចេញ មិនប្រមូលមក លុះកម្ចាត់ចេញហើយឋិតនៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត មានកុសលចិត្ត ហើយបរិនិព្វានទេ ។

[៤២៩] បុគ្គលមិនគួរនិយាយថា ព្រះអរហន្ត មានកុសលចិត្ត ហើយបរិនិព្វានទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មានសតិតម្កល់នៅស៊ប់ មានស្មារតី ដឹងខ្លួន ហើយបរិនិព្វានឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត មានសតិតម្កល់នៅស៊ប់ មានស្មារតី ដឹងខ្លួន ហើយបរិនិព្វាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត មានកុសលចិត្ត ហើយបរិនិព្វាន ។

ចប់ កុសលចិត្តកថា ។

# អានេញ្ជកថា

[៤៣០] ព្រះអរហន្ត ឋិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានឬ ។ អើ ។ ក្រែងព្រះអរហន្ត ឋិតនៅក្នុងបកតិចិត្ត[១] (ចិត្តជាប្រក្រតី) ហើយបរិនិព្វានឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត

១ បានដល់ភវង្គចិត្ត ។

បកតិចិត្តេ ឋិតោ បរិនិព្វាយតិ ឆោ វត រេ វត្តព្វេ អរហា អានេញ្ជេ ឋិតោ បរិនិព្វាយតីតិ ។

[៤៣១] អរហា អានេញ្ជេ ឋិតោ បរិនិព្វាយតីតិ ។ អាមន្តា ។ អរហា កិរិយមយេ ចិត្តេ ឋិតោ បរិនិព្វាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឆន្ទុ អរហា វិបាកចិត្តេ ឋិតោ បរិនិព្វាយតីតិ ។ អាមន្តា ។ ហញ្ចិ អរហា វិបាកចិត្តេ ឋិតោ បរិនិព្វាយតិ ឆោ វត រេ វត្តព្វេ អរហា អានេញ្ជេ ឋិតោ បរិនិព្វាយតីតិ ។

[៤៣២] អរហា អានេញ្ជេ ឋិតោ បរិនិព្វាយតីតិ ។ អាមន្តា ។ អរហា កិរិយាព្យាកតេ ចិត្តេ ឋិតោ បរិនិព្វាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឆន្ទុ អរហា វិបាកាព្យាកតេ ចិត្តេ ឋិតោ បរិនិព្វាយតីតិ ។ អាមន្តា ។ ហញ្ចិ អរហា វិបាកាព្យាកតេ ចិត្តេ ឋិតោ បរិនិព្វាយតិ ឆោ វត រេ វត្តព្វេ អរហា អានេញ្ជេ ឋិតោ បរិនិព្វាយតីតិ ។

ឋិតនៅ ក្នុងបកតិចិត្ត ហើយបរិនិព្វាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ឋិតនៅ ក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិ-និព្វានទេ ។

[៤៣១] ព្រះអរហន្ត ឋិតនៅ ក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានឬ ។ អើ ។ ព្រះអរហន្ត ឋិតនៅក្នុងចិត្តដែលសម្រេចដោយកិរិយា ហើយបរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្ត ឋិតនៅ ក្នុងវិបាកចិត្ត ហើយបរិនិព្វានឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត ឋិតនៅ ក្នុងវិបាកចិត្ត ហើយបរិនិព្វាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ឋិតនៅ ក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានទេ ។

[៤៣២] ព្រះអរហន្ត ឋិតនៅក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិ-និព្វានឬ ។ អើ ។ ព្រះអរហន្ត ឋិតនៅ ក្នុងចិត្ត ជាកិរិយានិងអព្យាក្រឹត ហើយបរិនិព្វានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្ត ឋិតនៅ ក្នុងចិត្ត ជាវិបាកនិងអព្យាក្រឹត ហើយបរិនិព្វានឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត ឋិតនៅ ក្នុងចិត្ត ជាវិបាកនិងអព្យាក្រឹត ហើយបរិនិព្វាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ឋិតនៅ ក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានទេ ។

[៤៣៣] អរហា អានេញ្ជេ ឋិតោ បរិនិព្វាយតីតិ ។ អាមន្តា ។ ននុ ភគវា ចតុត្ថជ្ឈានា វុដ្ឋហិត្វា សមនន្តរា បរិនិព្វុតោតិ ។ អាមន្តា ។ ហញ្ចិ ភគវា ចតុត្ថជ្ឈានា វុដ្ឋហិត្វា សមនន្តរា បរិនិព្វុតោ នោ ច វត រេ វត្តព្វេ អរហា អានេញ្ជេ ឋិតោ បរិនិព្វាយតីតិ ។

អានេញ្ជកថា ។

# ធម្មាភិសមយកថា

[៤៣៤] អត្ថិ គព្ភសេយ្យាយ ធម្មាភិសមយោតិ ។ អាមន្តា ។ អត្ថិ គព្ភសេយ្យាយ ធម្មទេសនា ធម្មស្សវនំ ធម្មសាកច្ឆា បរិបុច្ឆា សីលសមាទានំ ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា បុព្វរត្តាបររត្តំ ជាគរិយានុយោគោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ គព្ភសេយ្យាយ ធម្មទេសនា ។ បេ ។ បុព្វរត្តាបររត្តំ ជាគរិយានុយោគោតិ ។ អាមន្តា ។ ហញ្ចិ នត្ថិ គព្ភសេយ្យាយ ធម្មទេសនា ធម្មស្សវនំ ។ បេ ។

[៤៣៣] ព្រះអរហន្ត ឋិតនៅ ក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ចេញចាកចតុត្ថជ្ឈាន ហើយបរិនិព្វាន ក្នុងលំដាប់ (អំពីចតុត្ថជ្ឈាននោះ) ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ចេញចាកចតុត្ថជ្ឈាន ហើយបរិនិព្វាន ក្នុងលំដាប់ (អំពីចតុត្ថជ្ឈាននោះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ឋិតនៅ ក្នុងសេចក្តីមិនញាប់ញ័រ ហើយបរិនិព្វានទេ ។

ចប់ អានេញ្ជកថា ។

# ធម្មាភិសមយកថា

[៤៣៤] ការត្រាស់ដឹងធម៌ នៃសត្វដែលដេកនៅក្នុងគភ៌ មានដែរឬ ។ អើ ។ ការសម្តែងធម៌ ការស្តាប់ធម៌ ការសាកសួរធម៌ ការដេញដោលសួរ ការសមាទានសីល ភាវៈនៃការគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ភាវៈនៃការដឹងប្រមាណ ក្នុងភោជន ការប្រកបរឿយ ៗ ក្នុងកិរិយាភ្ញាក់រលឹក អស់រាត្រីខាងដើមនិងរាត្រីខាងចុង នៃសត្វដែលដេកនៅក្នុងគភ៌ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសម្តែងធម៌ ។ បេ ។ ការប្រកបរឿយ ៗ ក្នុងកិរិយាភ្ញាក់រលឹក អស់រាត្រីខាងដើមនិងរាត្រីខាងចុង នៃសត្វដែលដេកនៅក្នុងគភ៌ មិនមានទេឬ ។ អើ ។ ប្រសិនបើ ការសម្តែងធម៌ ការស្តាប់ធម៌ ។ បេ ។

បុព្វវត្តាបរវត្តំ ជាតរិយានុយោគោ ជោ វត រេ វត្តព្វេ អត្ថិ កព្ភសេយ្យាយ ជម្មាភិសមយោតិ ។

[៤៣៥] អត្ថិ កព្ភសេយ្យាយ ជម្មាភិសមយោ-តិ ។ អាមន្តា ។ ននុ ទេ្វ បច្ចយា សម្មាជិដ្ឋិយា ឧប្បាទាយ បរតោ ច ឃោសោ យោនិសោ ច ម-នសិការោតិ ។ អាមន្តា ។ ហញ្ចិ ទេ្វ បច្ចយា សម្មាជិដ្ឋិយា ឧប្បាទាយ បរតោ ច ឃោសោ យោនិសោ ច មនសិការោ ជោ វត រេ វត្តព្វេ អត្ថិ កព្ភសេយ្យាយ ជម្មាភិសមយោតិ ។

[៤៣៦] អត្ថិ កព្ភសេយ្យាយ ជម្មាភិសមយោ-តិ ។ អាមន្តា ។ សុត្តស្ស បមត្តស្ស មុដ្ឋស្សតិស្ស អសម្បជានស្ស ជម្មាភិសមយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ការប្រកបរឿយ ៗ ក្នុងកិរិយាភ្ញាក់រលឹក អស់រាត្រីខាងដើមនិងរាត្រីខាងចុង នៃសត្វដែលដេកនៅក្នុងគភ៌ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការត្រាស់ដឹងធម៌ នៃសត្វដែលដេកនៅក្នុងគភ៌ មានទេ ។

[៤៣៥] ការត្រាស់ដឹងធម៌ នៃសត្វដែលដេកនៅក្នុងគភ៌ មានដែរឬ ។ អើ ។ ក្រែងបច្ច័យទាំងឡាយ ២ គឺ សំឡេងគឹកកង អំពីសំណាក់នៃបុគ្គលដទៃ ១ ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ១ ព្រោះអាស្រ័យសម្មាទិដ្ឋិ មានឬ ។ អើ ។ ប្រសិនបើ បច្ច័យទាំងឡាយ ២ គឺសំឡេងគឹកកង អំពីសំណាក់នៃបុគ្គលដទៃ ១ ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ១ ព្រោះអាស្រ័យសម្មាទិដ្ឋិ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការត្រាស់ដឹងធម៌ នៃសត្វដែលដេកនៅ ក្នុងគភ៌ មានទេ ។

[៤៣៦] ការត្រាស់ដឹងធម៌ នៃសត្វដែលដេកនៅ ក្នុងគភ៌ មានដែរឬ ។ អើ ។ ការត្រាស់ដឹងធម៌ នៃសត្វដែលដេកលក់ មានសេចក្ដីប្រមាទ មានសតិភ្លេច មិនដឹងខ្លួន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ធម្មាភិសមយកថា ។

# តិស្សោបិកថា

[៤៣៧] អត្ថិ កព្ភសេយ្យាយ អរហត្តប្បត្តីតិ ។ អាមន្តា ។ សុត្តស្ស បមត្តស្ស មុដ្ឋស្សតិស្ស អសម្បជានស្ស អរហត្តប្បត្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ សុបិនគតស្ស ធម្មាភិសមយោតិ ។ អាមន្តា ។ សុត្តស្ស បមត្តស្ស មុដ្ឋស្សតិស្ស អសម្បជានស្ស ធម្មាភិសមយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ សុបិនគតស្ស អរហត្តប្បត្តីតិ ។ អាមន្តា ។ សុត្តស្ស បមត្តស្ស មុដ្ឋស្សតិស្ស អសម្បជានស្ស អរហត្តប្បត្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

តិស្សោបិកថា ។

# អព្យាកតកថា

[៤៣៨] សព្វំ សុបិនគតស្ស ចិត្តំ អព្យាកតន្តិ ។ អាមន្តា ។ សុបិនន្តេន បាណំ ហនេយ្យាតិ ។ អាមន្តា ។ ហញ្ចិ សុបិនន្តេន បាណំ ហនេយ្យ នោ វត វេ វត្តព្វេ សព្វំ សុបិនគតស្ស ចិត្តំ អព្យាកតន្តិ ។

# តិស្សោបិកថា

